UNDP

UNIFEM

JAPAN
Official Development Assistance

# ការរួចផុតពីការរីកលូតលាស់

## ផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបនីយកម្ម
## មកលើស្ត្រីក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា

ត្រូវបានរៀបចំសម្រាប់គម្រោងយេនឌ័រ
និងគម្រោងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍
ខែ តុលា ឆ្នាំ ២០០៤

គម្រោងនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/

មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី
ត្រូវបានអនុវត្តក្នុងភាពជាដៃគូ
ជាមួយអង្គការសិលការ SILAKA

# ការរួចផុតការរីកលូតលាស់

## ផលប៉ះពាល់នៃពាណិជ្ជៈសេរីភាវូបនីយកម្ម
## មកលើស្ត្រីក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា

**ត្រូវបានរៀបចំសម្រាប់គម្រោងយេនឌ័រ**

**និងគម្រោងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍**

**ខែ តុលា ឆ្នាំ ២០០៤**

ដោយ : INGRID FITZGERALD

**មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី**
(UNIFEM)

## ការបូកបន្ថែម

*ឥទ្ធិពលនៃពាណិជ្ជសេរីភាវូបនីយកម្មលើស្ត្រីក្នុងវិស័យសំលៀកបំពាក់*

*ការសន្ទនាខាងនយោបាយរបស់អ្នកពាក់ព័ន្ធចម្រុះ*

*ថ្ងៃសុក្រទី១៤ខែមករា ឆ្នាំ២០០៥*

## លទ្ធផលសង្ខេប

ការសន្ទនានយោបាយរបស់អ្នកពាក់ព័ន្ធចម្រុះ ដែលទាក់ទិននឹងភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយអ្នកតំណាងឧស្សាហកម្មកាត់ដេរ និងកម្មករកាត់ដេរ បានជួបប្រជុំគ្នានៅឯសណ្ឋាគារសាន់វេភ្នំពេញ នៅថ្ងៃសុក្រ ទី១៤ ខែមករា ឆ្នាំ ២០០៥ ដើម្បីពិភាក្សាអំពីផលប៉ះពាល់ ពីកំណែទម្រង់ពាណិជ្ជកម្ម លើកម្មការិនីកាត់ដេរ ។ ក្រសួងកិច្ចការនារីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី ត្រូវបានកោះអញ្ជើញឱ្យចូលរួមប្រជុំដែលមានលោកបណ្ឌិតណូងលីន ហេហ្ស៊ែរ នាយកប្រតិបត្តិនៃមូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រីជាម្ចាស់រៀបចំកម្មវិធីទទួលភ្ញៀវ ។

វាគ្មិនទាំងឡាយនៅលើវេទិកានោះមាន បណ្ឌិត ហេហ្ស៊ែរ (Dr Heyzer) អ្នកស្រី រីកាដា រេជ័រ (Ms Ricarda Rerger) ជាតំណាងអនុប្រធានកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឯកឧត្តមញ៉ែប ប៊ុនជិន រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម សុខ ស៊ីផាណា ពីក្រសួងឧស្សាហកម្ម ព្រមទាំង តំណាងទាំងឡាយពីម្ចាស់ជំនួយ ពីអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការស្រាវជ្រាវ តំណាងពីកម្មករកាត់ដេរ និង ពីឧស្សាហកម្មកាត់ដេរផងដែរ ។

អ្នកចូលរួមសន្ទនានយោបាយទាំងនោះបានចង្អុលបង្ហាញនូវបរិបទនយោបាយសំខាន់ៗមួយចំនួននៅថ្នាក់ជាតិនិងអន្តរជាតិ ។ ក្នុងបរិបទសំខាន់នោះមានយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល នារីរតនៈទី២ ផែនការយុទ្ធសាស្ត្រថ្មីរយៈពេលប្រាំឆ្នាំដើម្បីស្ត្រី និងផែនការសកម្មភាពខាងយេនឌ័រដែលថ្មីៗនេះត្រូវបានបង្កើតឡើងដោយក្រុមការងារបច្ចេកទេសខាងយេនឌ័រ ។ លើសពីនេះទៀត គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងកិច្ចព្រមព្រៀងអន្តរជាតិ និងគម្រោងការទាំងឡាយ ដូចជាអនុសញ្ញាស្តីពីការលុបបំបាត់ចោល រាល់ទំរង់រើសអើងប្រឆាំងនឹងនារីភេទ CEDAW និង ប៉េកាំងបូក ១០ ទាំងអស់ នេះបានផ្តល់នូវបរិបទសំខាន់សម្រាប់បញ្ហានេះ ។

មានកិច្ចព្រមព្រៀងយ៉ាងប្រត្យក្សថាអនាគតផ្នែកកាត់ដេរគឺជាបញ្ហាសំខាន់អាយុជីវិតសំរាប់កម្ពុជា ជាពិសេសសម្រាប់ការផ្តល់សិទ្ធិអំណាចខាងសេដ្ឋកិច្ចដល់ស្ត្រី ការកាត់បន្ថយភាពក្រីក្រ និងសមធម៌យេនឌ័រ ។

ទោះជាយ៉ាងណាក៏ដោយ អ្នកចូលរួមបានសង្កត់ធ្ងន់នូវសេចក្តីត្រូវការដើម្បីផ្តោតមិនទៅលើតែស្ត្រីក្នុងផ្នែកកាត់ដេរប៉ុណ្ណោះទេថែមទាំងលើស្ត្រីក្នុងឧស្សាហកម្ម និងផ្នែកផ្សេងទៀតដែលក្នុងនោះមានស្ត្រី ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ ។ ជាការពិតណាស់ អ្នកចូលរួមបានយល់ស្របថា ត្រូវការឱ្យមានការយកចិត្តទុកដាក់លើផ្នែកសេដ្ឋក្រៅប្រព័ន្ធឱ្យបានកាន់តែខ្លាំងឡើងទៀត ហើយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) និងអង្គការពលកម្មអន្តរជាតិ បច្ចុប្បន្ននេះ កំពុងធ្វើការស្រាវជ្រាវ អំពី

ការងារសមរម្យក្នុងសេដ្ឋកិច្ច ក្រៅប្រព័ន្ធ ដែលអាចផ្តល់ចំណុចចាប់ផ្តើមល្អមួយដើម្បីពិនិត្យ បញ្ហាស្ត្រីដែលធ្វើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ ។ លើសពីនេះទៀត សិក្ខាកាមបាន អំពាវនាវឱ្យមានការយកចិត្តទុកដាក់ ខ្លាំងឡើងលើការងារសមស្របសំរាប់អ្នកទាំងឡាយណាដែលធ្វើការក្នុងសេដ្ឋកិច្ចផ្លូវការនិងមិនផ្លូវការ ។

ទោះបីជាអ្នកចូលរួមមួយចំនួន កត់សម្គាល់ថាស្ថានភាព មិនទំនងជានាំឱ្យមានហេតុការណ៍អាក្រក់ក្រៃលែងបំផុតក្តី ក៏គេបានយល់ស្របជាទូទៅថា ត្រូវតែឱ្យមានផែនការសំរាប់គ្រោះថ្នាក់ទាំងឡាយ ដែលស្ត្រីអាចប្រឈមមុខ និងសម្រាប់ជាមធ្យោបាយគ្រប់គ្រងជាទូទៅនូវភយន្តរាយនោះ ។

ការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់បន្តការសន្ទនាទាក់ទិននឹងឋានៈរបស់អ្នកពាក់ព័ន្ធទាំងឡាយដែលនឹងផ្តល់វេទិកាឱ្យមានទស្សនៈផ្សេងៗគ្នា ហើយបានធានាថាគេនឹងចាត់វិធានការយកចិត្តទុកដាក់ដល់សេចក្តីត្រូវការរបស់កម្មការិនីកាត់ដេរនិងដំណើរការត្រួតពិនិត្យ ។

អ្នកចូលរួមបានសម្តែង ការគាំទ្រដល់មធ្យោបាយដោះស្រាយ ដែលទទួលស្គាល់ថារដ្ឋាភិបាល ម្ចាស់ជំនួយឧស្សាហកម្មកាត់ដេរ អ្នកទទួលទិញ និងកម្មករចែករំលែកការទទួលខុសត្រូវរួម ដើម្បីធ្វើផែនការ ផ្តល់ថវិកាគាំទ្រ និងសេវាកម្មបណ្តុះបណ្តាលដល់កម្មករដែលក្នុងនោះមានទាំងអ្នកដែលត្រូវកាត់ចេញពីការងារផងដែរ ។ ផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបនីយកម្មលើកម្មការិនីកាត់ដេរ គឺជាបញ្ហាអន្តរជាតិនិងអនាគតវិស័យកាត់ដេរកម្ពុជាមួយផ្នែកធំ នឹងត្រូវកំណត់ទៅជាយ៉ាងណានោះ អាស្រ័យលើកិច្ចការជាអន្តរជាតិព្រមទាំងការឆ្លើយតបថ្នាក់ជាតិផងដែរ ។ ព្រោះហេតុនេះហើយ បានជាអ្នកចូលរួមយល់ស្របគ្នាថា វានឹងមានតម្លៃច្រើនណាស់ ដែលឱ្យមានការចូលរួមពិភាក្សានាពេល អនាគតពីតំណាងអន្តរជាតិនានានៃក្រុមអ្នកមានចំណាប់អារម្មណ៍ផ្សេងៗគ្នា(ដូចជាអ្នកទិញដូរ) ជាដើម ។

## រដ្ឋាភិបាល

តំណាងរដ្ឋាភិបាលបានពិភាក្សាអំពីគំនិតផ្តួចផ្តើមដែលជាប់ពាក់ព័ន្ធជាមួយរដ្ឋមួយចំនួន ក្នុងនោះមាន ៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំផែនការសកម្មភាពស្តីអំពីការអភិវឌ្ឍន៍ធនធានមនុស្សនិងផ្តោតផងដែរលើការត្រួតពិនិត្យការអនុវត្តច្បាប់ការងារ ។ លើសពីនេះទៀតក្រសួងនេះ បានទទួលបន្ទុក ក្នុងការបង្កើតយុទ្ធសាស្ត្រការងារល្អិតល្អន់ពេញលេញមួយ ។ ដោយសហការជាមួយក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សុំឱ្យមានការដាក់បញ្ចូល(គំនិត)(Input)របស់មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រីទៅក្នុងកិច្ចការរបស់ខ្លួនស្តីពីយុទ្ធសាស្ត្រការងារ ។ យុទ្ធសាស្ត្រនោះសំដៅបង្កើនសេចក្តីត្រូវការ ក្នុងស្រុកដើម្បីបង្កើតការងារនិងបង្កើនចំនួនកម្មករជំនាញនៅក្នុងកម្លាំងពលកម្ម ជាពិសេសក្នុងវិស័យកសិកម្ម ។
- ក្រសួងកិច្ចការនារីកំពុងធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីដើម្បីផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីទាំងឡាយ ។ ក្នុងការបណ្តុះបណ្តាលនេះនឹងមាន អជីវកោសល្យ(Life skill បំនិនជីវិត) ជំនាញក្នុងភាព ជាសហព្រស្ថ ការបណ្តុះបណ្តាលផ្នែកពាណិជ្ជកម្ម របៀបប្រើប្រាស់ឥណទានខ្នាតតូច ។
- ក្រសួងពាណិជ្ជកម្មបានកត់សម្គាល់ថា ធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងកិច្ចការនារី និងសមាគមផលិតករសំលៀកបំពាក់កម្ពុជា អង្គការពលកម្មអន្តរជាតិ បានចុះហត្ថលេខាលើអនុស្សរណៈព្រមព្រៀង ដើម្បីផ្តល់ការហ្វឹកហ្វឺនដល់កម្មករកាត់ដេរ តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលកាត់ដេរសំលៀកបំពាក់ ។ កម្មវិធីហ្វឹកហ្វឺនសំដៅរ៉ាប់រងកម្មករចូលថ្មី និងផ្តល់ជំនាញគ្រឹះសំខាន់ ដើម្បីបានការងារធ្វើដោយមិនចាំបាច់ បង់ប្រាក់ដល់អន្តរការី(អ្នករត់ការកណ្តាល) ជាថ្នូរនឹងការរកការងារឱ្យនោះទេ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបាន បង្កើនថវិកាសំរាប់ការផ្តួចផ្តើមនេះ ។ លើសពីនេះទៀតគេបានធានាការផ្តល់ថវិកា ដើម្បីឱ្យអង្គការ ពលកម្មអន្តរជាតិអាចបន្តត្រួតពិនិត្យមើលលក្ខខណ្ឌការងារក្នុងរោងចក្រទាំងឡាយដែលមានសារៈសំខាន់ដើម្បីឧបត្ថម្ភ គំនិតផ្តួចផ្តើមដែលមានតែឈ្មោះនោះ ។ ក្រសួងពាណិជ្ជកម្ម បានកត់សម្គាល់ផងដែរថាទីភ្នាក់ងារបារាំងសំរាប់ការអភិវឌ្ឍន៍ AFD កំពុងបង្កើតសេវាសង្គមកិច្ចជិតៗរោងចក្រ ដើម្បីឱ្យកម្មការិនី អាចថែទាំកូនៗរបស់ពួកគេបាន ។ គេកំពុងតែបង្កើតមជ្ឈមណ្ឌលធ្វើម៉ូដសំលៀកបំពាក់ ដើម្បីឱ្យកាន់តែមានតម្លៃ ច្រើនឡើងថែមទៀតដល់ឧស្សាហកម្មនោះ ។លើសពីនេះទៀតរដ្ឋាភិបាលកម្ពុជាកំពុងបញ្ចុះបញ្ចូលសហរដ្ឋអាមេរិកឱ្យផ្តល់ច្រកចូលរួចពន្ធក្នុងទីផ្សារសហរដ្ឋអាមេរិកបាន និងធ្វើឱ្យកម្ពុជាអាចប្រកួតប្រជែងជាមួយ នឹងប្រទេស ចិន និង បង់ក្លាដែស ។ ខណៈដែលរោងចក្រធំៗនឹងរួមបញ្ចូលគ្នា ទាក់ទងជាមួយអ្នកទិញដូរជាក្រុមៗនោះ សំរាប់ ក្រុមហ៊ុនតូចៗដែលមានកម្មករ ៣០០-៥០០នាក់ នឹងប្រថុយគ្រោះថ្នាក់ខ្លាំងណាស់ ដូច្នេះហើយជាការសំខាន់ បើនឹងធ្វើកិច្ចការជាមួយរោងចក្រតូចតាច ឱ្យចេះចងក្រងគ្នាជាក្រុមអាចផ្តុំគ្នាជាតំណាងរួម សំរាប់ទាក់ទងជាមួយ នឹងអតិថិជនទាំងឡាយនោះបាន ។ ចុងក្រោយនេះក្រសួងពាណិជ្ជកម្មកំពុង

ទទួល ធ្វើការគូសវាសផែនទី ដែលមានសារៈសំខាន់ចាំបាច់ខាងសេដ្ឋកិច្ចនៅតាមខេត្ត ដើម្បីសំឡឹងមើលទីផ្សារនិងសម្រួលទីផ្សារឱ្យសមស្របគ្នា ទៅនឹងជំនាញ ។

## អ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានាទូលំទូលាយ

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានកត់សម្គាល់ថាជាការពិតផ្នែកកាត់ដេរធ្លាប់បានឆ្លងកាត់នូវការផ្លាស់ប្តូរ ប្រែប្រួលខ្លះៗ ហើយ ចាប់តាំងពីឆ្នាំ២០០០មកម្ល៉េះ ។ ការងារថ្មីៗមួយចំនួនក្នុងផ្នែកកាត់ដេរនោះបានឡើងខ្ពស់បំផុតក្នុងឆ្នាំ ២០០០ ហើយបាន និងកំពុងតែធ្លាក់ចុះវិញចាប់តាំងពីពេលនោះមក ដែលការនាំចេញប្រមាណ៧០% ស្ថិតនៅក្រៅប្រព័ន្ធបរិមាណ កំណត់ (quota system) រួចជាស្រេចទៅហើយ ។ ការបង្កើតការងារ បានថយចុះទៅបន្តិចម្តងៗរួចជាស្រេចទៅហើយ នេះមិនមែនជាបញ្ហាថ្មីទេ ។ ចិនទំនងជាមិនចង់ប្រកួត លើផលិតផល ដែលមានប្រាក់ចំណេញតិចតួចស្តួចស្តើងដូចជាអាវនិងខោខៅប៊យខៀវនោះទេ ដូច្នេះ ប្រសិនបើអភិបាលកិច្ច មានការកែលម្អបានប្រសើរឡើងហើយនោះ វានឹងមិនមានហេតុគួរឱ្យព្រួយបារម្ភ ច្រើនពេកទេ ។ វាជាការសំខាន់ដែរដែលធ្វើការក្រឡេកមើលទៅឯផ្នែកផ្សេងៗទៀតក្នុងនោះមានវិស័យ សេដ្ឋកិច្ចក្រៅប្រព័ន្ធដែលសិទ្ធិស្ត្រីត្រូវបានគេគោរពការពារប្រសើរតិចតួចនៅឡើយ ។

អង្គការអុកស្វាមអង់គ្លេស បានចង្អុលបង្ហាញនូវសេចក្តីត្រូវការឱ្យមាន គណៈកម្មការអ្នកពាក់ព័ន្ធចម្រុះ ដើម្បីអនុវត្តផែនការនិងត្រួតពិនិត្យផលប៉ះពាល់ សារៈសំខាន់នៃការពង្រឹងអនុវត្តន៏ច្បាប់ការងារថ្នាក់ជាតិជាពិសេសអ្នកដែលត្រូវកាត់ចេញពីកាងារ មានចំនួនលើសលប់ និងសេចក្តីត្រូវការឱ្យមានការបណ្តុះបណ្តាលឡើងវិញ ជួយរកការងារឱ្យកម្មករ ។ លើសពីនេះទៀតអង្គការអុកស្វាមបានគូសបញ្ជាក់ថាការទទួលខុសត្រូវរួមគ្នា គឺត្រូវតែមានការទទួលខុសត្រូវពិតប្រាកដមិនមែនមាននៅតែលើក្រដាសទេ និងបានកត់សម្គាល់ថា កង្វះខាតតំណាងស្ត្រីនៅក្នុងរចនាសម្ព័ន្ធសហជីព ច្រើនបំផុតមានន័យថាខ្វះខាតសម្លេងសំរាប់កម្មការិនី ។ អង្គការ អុកស្វាមជម្រុញអ្នកចូលរួម ឱ្យចាត់វិធានការរួមគ្នា បន្ទាន់ដើម្បីធានាឱ្យមានស្ថេរភាពការងារ និងការងារ សមរម្យ ។ ដៃគូអង្គការមិនមែនរដ្ឋាភិបាលសំរាប់អភិវឌ្ឍន៏នៅកម្ពុជា (PADEK) កំពុងតែសាកល្បង គំនិតផ្តួចផ្តើម ជាគន្លឹះដែលផ្តោតលើកម្មករកាត់ដេរ ។ ក្រុមកម្មករដែលចង់ចាកចេញ ពីការងាររោងចក្រកាត់ ដេរបានផ្តួចផ្តើមធ្វើសំណើមកអង្គការប៉ាដិក និងគម្រោងសាកល្បងនោះធ្វើការទាក់ទិននឹងកម្មករ ចំនួន ៨៨ នាក់ ។ ជាមួយក្រុមជួយខ្លួនឯងទាំងប្រាំបួន ។ សមាសធាតុគន្លឹះ៤ប្រភេទគឺ : ក្រុមជួយខ្លួនឯងដើម្បីជួយជម្រុញ លើកទឹកចិត្តឱ្យចេះសន្សំប្រាក់សហគ្រាស ដោយការបង្រៀនកម្មករអំពីរបៀបធ្វើពាណិជ្ជកម្មផ្ទាល់ខ្លួនគេ ការបណ្តុះបណ្តាលជំនាញ ដែលជួយឱ្យពួកគេអាចបើកហាងជំនួញផ្ទាល់ខ្លួនពួកគេ ឧទាហរណ៏ដូចជាជំនាញ ខាងការធ្វើសំលៀកបំពាក់ និងកែសម្ផស្ស និងឱ្យចេះដឹងអំពីរបៀបប្រើប្រាស់ឥណទានខ្នាតតូច ។ បញ្ហាសំខាន់ដែលរកឃើញមកដល់សព្វថ្ងៃនេះ គឺការវិនិយោគទុនរយៈពេលវែងដែលតម្រូវឱ្យស្ត្រីអាច អភិវឌ្ឍជំនាញដែលពួកគេត្រូវការ ខណៈដែលគ្មានប្រាក់ចំណូលទ្រទ្រង់ពួកគេនៅពេលដែលពួកគេកំពុងតែហ្វឹកហ្វឺនជំនាញ ។ ជាការត្រឹមត្រូវដែលស្ត្រីទាំងឡាយ ដែលពួកគេមានការព្រួយបារម្ភ អំពីឧស្សាហកម្មកាត់ដេរទៅអនាគត ។ (ទោះជាយ៉ាងណា) ពួកនាងអាច មានសមត្ថភាពស៊ូទ្រាំច្រើន អនាគតភ្លឺស្វាង និងមានសក្តានុពលអាចហុចផល

ផ្លែផ្កាបាន ។ (ដោយសារ) មានឱកាសល្អមួយ ដែលសង្ឃឹមទុកចិត្តលើពួកស្ត្រីទាំងនេះ សំរាប់ការធ្វើវិនិយោគរកស៊ីជាមួយ គឺថាកម្ពុជា មានស្ត្រីបែបនេះច្រើន ការឧបត្ថម្ភនិងការបណ្តុះបណ្តាលហ្វឹកហ្វឺនពួកគេឡើងវិញ មានផលល្អច្រើន ជាជាងទុកឱ្យពួកគេគ្មានការងារធ្វើ និងមានគ្រោះថ្នាក់ ។ គំនិតផ្តួចផ្តើមដ៏សំខាន់ពីរគឺ : ការសិក្សាជំនាញដែលត្រូវការដោយទីផ្សារក្នុងពេលឥឡូវនេះ និងបង្កើតមូលនិធិមួយសំរាប់ហ្វឹកហ្វឺនឡើងវិញ និងការងារ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា អតិថិជនអ្នកជាវ និយោជកនិងម្ចាស់ជំនួយ ។

អង្គការពលកម្មអន្តរជាតិ បានកត់សម្គាល់ថាថ្លៃចំណាយបង់ទៅលើអំពើពុករលួយមានប្រមាណពី ៦-១៥ % នៃប្រាក់ចំណូលសរុបទាំងមូល ខណៈដែលប្រាក់ខែមានចំនួនតែ ១៥% នៃថ្លៃដើមរោងចក្រ ។ ម្ចាស់រោងចក្រភាគច្រើនរីករាយផ្តល់ប្រាក់ដែលគេបង់ចំណាយលើអំពើពុករលួយ ឱ្យទៅកម្មករកាត់ដេរវិញ ។ ទោះបីជាមានអង្គការពលកម្មអន្តរជាតិដែលកំពុងបន្តការត្រួតពិនិត្យក្នុងរោងចក្រទាំងឡាយនោះក្តី ក៏នេះមិនមែន មានន័យថា ចន្លោះប្រហោងមិនកើតឡើងនោះទេ ។ លើសពីនេះទៀត ស្ត្រីទាំងឡាយតាមពិតទៅ នៅខាងក្រៅរោងចក្រងាយរងគ្រោះខ្លាំងណាស់ ជាឧទាហរណ៍ដូចជាពួកគេជួបគ្រោះថ្នាក់នឹងការឆក់ប្លន់យកប្រាក់ខែរបស់គេ ហើយក៏មានវប្បធម៌ភ័យខ្លាចដែលស្ត្រីទាំងឡាយតែងតែមាន ។ លើសពីនេះទៀត បញ្ហាអនុវត្តច្បាប់ការងារ ការការពារសមាជិកសហជីព និងសិទ្ធិកម្មករ ចាំបាច់ត្រូវតែធ្វើឱ្យឃើញជាក់ស្តែងក្នុងស្ថានភាពធំទូ លាយជាងនេះឡើងដែលជាសេចក្តីត្រូវការចាំបាច់ដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា ។ នេះអាចជាមធ្យោបាយមានប្រយោជន៍មួយ ដើម្បីពិនិត្យពិច័យមើលនិងដាក់ចេញនូវបញ្ហាផ្នែកកាត់ដេរ ។ អង្គការពលកម្មអន្តរជាតិកំពុងធ្វើការជាមួយអតិថិជនទិញទំនិញសំខាន់ៗបំផុត និងបានកត់សំគាល់ថាអ្នកទិញ ទាំងឡាយបានចង្អុលបង្ហាញថាពួកគេនឹងនៅតែបន្តទិញនៅកម្ពុជា ជាក់ស្តែងដោយសារតែលក្ខខណ្ឌការងារល្អ ។ ព្រោះហេតុនេះហើយ ការការពារកម្មករមានសារៈសំខាន់ជាអាយុជីវិត ដើម្បីធានានូវឧស្សាហកម្មកាត់ដេរដែលផលិតបានច្រើននិងអាចមានអាយុកាលឋិតថេរយូរអង្វែង ។

## ផ្នែកសំលៀកបំពាក់

កម្មករសំលៀកបំពាក់ បានរៀបរាប់ប្រាប់អំពីបទពិសោធន៍របស់ពួកគេយ៉ាងពិស្តារ ។ ថ្លៃចំណាយខ្ពស់សំរាប់ការចិញ្ចឹមជីវិត បានបង្ខំចិត្តឱ្យស្ត្រីៗ ស្វែងរកការងារធ្វើដើម្បីជួយទ្រទ្រង់ក្រុមគ្រួសារ ។ ថ្លៃចំណាយនេះរួមមាន ថ្លៃចំណាយដែលទាក់ទិននឹង សេវាឯកជនផ្សេងៗ ដូចជា សេវាសុខភាពនិងការអប់រំជាដើម ។ ចំណាយថ្លៃធ្វើកសិកម្មមានការកើនឡើងផងដែរ និងគ្រួសារមួយចំនួនមិនមានលទ្ធភាពដាក់បញ្ចូលសម្ភារៈ វត្ថុធាតុដើម (Input) ។ បំណុលមានកំរិតខ្ពស់នាំឱ្យមានសម្ពាធលើ ក្រុមគ្រួសារតាមជនបទចុងកាត់ មាត់ញកផងដែរ ។ ព្រោះហេតុទាំងនេះហើយ ដែលយុវតីទាំងឡាយបញ្ឈប់ការរៀនសូត្ររបស់ពួកនាងនិង ចាកចេញពីក្រុមគ្រួសារ និង ផ្ទះសំបែងស្វែងរកការងារធ្វើតាមរោងចក្រកាត់ដេរក្នុងទីក្រុងនានា ។ កម្មករទាំងឡាយធ្លាប់ទទួលរងការគាបសង្កត់បង្ខំឱ្យធ្វើការលើសម៉ោងពេល ដើម្បីបង្កើនប្រាក់ចំណូលនិងដើម្បីចៀសផុតពីការបាត់បង់ការងារ ។ ពួកគេបានរាយការណ៍ថា ច្បាប់ការងារមិនត្រូវបានគេអនុវត្តទេ ហើយនិងតាម

រោងចក្រមួយចំនួន គ្មានសហជីពទេ ។ ពួកគេភ័យព្រួយចំពោះគ្រោះថ្នាក់ផ្សេងៗ នៅខាងក្រៅរោងចក្រកាត់ដេរដូចជាចោរកម្មការចាប់ជំរិត និងការរំលោភសេពសន្ថវៈ ។ បច្ចុប្បន្ននេះ កម្មករភ័យព្រួយយ៉ាងខ្លាំងអំពីការបាត់បង់ការងាររបស់ពួកគេ និងអនាគតឧស្សាហកម្មកាត់ដេរមិនទៀងទាត់ ។ ការបារម្ភចំបងរបស់ពួកគេគឺគ្រួសាររបស់គេនៅឯផ្ទះដែលពឹងផ្អែកលើប្រាក់ចំណូលរបស់ពួកគេដែលរកបាន ។គេបារម្ភផងដែរអំពីប្រាក់កម្រៃដែលពួកគេមានសិទ្ធិទទួលបានប្រសិនបើពួកគេ ត្រូវបានកាត់ចេញពីការងារ ។ នៅក្នុងបរិយាកាសក្រោយការ ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកថ្មីៗនេះ គេរំពឹងថា នឹងបានឃើញមាននូវការបន្ធូរបន្ថយការងារ មិនពេញម៉ោង និងកិច្ចសន្យាថ្មីៗ ដែលមានប្រាក់ខែថោកជាង ។

ផលិតករកាត់ដេរសង្កត់ធ្ងន់លើសេចក្តីត្រូវការថាឱ្យមានការកែទម្រង់ដើម្បីដាក់ចេញនូវរបាំងចំណាយថ្លៃដើមក្នុងការធ្វើពាណិជ្ជកម្មនៅកម្ពុជា ។ មានវិធីតែមួយគត់ដើម្បីដោះស្រាយថ្លៃថយចុះ គឺត្រូវតែធានាឱ្យ មានផលិតភាពកាន់តែខ្ពស់ឡើង នេះគឺជាការទទួលខុសត្រូវទាំងកម្មករនិងអ្នកគ្រប់គ្រងរោងចក្រដែលត្រូវតែធ្វើការរួមជាមួយគ្នា ដើម្បីដោះស្រាយជម្លោះ និងធ្វើឱ្យប្រាកដថារោងចក្រកាត់ដេរអាចមានលទ្ធភាពប្រកួតប្រជែងខ្លាំងជាងមុន ។ សមាគមន៍ផលិតករកាត់ដេរកម្ពុជាបានកត់សម្គាល់ផងដែរថាមានបញ្ជាទិញច្រើនបរិបូរណ៍សម្រាប់ខែមករានិងខែកុម្ភៈ បន្តែដល់ខែមីនាមិនដឹងប្រាកដជាយ៉ាងណាទេ ។

# សេចក្តីសង្ខេប

*ជោគជ័យនៃគោលនយោបាយពាណិជ្ជកម្ម ត្រូវតែធ្វើការវាយតម្លៃ....... តាមបែបផែនមួយ ថាតើគោលនយោបាយទាំងនេះមានផលៈ ចង់ឱ្យសង្គមទទួលបានលទ្ធផល ដូចជាសមធម៌ ការគាំពារផ្នែកសង្គមកិច្ច ការរួចចាកពីភាពក្រីក្រ ការអភិវឌ្ឍន៍សមត្ថភាពមនុស្ស (Human Capability) ការការពារសិទ្ធិមនុស្ស អភិបាលកិច្ចប្រកបដោយប្រជាធិបតេយ្យ និងនិរន្តរភាពបរិស្ថាន (ខាតាហ្គេ ២០០១ : ៣)។*

ក្នុងឆ្នាំ២០០៥ កូតាដែលបានគាំពារដល់ផ្នែកកាត់ដេរនឹងបញ្ចប់ ហើយកម្ពុជានឹងក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ទោះបីជាការព្យាករណ៍អំពីអនាគត នៃឧស្សាហកម្មកាត់ដេរខុស១ពីគ្នា យ៉ាងណាក្តី ក៏រោងចក្រមួយចំនួនទំនងជាត្រូវបិទទ្វារ រោងចក្រមួយចំនួនទៀតត្រូវបញ្ចូលគ្នា ឬរើទៅតាំងទីនៅកន្លែងផ្សេង១វិញ ។ អ្នកជំនាញការមួយចំនួនបានព្យាករណ៍ថា នឹងមានចំនួនកម្មករដ៏ច្រើន រហូតទៅដល់ ៥០ ០០០ នាក់ ដែលត្រូវបញ្ឈប់ ពីការងារដោយសារផលប៉ះពាល់នេះ។

ផ្នែកកាត់ដេរ គឺជាប្រភពមួយដ៏សំខាន់ដែលផ្តល់ការងារមានប្រាក់ឈ្នួលដល់ស្ត្រីកម្ពុជា មានចំនួនប្រមាណជា ១៨០.០០០ នាក់ ហើយដែលម្នាក់១ ត្រូវទទួលបន្ទុកចិញ្ចឹម គ្រួសារដែលមានមនុស្សពី ៤ ទៅ៩ នាក់ ។ ចំនួនមនុស្ស ប្រមាណមួយលាននាក់កន្លះ(១.៥លាន) ត្រូវបានគាំទ្រដោយផ្នែកកាត់ដេរក្នុងនោះ រួមមានការងារក្រៅប្រព័ន្ធ (informal sector jobs) ដែលជួយទ្រទ្រង់ឧស្សាហកម្ម។ ភាគច្រើននៃកម្មការិនីកាត់ដេរ គឺជាស្ត្រីវ័យក្មេង ដែលមកពីតំបន់ជនបទ ។ គ្រោះថ្នាក់ចំពោះកម្មការិនីដែលបណ្តាលមកពីការផ្លាស់ប្តូរនៅក្នុងឧស្សាហកម្មគឺខុសពីការប្រឈមមុខដែលនិយោជិតបុរសជួបប្រទះដែលក្នុងនោះរួមមានការចូលទៅបំរើផ្លូវភេទ ចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេស នឹងការខ្វះខាត ការទទួលបានការងារជំនាញនៅពេលដែលវិស័យនេះ ត្រូវរៀបចំរចនាសម្ព័ន្ធឡើងវិញ ។

រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់មូលនិធិ បានដាក់ចេញនូវអន្តរាគមន៍ទ្រង់ទ្រាយធំជាច្រើន ដើម្បីរៀបចំពង្រឹងការប្រកួតប្រជែង នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ដែលក្នុងនោះមានការកាត់បន្ថយតម្លៃចំណាយ និងការបង្កើនផលិតភាព ។ ទោះជាយ៉ាងណាក៏ដោយ ទំហំនិងជំហាននៃអន្តរាគមន៍នេះ ពុំទាន់លេចចេញ ជារូបរាងជាក់លាក់នៅឡើយទេ ។ លើសពីនេះទៅទៀត គំនិតផ្តួចផ្តើមនៃម្ចាស់មូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានរៀចំដើម្បីជួយឱ្យកម្មករ ដែលទទួលរងនូវឥទ្ធិពល ពីការផ្លាស់ប្តូរបរិស្ថានពាណិជ្ជកម្មនោះ មានកម្មវិធីសាកល្បងដែលរៀបចំឡើងដើម្បីជួយគាំទ្រកម្មការិនី ឱ្យឆ្លងផុតពីរយៈពេលអន្តរកាល ។

យូនីហ្វាម (UNIFEM) តាមរយៈ កម្មវិធីយេនឌ័រ និងគោលដៅសហស្សវត្សរ៍ (MDG) បានស្នើសុំឱ្យរៀបចំឯកសារមួយ ដើម្បីពិនិត្យទៅលើផលប៉ះពាល់ជាក់លាក់ទៅលើពាណិជ្ជសេរីភាវូបនីយកម្ម នៅក្នុងផ្នែកកាត់ដេរហើយ និងធ្វើការពិនិត្យឡើងវិញ នូវអន្តរាគមន៍បច្ចុប្បន្ន ដើម្បីកំណត់នូវអន្តរាគមន៍ផ្សេង១ ទៀតដែលអាចជួយគាំទ្រ កម្មការិនី និងដើម្បីបង្កើតសន្ទស្សន៍បន្ថែមទៀត ស្របទៅតាមគោលដៅសហស្សវត្សរ៍ ទី១ និង ទី៦ ( MDGs 1 and 6 )។

ការិយាល័យស្រាវជ្រាវ និងពិគ្រោះយោបល់ រួមជាមួយភ្នាក់ងារសំខាន់ផ្សេងៗទៀត បានបញ្ជាក់ថា បញ្ហាដែលអាក្រក់នឹងអាចកើតឡើងទៅលើកម្មការិនី រហូតដល់ទៅចំនួន ៥០,០០០ នាក់ និង ២០,០០០ គ្រួសារអាចមានឥទ្ធិពលបណ្តាលមកពីការផ្លាស់ប្តូរ នៅក្នុងផ្នែកកាត់ដេរ ។ ការគាំពារឱ្យមានប្រាក់ចំណូល និងការអភិវឌ្ឍន៍ជំនាញ គឺជាតម្រូវការចាំបាច់ក្នុងការជួយកម្មការិនី ឱ្យឆ្លងផុតពីរយៈពេលអន្តរកាល ហើយនិងស្ត្រីទាំងឡាយណាដែលនឹងត្រូវបានគេបញ្ឈប់ពីការងារ ដើម្បីទទួលបានការងារធ្វើនៅក្នុងវិស័យផ្សេងៗទៀត ឬទទួលបាននូវការងារដែលត្រូវការជំនាញច្រើន ក្នុងឧស្សាហកម្មកាត់ដេរ ប្រសិនបើរោងចក្រ ទាំងនេះផ្តល់ឱកាសឱ្យពួកគេ ។ មានការចាប់អារម្មណ៍យ៉ាងខ្លាំង និងមានសកម្មភាព ដែលគួរឱ្យពិចារណា នៅក្នុងរង្វង់អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់មូលនិធិ និងរាជរដ្ឋាភិបាល អំពីអនាគត របស់ឧស្សាហកម្ម ហើយនិងការជួយគាំទ្រកម្មការិនី ។ គំនិតផ្តួចផ្តើមដោយផ្តោតទៅលើក្រុមគោលដៅ ដែលក្នុងនោះ រួមមានគម្រោងរាជរដ្ឋាភិបាល និងគម្រោងម្ចាស់មូលនិធិ ដែលបានរៀបចំដើម្បីផ្តល់វគ្គបណ្តុះបណ្តាល ការបង្កើតឱកាសសំរាប់ជម្រើសការងារ ការគាំទ្រឱ្យមានប្រាក់ចំណូល និងជួយស្ត្រីឱ្យទទួលបានឥណទានខ្នាតតូច ។

ទោះបីជាយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមបច្ចុប្បន្ន ដែលមានផែនការរួចហើយ សំដៅជួយក្រុមកម្មការិនីកាត់ដេរ គឺ ស្ថិតនៅក្នុងដំណាក់កាលបឋម និងមានលក្ខណៈទ្រង់ទ្រាយតូច ។ មានតម្លាតយ៉ាងខ្លាំង ដែល ក្នុងនោះមានគំនិតផ្តួចផ្តើមឱ្យ មានឧស្សាហកម្មច្រើន ដើម្បីទទួលបាននូវប្រាក់ចំណូល និងសេវាសុវត្ថិភាព សង្គម ដើម្បីឈានទៅទទួលបាននូវវគ្គបណ្តុះបណ្តាល និងការទទួលស្គាល់នូវជំនាញបច្ចុប្បន្នរបស់កម្មករ និងឱកាសទទួលបាន នូវជម្រើសការងារ ។ ការវិនិយោគ របស់ជាតិដែលកើនឡើង ក្នុងការអភិវឌ្ឍន៍ សហគ្រាសធុនតូច និងមធ្យម សំរាប់ស្ត្រីនៅក្នុងការអប់រំវិជ្ជាជីវៈ និងសំរាប់ស្ត្រីដែលមានអាយុអាចធ្វើការ ក៏ជា តម្រូវការចាំបាច់ផងដែរ ។

លើសពីនេះទៀត ការស្រាវជ្រាវ តម្រូវឱ្យមានការបង្កើតនូវទិន្នន័យជាក់លាក់អំពីទំហំ និងសមាសភាព វិស័យក្រៅប្រពន្ធ័ ដែលជួយទ្រទ្រង់ឧស្សាហកម្មកាត់ដេរ ។ ការជួយអន្តរគមន៍ជាសក្តានុពល ផ្សេងៗទៀត ដែលរួមមានការផ្តួចផ្តើមរួមគ្នា រវាងក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតទំនាក់ទំនងរវាង មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី (WDCs) ជាមួយនឹងមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត និងលើកកំពស់ការអប់រំវិជ្ជាជីវៈ សំរាប់ ស្ត្រីដែលមានអាយុអាចធ្វើការបាន ( ឧទាហរណ៏ការបង្កើតកម្មវិធីសាកល្បងការសិក្សាមុនទទួលស្គាល់(Recognized prior learning) សំរាប់កម្មការិនីកាត់ដេរ ។ ការជួយអន្តរាគមន៍ជាសក្តានុពល ក៏មានរួមផងដែរ នូវការរៀបចំយុទ្ធនាការទីផ្សារសង្គម ដើម្បីលើកកំពស់ ការចូលរួមចំណែករបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងដើម្បីឆ្លើយតបទៅនឹងគំនិតដែលថា ការងារ ផ្នែកកាត់ដេរនៅមិនទាន់ល្អ និងដើម្បីផ្តល់វគ្គបណ្តុះបណ្តាលជំនាញថ្មីៗ ដើម្បីឱ្យកម្មការិនី អាចទៅបំរើការងារ ក្នុងវិស័យទេសចរណ៏ ។

ឥទ្ធិពលនៃការផ្លាស់ប្តូរ ចំពោះផ្នែកកាត់ដេរ និងរបៀបគ្រប់គ្រង បញ្ហានេះនិងធ្វើឱ្យឥទ្ធិពលជាអវិជ្ជមាននេះថយចុះ ហើយក្លាយទៅជាករណីសាកល្បងមួយដ៏សំខាន់ សំរាប់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ និងសំរាប់សមធមិយេនឌ័រ ។ សន្ទស្សន៍ជាក់លាក់ជាច្រើនកំពុងត្រូវការ ដើម្បីតាមដាន និងវាយតម្លៃទៅលើឥទ្ធិពល នៃការផ្លាស់ប្តូរនេះ និងអន្តរាគមន៍

ដែលបានធ្វើផែនការរួចហើយ ដើម្បីជួយគាំទ្រដល់កម្មការិនីកាត់ដេរ ដោយផ្តោតទៅលើការអភិវឌ្ឍន៍ និងយេនឌ័រ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។សន្ទស្សន៍ជាគន្លឹះ សំខាន់សំរាប់តាមដាន និងរៀបចំផែនការលម្អិត (MAP) ចំពោះឥទ្ធិពលទាំងនេះ ដោយរួមបញ្ចូលទាំងក៏រិត នៃការចាកចេញនៃកម្មករកាត់ដេរ កំរិតនៃភាពក្រីក្ររបស់កម្មករក្នុងវិស័យកាត់ដេរ និងសមាជិកគ្រួសាររបស់ពួកគេនៅឯផ្ទះ ។ សន្ទស្សន៍នេះ វាស់នូវភាពក្រីក្រនៃស្ត្រីដែលមាន អាយុពី ១៥-២៤ ឆ្នាំ និងសមាជិកគ្រួសាររបស់ពួកគេស្ថានភាពក្នុងប្រព័ន្ធនិងប្រព័ន្ធក្រៅការងារ ចំនួនស្ត្រីលម្អិត ដែលធ្វើការសំរាប់ខ្លួនឯង (Self-employment) អត្រានៃការចូលរួមរបស់ស្ត្រីនៅក្នុងការអប់រំជំនាញផ្លូវការទាំងមិនផ្លូវការ និងអត្រាចំណាកស្រុកទាំងក្នុង និងក្រៅប្រទេសនៃស្ត្រីក្នុងការស្វែងរកការងារ ។

ព័ត៌មានលម្អិត ផ្តល់យោបល់ថែមទៀត ដែលទាក់ទងទៅនឹងការធ្វើអន្តរាគមន៍ និងសន្ទស្សន៍ដែលអាចវាស់ វែងបានមាននៅក្នុងតួសេចក្តី នៃរបាយការណ៍នេះ។

## ១ សេចក្តីផ្តើម

*គោលនយោបាយពាណិជ្ជកម្មមានវិបាកខុសៗគ្នាចំពោះស្ត្រី និងបុរស ពីព្រោះថា ស្ថានភាពសេដ្ឋកិច្ច និងសង្គម ខុសគ្នា ( អង្គការអ៊ុកស្វាម អន្តរជាតិ ២០០១:១៩ ) ។*

*ការវិភាគទៅលើយេនឌ័រ គឺមានសារៈសំខាន់ ចំពោះការរៀបចំឱ្យបានល្អនូវគោលនយោបាយពាណិជ្ជកម្មដែលធ្វើឱ្យមានភាពប្រសើរឡើង ដើម្បីចៀសវាងនូវការរារាំងដល់ការអភិវឌ្ឍន៍មនុស្ស និង សមធម៌យេនឌ័រ ( ឃាតាហ្គេ ២០០១:៣ ) ។*

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ប្រព័ន្ធកូតាកិច្ចព្រមព្រៀងពហុវាយនភណ្ឌ (Multi-Fibre Agreement – MFA) ដែលបានជួយគាំពារវិស័យផ្នែកកាត់ដេរនៅកម្ពុជាពីការប្រកួតប្រជែងទីផ្សារអន្តរជាតិ ដែលបាននិងជួយធ្វើឱ្យមានការលូតលាស់យ៉ាងខ្លាំង ក្នុងសេដ្ឋកិច្ចកម្ពុជានោះ នឹងត្រូវបញ្ចប់ ។ នៅដំណាច់ឆ្នាំ២០០៤ កម្ពុជានឹងចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ការបើកចំហឱ្យឧស្សាហកម្មដែលទទួលបានជោគជ័យបំផុតរបស់កម្ពុជា ដើម្បីប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ហើយដែលឧស្សាហកម្មទាំងនោះទទួលខុសត្រូវក្នុងការបង្កើត ការនាំចេញរហូតដល់ ៩៣% នៃការនាំចេញសរុប ព្រមទាំងទទួលខុសត្រូវបង្កើតការងារច្រើនឱ្យបានជាង ២០០០០០ កន្លែង នឹងមានការទទួលរងនូវឥទ្ធិពលមួយយ៉ាងធ្ងន់ធ្ងរទៅលើការលូតលាស់របស់ជាតិ ដែលជាលទ្ធផល គឺប៉ះពាល់ទៅលើការងាររបស់ស្ត្រី ក៏រិតនៃភាពក្រីក្រ និងស្ថិរភាពសង្គមក្នុងប្រទេសកម្ពុជា ។

ក្រៅពីវិស័យកសិកម្ម ផ្នែកកាត់ដេរ គឺជាកន្លែងផ្តល់ការងារដ៏សំខាន់សំរាប់ ស្ត្រីកម្ពុជា និងជាប្រភពសំខាន់ នៃការងារដែលទទួលបានប្រាក់ឈ្នួល ទោះបីជា នៅក្នុងទីផ្សារពលកម្មតូចក្តី ធំក្តី ។ ស្ត្រីជំទង់ៗប្រមាណជា ១៨០,០០០នាក់ ធ្វើការក្នុងរោងចក្រកាត់ដេរ នៅទីក្រុងភ្នំពេញ និងជុំវិញក្រុងភ្នំពេញ ។ ភាគច្រើននៃស្ត្រីដែលមានអាយុពី១៨ ដល់២៤ឆ្នាំ ជាអ្នកដែលធ្វើចំណាកស្រុកពីតំបន់ជនបទ ដើម្បីគេចចេញពីភាពក្រីក្រ ហើយរកប្រាក់កម្រៃសំរាប់ចិញ្ចឹមជីវិត ។ពួកគេបាន ផ្ញើប្រាក់មួយចំនួនធំនៃប្រាក់ចំណូល របស់ពួកគេដែលគេអាចរកបាន ទៅផ្គត់ផ្គង់គ្រួសាររបស់គេ ដែលមានសមាជិកក្នុងគ្រួសារ ពី ៤ ទៅ ៩ នាក់ ។ មនុស្សប្រមាណជា មួយលានកន្លះ ( ១,៥ លាន) ពឹងផ្អែកទៅលើផ្នែកកាត់ដេរ សំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និងយុទ្ធសាស្ត្រពាណិជ្ជកម្មទ្រទ្រង់អ្នកក្រ ក្នុងគោលបំណងផ្តល់ប្រយោជន៍ ដល់ការធ្វើពាណិជ្ជកម្ម និងលើកកំពស់ប្រសិទ្ធភាព ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ។ រាជរដ្ឋាភិបាលមានទស្សនៈថាការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ជាគន្លឹះមួយដ៏សំខាន់ក្នុងការលើកកំពស់ការលូតលាស់ និងការលុបបំបាត់ភាពក្រីក្រ នៅកម្ពុជា ។

មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការលុបបំបាត់ និងការកាត់បន្ថយភាពក្រីក្រ ដែលផ្តោតទៅលើស្ត្រី គឺមានប្រសិទ្ធភាពច្រើនជាងការធ្វើការជាមួយបុរស ។ ក្នុងចំណោមអ្នកក្រ ស្ត្រីមានចំនួនច្រើនជាងគេ ។ ការធ្វើឱ្យប្រសើរនូវសុខភាពរបស់ស្ត្រី ការអប់រំ និងស្ថានភាពសេដ្ឋកិច្ច មិនត្រឹមតែអាចធ្វើឱ្យមានភាពផ្លាស់ប្តូរ សំរាប់តែស្ត្រីខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែ គឺសំរាប់កូនចៅរបស់ពួកគេទៀតផង (បើរេសហ្វត អេ អល ០០៤:៩៧) ។ ទោះបីជាយ៉ាងណាក៏ដោយ

គោលនយោបាយពាណិជ្ជកម្ម ជួនកាលមិនត្រូវចេះតែបង្កើតឡើងហើយ មិនស្របទៅនឹងតម្រូវការចាំបាច់ឬផលប្រយោជន៍ជាក់លាក់របស់ស្ត្រី ដូចដែលគេបានគិតនោះទេ គឺត្រូវវិភាគលើប្រសិទ្ធភាពនៃការជះឥទ្ធិពល ពីកម្មវិធីគោលនយោបាយនោះចំពោះស្ត្រីផងដែរ ដូចជា ការទទួលរងនូវផលប៉ះពាល់ដ៏មានសក្តានុពលទៅលើជីវភាពប្រចាំថ្ងៃរបស់ស្ត្រី និងលក្ខខណ្ឌការងារ ឬរបៀបដែលស្ត្រីជ្រើសរើស និងជម្រើសរបស់ស្ត្រីកើនឡើង ឬមានភាពចង្អៀតដោយសារ ឥទ្ធិពលនៃការសំរេចចិត្តនូវគោលនយោបាយខាងលើនោះ ។

ការវិភាគយេនឌ័រ អំពីឥទ្ធិពលក្នុងការផ្លាស់ប្តូរ នៅក្នុងគោលនយោបាយពាណិជ្ជកម្ម តម្រូវឱ្យមានប្រសិទ្ធភាពលើការអនុវត្តការងារ និងទ្រទ្រង់ការអនុវត្តន៍ ដែលទទួលបានជោគជ័យ សំរាប់យុទ្ធសាស្ត្រជាតិ កាត់បន្ថយភាពក្រីក្រ និងគោលដៅសហស្សវត្សរ៍របស់ប្រទេសកម្ពុជា (MDGs) ។ តម្រូវការសំរាប់ការវិភាគបែបនេះ មានបញ្ជាក់ក្នុងការស្ទាបស្ទង់យេនឌ័រ ដែលធ្វើឡើងដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន នៅខែ មិថុនា ឆ្នាំ ២០០៤ ( យូនីហ្វាម អេ អល ២០០២ អេ- UNFEM et al 2004a ) ។

ទោះបីជាទស្សនៈអំពីទំហំ និងលក្ខណៈចរិតរបស់ផលប៉ះពាល់ នៃការបញ្ចប់កិច្ចព្រមព្រៀង ពហុវាយនភណ្ឌ (MFA) និងការចូលជាសមាជិកពាណិជ្ជកម្មពិភពលោក មិនដូចគ្នាយ៉ាងណាក៏ដោយ ក៏នៅតែមានការយល់ស្របជារួមថា វានឹងមានការផ្លាស់ប្តូរមួយដ៏ធំ និងមានភាពច្របូកច្របល់ ដែលពុំអាចទប់ស្កាត់បាន នៅក្នុងផ្នែកកាត់ដេរនៅកម្ពុជា ។ ទំនងជាមានរោងចក្រមួយចំនួនដែលត្រូវបិទទ្វារឧស្សាហកម្មមួយចំនួននឹងត្រូវបញ្ចូលគ្នាទៅតាមចំនួនតិចឬច្រើននៃរោងចក្រ និងក្រុមហ៊ុនមួយចំនួននឹងត្រូវរើទៅតាំងទីនៅកន្លែងដទៃវិញ ។ តាមការគូសបញ្ជាក់ជា វិជ្ជមាន គឺថាមានរោងចក្រមួយចំនួនត្រូវពង្រីក ក្រុមហ៊ុនថ្មីៗ មួយចំនួនកំពុងបើកដំណើរការរកស៊ី ហើយវិនិយោគទុន អន្តរជាតិថ្មីៗ ក្នុងវិស័យវាយនភណ្ឌ (តម្បាញ) កំពុងបើកទូលាយ (សាលិងចេរ ២០០៤: ៦) ។ ទោះជាយ៉ាងណាក៏ដោយ មានការយល់ស្រប ជាទូទៅថា បើសិនជាមិនមានការចាត់វិធានការដោយរាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយការចំណាយ លើវិស័យឯកជនព្រម ទាំងដោយរោងចក្រកាត់ដេរខ្លួនឯងដើម្បីកែលម្អការអនុវត្តគ្រប់គ្រង និងផលិតភាពទេនោះវាទំនងជា នឹងមានផលប៉ះពាល់ មិនល្អទៅលើវិស័យនេះ ហើយនិងកាន់តែធំជាងនេះទៅទៀតនោះគឺសេដ្ឋកិច្ចកម្ពុជាតែម្តងយ៉ាងហោច ណាស់ក៏ក្នុងរយៈពេលខ្លីដែរ ។

ការផ្លាស់ប្តូរទាំងនេះ នឹងមានផលប៉ះពាល់មិនដូចគ្នាទេ ទៅលើស្ត្រីនិងបុរស ជាលទ្ធផលធ្វើឱ្យកំរិតនៃការអប់រំ ស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពសង្គមរបស់ពួកគេ មានភាពខុសៗគ្នា ។ រាល់ការពិភាក្សារបស់រដ្ឋាភិបាល និងម្ចាស់មូលនិធិអំពីកំណែទម្រង់ពាណិជ្ជកម្ម តែងតែពុំបានពិចារណាទៅលើផលប៉ះពាល់ជាក់លាក់លើស្ត្រី និងថាតើផលប៉ះពាល់ដល់ស្ត្រីនោះអាចខុសគ្នាផ្សេងពីលទ្ធផលចំពោះបុរសយ៉ាងដូចម្តេច ។ គ្រោះថ្នាក់ ដែលអាចកើតមានឡើង ក្នុងនោះមានការឈានទៅរកមុខរបររកស៊ីផ្លូវភេទ ដើម្បីរក្សាកំរិតនៃប្រាក់ចំណូលរបស់ពួកគេ និងធ្វើចំណាកស្រុកមកធ្វើការនៅក្នុងរោងចក្រក្នុងទីក្រុង និងឧស្សាហកម្ម ដទៃទៀតនៅក្រៅប្រទេស និងការមិនអាចទទួលបាន នូវឱកាសបង្កើនជំនាញកម្មករសំរាប់ការងារ នៅពេលវិស័យនេះ ធ្វើការកែទម្រង់រចនាសម្ព័ន្ធ ។

នៅសល់រយៈពេលតែ ៤ខែប៉ុណ្ណោះ ដែលប្រព័ន្ធកូតាកិច្ចព្រមព្រៀងពហុវាយនភណ្ឌ (MFA) ត្រូវបានបញ្ចប់និងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកឈានមកដល់ ។ កម្ពុជាពុំមានពេលវេលាច្រើន ដើម្បីរៀបចំសេវសុវត្ថិភាព និងអនុវត្តយុទ្ធសាស្ត្រដែលជួយដល់កម្មការិនីកាត់ដេរឱ្យអាចត្រៀមខ្លួនទៅក្នុងរយៈពេលអន្តរកាល សំរាប់ការចូលជាសមាជិកពេញសិទ្ធិរបស់អង្គការពាណិជ្ជកម្មពិភពលោក និងការប្រកួតជាមួយប្រទេសដទៃទៀត ។ ឥឡូវនេះ សកម្មភាពទាំងឡាយមានការទាមទារ ឱ្យអនុវត្តបានជាការប្រញាប់ ដើម្បីធានាថា កម្មការិនីរោងចក្រកាត់ដេរ និងសមាជិកគ្រួសារប្រមាណជាមួយលាននាក់ដែលទីពឹងលើប្រាក់ចំណូលរបស់ពួកគេមិនធ្លាក់ទៅក្នុងភាពក្រីក្រ ។

រាជរដ្ឋាភិបាល និងភ្នាក់ងារផ្តល់ជំនួយបានធ្វើការវិភាគយ៉ាងលម្អិត ដើម្បីស្ទាបស្ទង់ផលប៉ះពាល់ ដែលអាចកើតមានឡើង ដោយសារការចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងការបញ្ចប់កូតា ហើយ រាជរដ្ឋាភិបាល និងភ្នាក់ងារផ្តល់ជំនួយបានកំណត់នូវវិធានការ ដើម្បីគាំទ្រដល់ឧស្សាហកម្មក្នុងការប្រកួតប្រជែង និងផ្តល់ភាពងាយស្រួលដល់វិនិយោគទុនក្នុងប្រទេសកម្ពុជា ។ លើសពីនេះទៀត ម្ចាស់មូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាល កំពុងអនុវត្តនូវគំនិតផ្តួចផ្តើមថ្មីរបស់ខ្លួន ដើម្បីបង្កើននូវផលិតភាព បង្កើនការគោរពបទដ្ឋានការងាររបស់កម្មករ និងផ្តល់ជំនាញអភិវឌ្ឍន៍ និងការដែលអាចទទួលបាន នូវជម្រើសការងារសំរាប់កម្មការិនីរោងចក្រកាត់ដេរ ។ ដោយគម្រោងផែនការពេលវេលាប្រថុចញ៉ិច និងការពុំមានទស្សនៈយេនឌ័រ នៅក្នុងគម្រោងផ្តួចផ្តើមមួយចំនួននោះ គម្លាតនិងឱកាស ប្រហែលជាពុំទាន់បានដោះស្រាយ ទាំងស្រុងនៅឡើយទេ ។

គម្រោងយេនឌ័រ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍គាំទ្រមូលនិធិដោយយូនីហ្វាម (UNIFEM) បានធ្វើការត្រួតពិនិត្យ ទៅលើផលប៉ះពាល់ដោយការបញ្ចប់នៃប្រព័ន្ធកូតាកិច្ចព្រមព្រៀងពហុវាយនភណ្ឌ (MFA) ទៅលើស្ត្រីវ័យជំទង់៧ចំនួន ១៨,០០០ ជាមនុស្សដែលបច្ចុប្បន្ននេះ កំពុងធ្វើការនៅរោងចក្រកាត់ដេរកម្ពុជា ។ ដោយការទំនាក់ទំនងជាមួយសេដ្ឋកិច្ចក្រៅប្រព័ន្ធនិង ការធ្វើចំណាកស្រុកទៅធ្វើការក្នុង វិស័យក្រៅប្រព័ន្ធនៅក្រៅប្រទេស ត្រូវបានគេពិចារណា ឯកសារនេះបានផ្តោតជាពិសេសទៅលើស្ត្រីដែល ធ្វើការក្នុងផ្នែកសំលៀកបំពាក់ផ្លូវការ ។ ឯកសារបានដកស្រង់ទស្សនៈផ្តួចផ្តើម នៃការស្រាវជ្រាវដែលមានស្រាប់ និងកិច្ចសម្ភាសន៍ជាមួយនឹងក្រសួងដែលបានជ្រើសរើសភ្នាក់ងារម្ចាស់មូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើឡើងក្នុងខែកក្កដា-សីហា២០០៤ ( សូមមើលសេចក្តីបន្ថែម សំរាប់តារាងនៃការពិគ្រោះយោបល់ទាំងនេះ ) និង:

- ការផ្តល់ព័ត៌មានលម្អិត អំពីស្ត្រីនៅក្នុងផ្នែកកាត់ដេរ ដោយដកស្រង់ចេញពី ឯកសារស្រាវជ្រាវ ដែលមានស្រាប់ ។
- ត្រួតពិនិត្យនូវការព្យាករណ៍ទាំងឡាយអំពីផលប៉ះពាល់នូវការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនិងការបញ្ចប់នៃប្រព័ន្ធកូតា ទៅលើផ្នែកកាត់ដេរនៅកម្ពុជា ។
- ធ្វើការប៉ាន់ប្រមាណទៅលើគ្រោះថ្នាក់ជាសក្តានុពល ដល់កម្មការិនីរោងចក្រ ព្រមទាំងឱកាសដែលអាចទទួលយកបាននៅពេលដែលផ្នែកកាត់ដេរបើកចំហ និងឈានចូលទៅក្នុងរយៈពេលអន្តរកាល ។

- ត្រួតពិនិត្យ យុទ្ធសាស្ត្របច្ចុប្បន្ន ដែលរៀបចំរួចហើយ ដើម្បីគាំទ្រចំពោះកម្មការិនីកាត់ដេរ នៅក្នុង ព្រឹត្តិការណដែលវិស័យនេះជួបប្រទះ នូវភាពមិនប្រក្រតី និងត្រួតពិនិត្យទៅលើគម្រោងផ្តួចផ្តើម ដើម្បីគាំទ្រចំពោះស្ត្រី ក្នុងការទទួលយកផលប្រយោជន៍ពីឱកាស ប្រសិនបើឱកាសនេះមាននៅក្នុង ផ្នែកកាត់ដេរ ឬក្នុងឧស្សាហកម្មផ្សេងៗទៀត ។
- កំណត់នូវកម្មវិធីអន្តរាគមន៍ និងគោលនយោបាយបន្ថែម ដែលអាចមានប្រយោជន៍ក្នុងការអនុវត្តន៍ ដោយយូនីហ្វមក្រោមកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារផ្សេងៗ រួមជាមួយនឹងសន្ទស្សន៍ ដែលអាចប្រើ ដើម្បីវាស់វែងការរីកចម្រើន នៅក្រោមកម្មវិធីយេនឌ័រ និងកម្មវិធីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ជាពិសេស ជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ទី១ និងទី ៦។

ព័ត៌មានអំពីសកម្មភាព ដែលបានធ្វើផែនការហើយឬកំពុងអនុវត្ត គឺទទួលបានស្របពេលជាមួយនឹងការសរសេរឯកសារនេះ ទោះបីជាយ៉ាងណាក៏ដោយ ដោយមានភ្នាក់ងារជាច្រើន ដែលបច្ចុប្បន្ននេះ កំពុងតែផ្តោត ទៅលើផ្នែកកាត់ដេរ គំនិតផ្តួចផ្តើមមួយចំនួនដែលពាក់ព័ន្ធ មិនត្រូវបានគេបញ្ចូល ហើយសកម្មភាព នឹងមានការផ្លាស់ប្តូរនៅពេលដែលគម្រោងការមានការវិវត្តន៍ ។ លើសពីនេះទៅទៀត ការធ្វើតេស្តបន្ថែម ទៅលើជម្រើសនិងយុទ្ធសាស្ត្រ ព្រមទាំងក្រុមពាក់ព័ន្ធ ដែលបានបង្ហាញនៅក្នុងឯកសារនេះជាតម្រូវការចាំបាច់។ ដូច្នេះ ឯកសារនេះ រៀបចំឡើង ដើម្បីឱ្យមានការពិភាក្សា នៅក្នុងចំណោមអង្គការស្ត្រី និងភ្នាក់ងារចាប់អារម្មណ៍មួយចំនួន ទៅលើកម្មវិធីអន្តរាគមន៍ និងគោលនយោបាយ ដែលអាចអនុវត្តទៅបាន និងទៅលើសកម្មភាព ដែលតម្រូវឱ្យអនុវត្ត នាពេលអនាគតដ៏ខ្លី ដើម្បីជួយគាំទ្រ ចំពោះកម្មការិនី នៅក្នុងឧស្សាហកម្មកាត់ដេរ ។

## ២ ស្ត្រីក្នុងឧស្សាហកម្មកាត់ដេរ : ព័ត៌មានលម្អិត

*ក្រុមដែលងាយនឹងទទួលរង នូវផលប៉ះពាល់ពីសង្គម ត្រូវការឱ្យខាងតែបានទូវការងារ ដែលជួយពួកគេឱ្យរួចផុតពីភាពក្រីក្រ និងអសមត្ថភាព ។ ប៉ុន្តែគេមិនអាចជៀសផុតពីបញ្ហានេះបានឡើយ បើសិនជាថៅកែ នៅតែផ្តល់ឱ្យពួកគេនូវប្រាក់ឈ្នួលតិចតួច បង្ខំឱ្យធ្វើការធ្ងន់និងឱ្យធ្វើការច្រើនម៉ោង ព្រមទាំងព្យាយាម មិនផ្តល់ប្រាក់កម្រៃ ឱ្យពួកគេត្រឹមត្រូវនោះ ( អុកស្វាម អន្តរជាតិ ២០០៤:៥) ។*

មានឱកាសតិចតួចណាស់សំរាប់ស្ត្រីកម្ពុជានៅក្នុងទីផ្សារពលកម្មការងារក្នុងប្រព័ន្ធ ព្រោះវាមានតែនៅក្នុងឧស្សាហកម្មកាត់ដេរប៉ុណ្ណោះ ដែលផ្តល់ការងារមានប្រាក់ឈ្នួលច្រើនគួរសមដល់ស្ត្រី ។ ដោយសារប្រទេសកម្ពុជាជាប្រទេសមួយដែលមានអត្រា នៃការចូលរួមទីផ្សារពលកម្មការងារស្ត្រីខ្ពស់ជាងគេ នៅក្នុងអាស៊ី ៨២%នៃស្ត្រីដែលមាន អាយុលើសពី ១៥ ឆ្នាំ ភាគច្រើនធ្វើការនៅក្នុងវិស័យក្នុងប្រព័ន្ធ ឬ ក៏ធ្វើការនៅក្នុងកសិដ្ឋាន និងអាជីវកម្មគ្រួសារ ដែលមិនបានទទួលប្រាក់ឈ្នួលសំរាប់ពលកម្ម (យូនីហ្វាម អេ អល ២០០៤ ប៊ី.៣៨.៣៨) ។ ហាសិបបីភាគរយ(៥៣%)នៃស្ត្រីដែលសកម្មនៅក្នុងវិស័យសេដ្ឋកិច្ច ប្រើពលកម្មរបស់ខ្លួនដោយមិនបានទទួលប្រាក់ឈ្នួល ។ ចំណែកនៅក្នុងវិស័យក្រៅប្រព័ន្ធវិញស្ត្រីសកម្មនៅក្នុងរបររកស៊ីកំប៉ិកកំប៉ុកលក់ដូរនៅតាមផ្លូវនិងនៅក្នុងរបររកស៊ីផ្លូវភេទ ។ វិស័យមិនផ្លូវការនៅក្នុងប្រទេសកម្ពុជា មិនមាន វិធានការ ឬច្បាប់គ្រប់គ្រងត្រឹមត្រូវទេ ហើយការទទួលបានវគ្គបណ្តុះបណ្តាលសេវាកម្ម និងឥណទាន គឺនៅមានកំរិតផងដែរ ។ លើសពីនេះទៅទៀត កំរិតប្រាក់ឈ្នួល ហើយនិងលក្ខខ័ណ្ឌការងារ ជាទូទៅស្ថិតនៅក្នុងកំរិតទាប ហើយស្ត្រីទាំងនោះទទួលរងនូវការយាយីផ្លូវភេទ ហើយត្រូវតែធ្វើការសូកប៉ាន់ ដើម្បីអាចទទួល ឬស្ថិតនៅក្នុងតួនាទីនេះ (យូនីហ្វាម អែត អល ២០០៤ប៊ីៈ ៤៤.ហ្គរមែន អែល អល ១៩៩៩: ៤១) ។ ផ្នែកសំលៀកបំពាក់ ផ្តល់កំរិតប្រាក់ចំណូលខ្ពស់ជាង ហើយលក្ខខ័ណ្ឌការងារប្រសើរជាងនៅកន្លែងផ្សេង ដែលស្ត្រីធ្វើការ ។ ថ្មីៗនេះការសិក្សាភាគច្រើន ដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តោតទៅលើផ្នែកកាត់ដេរ និងបទពិសោធន៍ការងាររបស់ស្ត្រីនៅក្នុងផ្នែកកាត់ដេរ (ស៊ី អអាយ ២០០៤) ។ ការសិក្សាទាំងនេះផ្តោតសំខាន់ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ស្ត្រី ការលើកទឹកចិត្តគោលបំណងរបស់ពួកគេ និងលក្ខខណ្ឌការងារដែលគេមានបទពិសោធន៍ថ្មីៗ ហើយនិងជីវិតរស់នៅរបស់ពួកគេ នៅ "ក្រៅរបងរោងចក្រ" ។ ព័ត៌មាន លម្អិតមាននៅទីនេះ ។

### ២.១ ស្ថានភាពសេដ្ឋកិច្ចសង្គម

ស្ត្រីនៅក្នុងផ្នែកកាត់ដេរភាគច្រើនគឺជាស្ត្រីវ័យក្មេង ហើយជាអ្នកមកពីជនបទ ។ ការស្រាវជ្រាវរបស់ ធនាគារអភិវឌ្ឍន៍អាស៊ីបានរកឃើញថា ៦៧% គឺជាស្ត្រីដែលមានអាយុចាប់ពី១៤-១៨ឆ្នាំ ហើយត្រឹមតែ ៧% ប៉ុណ្ណោះ ដែលនៅទីក្រុងភ្នំពេញ ។ ស្ត្រីទាំងនោះ ភាគច្រើនមកពីខេត្តកំពង់ចាម កណ្តាល និងព្រៃវែង ភាគច្រើននៃស្ត្រីទាំងនោះគឺមិន ទាន់រៀបការ ។ កំរិតការអប់រំ និងជំនាញរបស់ពួកគេឋិតនៅក្នុងកំរិតទាប ដែលក្នុងនោះ ៩០% បានសិក្សារយៈពេល៩ឆ្នាំ នៅ ក្នុងវិស័យអប់រំក្នុងប្រព័ន្ធ

ហើយចំពោះស្ត្រីភាគច្រើន ការងារ នៅរោងចក្រគឺជាការងារលើកទី១របស់ពួកគេ ហើយពួកគេ មានជំនាញទីផ្សារតិចតួច (ស៊ី អឌី ២០០៤ : ២០) ។ តាមពិត បច្ចុប្បន្ននេះ មានការធានាការងារតិចតួចណាស់ នៅក្នុងផ្នែកកាត់ដេរ ឬក៏មិនមានការធានាឱ្យមានជំនាញ ឬបទពិសោធន៍ ទោះបីជាផ្នែកកាត់ដេរ នឹងត្រូវបញ្ចូលទៅជា ឧស្សាហកម្មធំៗ បន្ទាប់ពី ឆ្នាំ២០០៤ក៏ដោយ ។ ដោយសារពួកគេធ្វើការបន្ថែមម៉ោង ដូច្នេះពួកគេ អាចទទួលបានប្រាក់ឈ្នួល ជាមធ្យម ពី៥០ទៅ៧៥ ដុល្លារ ក្នុងមួយខែ ហើយគេផ្ញើប្រាក់ប្រមាណជា ១០ទៅ៣០ ដុល្លាទៅគ្រួសាររបស់គេក្នុងមួយខែៗ ។ ការចំណាយសំរាប់ជីវភាពរស់នៅ និងទៅលើសេវាកម្មសុខភាពច្រើន ដោយសារជីវភាពរស់នៅ និងការងារមិនអំណោយផល ធ្វើឱ្យប្រាក់ចំណូលរបស់គេត្រូវចំណាយអស់គ្មានសល់ ។

## ២.២ ការជំរុញលើកទឹកចិត្តនិង គោលបំណង

ការឡើយហត់ក្នុងការងារជាស្ត្រីដ៏ធ្ងន់លើសប្រមាណចំពោះសេចក្តីត្រូវការខាងសេដ្ឋកិច្ច និងគ្រួសាររបស់គេនោះហើយ ទើបជំរុញឱ្យស្ត្រីតាមជនបទ មកបំរើការងាររោងចក្រនៅទីក្រុង (ស៊ី អឌី ២០០៤:៣៦) ។

ការបង្ខំចិត្តមករស់នៅទីក្រុង ដើម្បីធ្វើការនៅក្នុងផ្នែកកាត់ដេរគឺទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ច ។ ស្ត្រីទាំងនោះ អាចទទួលបានប្រាក់ចំណូលប្រសើរជាងការរកប្រាក់ចំណូលរបស់ពួកគេ នៅក្នុងសហគមន៍តាមរយៈ ការធ្វើស្រែចំការ ឬ បំរើការងារ លើវិស័យក្រៅប្រព័ន្ធ ។ គេក៏បានគិតផងដែរថា ការធ្វើការនៅរោងចក្រ គឺជាមធ្យោបាយមួយ ដើម្បីលើកកំពស់ជីវភាពរស់នៅ ព្រមទាំងគ្រួសាររបស់ពួកគេ ។ ទោះបីជាមាន ការយល់ខុសរបស់សង្គមទៅលើស្ត្រី ដែលធ្វើការងារនៅក្នុងរោងចក្រកាត់ដេរក៏ដោយចុះ ក៏គ្រួសារនីមួយៗ ជាទូទៅ តែងតែគាំទ្រកូនស្រីរបស់ពួកគេឱ្យចេញពីស្រុកភូមិ ដើម្បីធ្វើការងារ ។ តាមពិតស្ត្រីជំទង់ៗជាច្រើន បានរាយការណ៍ថាពួកគេមិនព្រមចេញទៅធ្វើការក្រៅភូមិទេ ប្រសិនបើពុំមានការព្រមព្រៀងពីឪពុកម្តាយ ទេនោះ នេះគឺជាភស្តុតាងមួយ ដែលគ្រួសារមួយចំនួន បានបោះបង់មុខរបរធ្វើស្រែចំការហើយពឹងផ្អែក ទៅលើកូនស្រីរបស់ខ្លួនដើម្បីផ្គត់ផ្គង់ប្រាក់ចំណូលចំពោះគ្រួសារ និងផ្គត់ផ្គង់ការសិក្សារៀនសូត្ររបស់ប្អូនៗ ជាពិសេស ប្អូនប្រុស និងបងប្អូន (សម្ភាសន៍របស់អង្គការ WAC) ។ ស្ត្រីឱ្យតម្លៃទៅលើប្រាក់ដែលបានពីការងារកាត់ដេរ ហើយនឹងសង្ឃឹមថា ការងារនោះនឹងបន្តទៅទៀត ហើយគោលបំណងដ៏វែងឆ្ងាយរបស់គេ គឺត្រឡប់ទៅ ភូមិស្រុកវិញដើម្បីបន្តធ្វើស្រែចំការ ចាប់ផ្តើមប្រកបអាជីវកម្មផ្ទាល់ខ្លួន ឬក៏ទៅធ្វើការនៅរោងចក្រផ្សេងៗទៀត ដែលអាចទទួលបានប្រាក់កម្រៃខ្ពស់ជាង។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាមួយចំនួនតូចទៀត បានបញ្ជាក់ថា ស្ត្រីមិនសូវដែលបានទទួលព័ត៌មាន អំពីមុខជំនាញផ្សេងៗ ដែលជាតម្រូវការ ដើម្បីទទួលបាននូវឱកាសការងារ ថ្មីនោះឡើយ(CRD២០០៤:៤៤) ។ មូលហេតុដ៏ចម្បងដែលស្ត្រីចាកចេញ ពីការងាររោងចក្រ គឺដើម្បីរកលុយ ឱ្យបានច្រើន ។ ចំណែកស្ត្រីមួយចំនួន ដែលបំរើការងារផ្លូវភេទ ដើម្បីរកកម្រៃបន្ថែមនៅពេលដែល កំពុងធ្វើការនៅក្នុងរោងចក្រកាត់ដេរ គេបានចាត់ទុកថាការងារផ្លូវភេទគឺជាវិធីមួយយ៉ាងសាមញ្ញ នៅពេលដែលគេចាកចេញពីរោងចក្រ ពីព្រោះវាជួយឱ្យពួកគេរក្សានូវកំរិតប្រាក់ចំណូលទាំងនោះផងដែរ ដោយ

ហេតុថាគេពុំមានជម្រើសផ្សេងពីនេះ ( ប៊ូច អែត អល ២០០៣ : ១៥៧. ហ្គូតូស្កា ២០០១ : ៧៩ ) ។ ទិសដៅសាមញ្ញដទៃៗទៀត ចំពោះការចាកចេញពីរោងចក្រ គឺការទៅធ្វើការ នៅក្នុងវិស័យក្រៅប្រព័ន្ធ ។

## ២.៣ ស្ថានភាពកម្មករ

មានចំនួនមួយភាគធំនៃមនុស្សពេញវ័យ ដែលចូលទៅធ្វើការនៅក្នុងរោងចក្រកាត់ដេរ បានបង់កម្រៃជើងសា ដើម្បីទទួលបានការងារនោះ ។ យោងទៅតាមការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានត្រឹមតែ ១៦%ប៉ុណ្ណោះ ប៉ុន្តែ តាមការសិក្សាដទៃៗទៀត បានប៉ាន់ប្រមាណថា មានអត្រាច្រើនជាងនេះនៅក្នុង "ការងារដែលបង់ប្រាក់កម្រៃជើងសានោះ " ។ ការត្រួតពិនិត្យ របស់អង្គការពលកម្មអន្តរជាតិ នៅក្នុងការងាររោងចក្របានសរសេរថា មានការរីកចម្រើនគួរឱ្យចាប់ អារម្មណ៍នៅក្នុងបទដ្ឋានការងារក្នុងរយៈពេលកន្លងមក ។ ទោះបីជាយ៉ាង ណាក៏ដោយ ការស្រាវជ្រាវជាមួយកម្មការិនីរោង ចក្រកាត់ដេរ បានបញ្ជាក់ថា ការអនុវត្តន៍បទដ្ឋានការងារ នៅតែមិនទាន់មានភាពប្រសើរនៅឡើយ ។ ការសិក្សាមួយចំនួនទៀត បានលើកឡើងថា រោងចក្រអាចធ្វើ ឯកសារបន្លំ ដើម្បីបង្ហាញថា ការអនុវត្តន៍ទៅតាមបទដ្ឋាន មានភាពជោគជ័យ ( អុកស្វាម ២០០៤: ៣៩ ) ។ ការមិនគោរពបទដ្ឋានការងារបានរៀបរាប់នៅក្នុងឯកសារស្រាវជ្រាវមាន :

- បង្ខំឱ្យធ្វើការក្រៅម៉ោង ហើយត្រូវតែធ្វើការលើសម៉ោង ដើម្បីប្រាក់ខែមួយដែលអាចចិញ្ចឹមជីវិតបាន
- បរិស្ថានការងារមិនល្អ ខ្វះលក្ខខណ្ឌការងារសុវត្ថិភាព
- ពុំមានការអនុញ្ញាត ការដាក់ទណ្ឌកម្ម ចំពោះអ្នកដែលឈប់សំរាក ហើយនិងការបណ្តេញចេញ ដោយអយុត្តិធម៌ ។
- មានការកើនឡើងនូវការរំខានផ្សេងៗ ដូចជាការយាយីផ្លូវភេទ និងការរំលោភ ។
- ពុំមានសុវត្ថិភាពការងារ ដោយពុំមានកិច្ចសន្យាការងារ ដែលជាហេតុធ្វើឱ្យមានការបណ្តេញចេញ កម្មករ នៅពេល ដែលការផលិតមានភាពយឺតយ៉ាវ ឬបិទរោងចក្រ ។

តាមពិតលក្ខខណ្ឌការងារដែលមិនល្អហើយនិងសុខភាពអន់ថយ វាជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយ ដែលធ្វើឱ្យស្ត្រីចាកចេញពីរោងចក្រ ( ស៊ី អឌី ២០០៤ ) ។

ការស្រាវជ្រាវក៏បានបញ្ជាក់ផងដែរថា និយោជកចូលចិត្តស្ត្រីដែលមានវ័យក្មេង ( ជំទង់ៗ ) ពីព្រោះ គេគិតថា ស្ត្រីទាំងនោះ មានលទ្ធភាពធ្វើការបានច្រើនមុខ ហើយមានការប្រយ័ត្នប្រយែង ហើយនិងទំនងជា មិនក្លាយទៅជា សកម្មជន ឬក៏មិនបង្កការ រាំងស្ទះ តាមរយៈការបង្កើតជម្លោះក្នុងរោងចក្រ ។ អាចនិយាយបាន ម្យ៉ាងទៀតថាស្ត្រីទាំងនោះ ត្រូវបានគេគិតថាជាអ្នក ដែលមិនចេះតវ៉ានិងចាំតែធ្វើតាម (ស៊ីអឌី២០០៤:៣) ដោយសារមានតែចំនួនប្រមាណជា៤0% នៃស្ត្រីជាសមាជិកសហជីព ជាទូទៅបុរស ជាអ្នកដឹកនាំសហជីព ហើយស្ត្រីមិនសមធ្វើជាតំណាងឱ្យមុខងារទាំងនេះទេ ។

និយោជកមួយចំនួនសម្តែងការមិនពេញចិត្តចំពោះការតម្រូវឱ្យមានការគោរពទៅតាមបទដ្ឋានការងារ និងការចំណាយ ទៅលើបញ្ហានេះ ( បើរេសហ្វត អេ អល ២០០៤: ១៥៧ ) ដោយលើកឡើងថា តម្រូវការសំរាប់ការអប់រំបន្ថែម លុះត្រាតែកម្ពុជា

ត្រូវតែរៀបចំខ្លួនឯងឱ្យបានជោគជ័យ ក្នុងការទទួលខុសត្រូវ សង្គមកិច្ច ដែលជា របៀបមួយសំរាប់ការពារ និងលើកកំពស់ខាងផ្នែកកាត់ដេរ ។

**២.៤ នៅខាងក្រៅរោងចក្រ ៖**

ដោយសារកម្មការិនីរោងចក្រភាគច្រើនជាស្ត្រីវ័យក្មេង ហើយមកពីតំបន់ជនបទ គេទាំងនោះឋិតនៅ ក្នុងលក្ខណៈមួយដែលងាយទទួលរងនូវការកេងប្រវ័ញ្ច និងការរំលោភទាំងនៅក្នុងរោងចក្រ ទាំងនៅក្នុងការរស់នៅរបស់គេនៅខាងក្រៅ ។ កម្មការិនីទាំងនោះ រស់នៅជាមួយគ្នាជាក្រុមនៅកន្លែង ដែលគ្មានអនាម័យ ជាពិសេស គឺនៅកន្លែងដែលគ្មានទឹក ឬបង្គន់ ។ ដោយសារពួកគេផ្ញើចំណូលមួយចំនួនធំទៅគ្រួសារ របស់ពួកគេ គេតែងតែមិនបានហូបចុកគ្រប់គ្រាន់ហើយចំណាយមួយចំណែកទៀតនៃប្រាក់ឈ្នួលរបស់គេ ទៅលើសេវាសុខភាព ( ឯកជន ) ពួកគេមានការព្រួយបារម្ភ ចំពោះសុវត្ថិភាពរបស់ពួកគេជាពិសេសនៅពេលដែល គេធ្វើដំណើរចេញពីរោងចក្រ ទៅកន្លែងស្នាក់នៅរបស់ពួកគេពេលយប់ បន្ទាប់ពីវេនការងារវែង (Long shifts) ឬក៏ការងារបន្ថែមម៉ោង ដូចជាការប្លន់ ការយាយី និងការរំលោភផ្លូវភេទ ( ឃែរ អន្តរជាតិ ១៩៩៩ ហ្គរមែន ១៩៩៧ ) ។ កង្វះខាតការយល់ដឹងអំពីសុខភាពបន្តពូជ និង សុខភាពផ្លូវភេទ ក៏បានធ្វើឱ្យ ពួកគេងាយទទួលរងនូវការឆ្លងជំងឺកាមរោគ ហ៊ីវ/អេដស៍ ទោះបីជា អត្រានៃការចម្លង ហាក់បីដូចជាទាប ក៏ដោយ ( ការសម្ភាសន៍របស់អង្គការ ឃែរ ) ។

## ៣ ឥទ្ធិពលនៃការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ហើយនិងការបញ្ចប់ ប្រព័ន្ធកូតានិងកិច្ចព្រមព្រៀងពហុវាយនភណ្ឌ :

*កម្ពុជាប្រហែលជានឹងបាត់បង់ការទទួលនូវការអនុគ្រោះ ដែលប្រទេសនេះធ្លាប់បានទទួលកូតាពីមុនៗ ដោយសារការបញ្ចប់នៃកិច្ចព្រមព្រៀងវាយនភណ្ឌដោយសារចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក ក្នុងខែ ធ្នូ ឆ្នាំ ២០០៤ ។ ប្រទេសកម្ពុជា មិនមានបំណងចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលជាទីផ្សារ ដ៏ទូលំទូលាយនេះទេ ដោយសារតែត្រូវធ្វើការប្រកួតប្រជែងច្រើន ជាមួយនឹងប្រទេសដែលមានសមត្ថភាពប្រកួតប្រជែង ខ្ពស់ដូចជាប្រទេស ចិន និងឥណ្ឌា ។ ( អ៊ុកស្វាម អន្តរជាតិ ២០០៤ប៊ី: ៥) ។*

ការព្យាករណ៍អំពីអនាគតនៃផ្នែកកាត់ដេរ បន្ទាប់ពី ឆ្នាំ២០០៤ មានភាពខុសគ្នាយ៉ាងច្រើន។ ទោះបីជា ភ្នាក់ងារមួយចំនួនបានធ្វើការព្យាករណ៍អំពីផលមិនល្អយ៉ាងណាក៏ដោយ ទស្សនៈវិជ្ជមានមួយចំនួនធំបាន ដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា និងផ្នែកកាត់ដេរខ្លួនឯងផ្ទាល់ អំពីលក្ខខ័ណ្ឌដែលថា កំណែទម្រង់មួយ ចំនួនធំដែលបានស្នើឡើង ត្រូវបានគេអនុវត្តដើម្បីបង្កើននូវផលិតភាព និងដើម្បីកាត់បន្ថយទៅ លើឧស្សាហកម្ម ។ ឧទាហរណ៍ :

- នៅក្នុងសេចក្តីថ្លែងការណ៍មួយ ស្ថាប័នរូបិយវត្ថុអន្តរជាតិបានព្យាករណ៍ទុកថា ការរីកចម្រើននឹងមាន ការធ្លាក់ចុះពី៥-៦% ទៅដល់ពី ១-២ ភាគរយនៃទិន្នផលក្នុងស្រុកសរុប (GDP) នៅក្នុងឆ្នាំ២០០៥ ដោយសារ ការបញ្ចប់ប្រព័ន្ធកូតា ហើយនិងការប្រកួតប្រជែង ដោយផ្ទាល់ជាមួយប្រទេសដទៃទៀត ។
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានលើកឡើងថាប្រទេសកម្ពុជា នឹងជួបការលំបាក ក្នុងការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិបន្ទាប់ពីការចូលជាសមាជិកអង្គការអន្តរជាតិដោយសាររោងចក្រ ជាច្រើន នឹងត្រូវប្តូរទីតាំងទៅប្រទេសចិន នៅពេលដែលលក្ខខណ្ឌកំណត់ ឈានចូលទៅដល់ការលុបចោល ក្នុងឆ្នាំ ២០០៨ ( ប៊ើរេសហ្វត អេ អល ២០០៤: ១៦៤ ) ។
- ធនាគារពិភពលោកបានស្នើយោបល់ឡើងថា ការប្រកួតប្រជែងថ្លៃដើម នឹងក្លាយទៅជាបញ្ហាមួយ ដ៏សំខាន់ ដោយមានការបញ្ចូលគ្នាឆ្លងកាត់ច្រកព្រំដែន ដើម្បីធ្វើឱ្យសេដ្ឋកិច្ចមានកំរិតខ្ពស់។ ( ធនាគារ ពិភពលោក ២០០៤:៣៨) ។
- ការសិក្សាមួយមានទំហំធំដែលសរសេរឡើងដោយទីភ្នាក់ងារអភិវឌ្ឍន៍ជំនួយសហរដ្ឋអាមេរិក បានទាយទុកថាប្រទេសទាំងឡាយ លើកលែងតែប្រទេសចិននឹងបន្តផ្គត់ផ្គង់សំលៀកបំពាក់ទៅដល់ទីផ្សារ សហរដ្ឋអាមេរិកនិងអឺរ៉ុបតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះទ្វេភាគី ។ របាយការណ៍ បានបញ្ជាក់ថាប្រទេសចិន នឹងធ្វើវិនិយោគទុននៅក្នុងការផលិតវាយនភណ្ឌ ដើម្បីអភិវឌ្ឍប្រទេស ជាមួយនឹងការវិនិយោគរោងចក្រវាយនភណ្ឌសំខាន់ៗ ដែលនឹងរៀបចំឡើង នៅពេលណាមួយ នៅទីក្រុង ព្រះសីហនុ ( សាលីងជើ ២០០៤: ៣) ។
- សមាគមផលិតករសំលៀកបំពាក់កម្ពុជា (GMAC) បានប្រកាន់ទស្សនៈថា វានឹងពុំមាន ការបាត់បង់ការងារធំដុំនោះទេ ដោយសារគេបានប៉ាន់ប្រមាណថា រោងចក្រតូចៗមួយចំនួនអាចបិទមែន ប៉ុន្តែរោងចក្រធំៗចំនួន ១០ អាច

នឹងពង្រីកឡើងដោយស្រូបយកការងារដែលបាត់បង់ ហើយកាត់បន្ថយ ការងារ ដែលបាត់បង់បន្តិចម្តងៗ (ការសម្ភាសន៍ជាមួយ សមាគមផលិតករសំលៀកបំពាក់កម្ពុជាកម្ពុជា) ។

- អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានប្រកាន់នូវទស្សនៈ ដែលមិនពេញចិត្តដោយទាយថា នៅពេលដែលកូតាត្រូវបានបញ្ចប់ ក្រុមហ៊ុនដែលមានទុនតិចជាងគេ នឹងត្រូវបរាជ័យ ពេលនោះការកាត់បន្ថយកម្មករ និងសម្ពាធលើលក្ខខណ្ឌការងារ និងប្រាក់ខែ អាចនឹងកើតឡើង (អង្គការអ៊ុកស្វាមអន្តរជាតិ ២០០៤អេះ៤៦) ។

រាជរដ្ឋាភិបាលកម្ពុជាបានប៉ាន់ប្រមាណថា ប្រមាណជា ៣០% នៃការនាំចេញរបស់ប្រទេសកម្ពុជា អាចស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដោយសារការប្រកួតប្រជែងពីប្រទេសចិន និងប្រទេសផ្សេងៗទៀត ។ ការធ្លាក់ចុះក្នុងរយៈពេលខ្លី គួរឱ្យចាប់អារម្មណ៍ គឺទំនងជានៅក្នុងឆ្នាំ ២០០៥ ដែលមានចំនួនរហូតដល់ ១/៣ នៃក្រុមហ៊ុនដែលនឹងបិទទ្វារ។ ក្រុមហ៊ុនធំៗ នឹងទទួលយកភាគហ៊ុនទីផ្សារដែលបាត់បង់ ហើយរោងចក្រមួយចំនួន នឹងត្រូវរើទីតាំងទៅក្រៅប្រទេស (រាជរដ្ឋាភិបាលកម្ពុជា ២០០៤:៣៨) ។

អ្នកទិញនឹងស្វែងរករោងចក្រណាដែលផ្តល់ភាពបត់បែន និងសកម្មជានិច្ច ព្រមទាំងតម្លៃលក់ស្ថិតនៅក្នុងការប្រកួតប្រជែង (ណរដាស់ ២០០៤) ។ អ្នកទិញទាំងនោះ នឹងចូលមកធ្វើទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ (supplier) ដោយមិនបាច់មានភ្នាក់ងារបន្ត និងក្រុមហ៊ុននាំចូល ។ អ្នកទិញទាំងនេះ នឹងបញ្ជូនប្រាក់ចំណាយសំរាប់ផលិតទៅក្នុងរោងចក្រដោយសង្ឃឹមថា រោងចក្រនឹងផ្តល់នូវការទិញបណ្តាក់ ដោយគ្មានការ ប្រគល់ប្រាក់រហូតដល់សំលៀកបំពាក់ ត្រូវបានលក់ដាច់អស់ ដោយអ្នកលក់រាយ ។ អ្នកទិញសង្ឃឹមថា រោងចក្រនឹងមានការទទួលខុសត្រូវថែមទៀត ។ ឧទាហរណ៍ ការចែកចាយផលិតផលរបស់ពួកគេ (ក្រសួងពាណិជ្ជកម្ម សុន្ទរកថា ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០០៤ ) ។ អ្វីដែលបានរៀបរាប់ខាងលើមានន័យថា សម្ពាធ ដែលបានដាក់ដោយអ្នកទិញ ដើម្បីធានាថា អ្នកផ្គត់ផ្គង់អនុវត្តទៅតាមបទដ្ឋានការងារ វាក៏មានន័យថា រោងចក្រទទួលខុសត្រូវថែមទៀត លើការចំណាយប្រាក់សំរាប់ផលិត ហើយអាចបញ្ជូនប្រាក់ចំណាយទាំងនេះ ទៅដល់កម្មករតាមរយៈការកាត់ប្រាក់ខែ ។

រាជរដ្ឋាភិបាលកម្ពុជាបានជជែកពិភាក្សាថា បើសិនជា មិនមានការកែទម្រង់ធំដុំនោះទេ ផ្នែកកាត់ដេរនឹងជួបប្រទះបញ្ហាលំបាកក្នុងឆ្នាំ២០០៥ ហើយក្រុមហ៊ុនមានចំនួនដល់ ៣០% នៃក្រុមហ៊ុនទាំងអស់នឹងត្រូវបិទទ្វារ ( រាជរដ្ឋាភិបាលកម្ពុជា ២០០៤ : ៤០ ) ។ លើសពីនេះទៅទៀត របាយការណ៍មួយចំនួន តូចបានលើកឡើងថា ប្រាក់ខែមាន "កំរិតខ្ពស់ណាស់" ហើយលក្ខខណ្ឌការងារ "ល្អណាស់ "បន្ថែមទៅលើការចំណាយរបស់រោងចក្រហើយបានលើកឡើងថា រួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធ និងត្រូវការកាត់បន្ថយ ដើម្បីឱ្យរោងចក្រអាចប្រកួតប្រជែងនឹងគេបាន (រាជរដ្ឋាភិបាល ២០០៤:បណ្ឌិត ហង្ស ជួនណារ៉ុង ២០០២) ។

ដោយមានការព្យាករណ៍ខុសៗគ្នាយ៉ាងដូច្នេះ វាមិនអាចប៉ាន់ប្រមាណថា អ្វីនឹងកើតឡើង បន្ទាប់ពីឆ្នាំ ២០០៤ ឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វាហាក់បីដូចជា :

- រោងចក្រមួយចំនួននឹងបិទទ្វារ ជាពិសេសក្រុមហ៊ុនតូច ៗ
- ការងារថ្មីៗមួយចំនួននឹងអាចបង្កើតឡើង ដោយសាររោងចក្រធំៗ អាចស្រូបយកភាគហ៊ុនទីផ្សារពីក្រុមហ៊ុនដែលបិទទ្វារ ។
- ក្រុមហ៊ុនមួយចំនួនទៀត នឹងបញ្ចូលប្រតិបត្តិការទូទាំងប្រទេសដើម្បីបង្កើតនូវប្រសិទ្ធភាពខ្ពស់ឡើង
- ក្រុមហ៊ុនថ្មីមួយចំនួនទៀតអាចបើកហើយប្រទេសមួយចំនួនដូចជាប្រទេសចិន អាចវិនិយោគនៅកម្ពុជា ឧទាហរណ៍ដូចជាការផលិតវាយនភណ្ឌ ។
- បើសិនជាកំណែទម្រង់ត្រូវបានគេរៀបចំឡើងដើម្បីកាត់បន្ថយនូវចំណាយទៅលើវិស័យឯកជនមិនត្រូវបានគេអនុវត្តទាន់ពេលវេលានោះទេ វាទំនងជាមានសម្ពាធគួរឱ្យចាប់អារម្មណ៍ទៅលើការកាត់បន្ថយ ប្រាក់ឈ្នួល កាត់បន្ថយវេនធ្វើការ (turnaround times) ហើយនឹងដាក់សម្ពាធ ដើម្បីបង្កើននូវបរិមាណ គុណភាព ក្នុងគោលបំណងឱ្យរោងចក្រអាចប្រកួតប្រជែងនឹងគេបាន ។
- ជាមួយគ្នានេះដែរ ការទទួលខុសត្រូវសាជីវកម្មសង្គមកិច្ច អាចក្លាយទៅជាផ្នែកមួយនៃយុទ្ធសាស្ត្រ "**ប្រើផ្លាក**" រាជរដ្ឋាភិបាលកម្ពុជា ដោយមានហេតុផលថា លក្ខខណ្ឌការងារនឹងត្រូវបានគាំពារ ។ ការផ្តល់ជំនាញ និង ចំណេះដឹងថ្មីគឺជាការងារថ្មីរបស់អ្នកគ្រប់គ្រង និងបុគ្គលិក ។
- តួនាទីដែលត្រូវការជំនាញច្រើនមួយចំនួនអាចនឹងបើកចំហ នៅពេលដែលក្រុមហ៊ុនទាំងឡាយ ឈានទៅដល់ការលើកកំពស់ ការអនុវត្តន៍ការគ្រប់គ្រង និងការប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី ។
- ដោយសារទីផ្សារពលកម្មបច្ចុប្បន្ន មិនត្រូវការកម្លាំងពលកម្មដែលមានជំនាញខ្ពស់ ការខ្វះខាត ជំនាញនឹងអាចកើតមានឡើង នៅពេលដែលរោងចក្រនីមួយៗ រុះរើរចនាសម្ព័ន្ធ ដើម្បីឱ្យក្លាយទៅជាឧស្សាហកម្មទាន់សម័យរួមជាមួយនឹងការអភិវឌ្ឍន៍ធនធានមនុស្ស ហើយនិងវិនិយោគ ដោយរាជរដ្ឋាភិបាល និងផ្នែកកាត់ដេរផងដែរ ។

ការព្យាករណ៍អំពីឥទ្ធិពលជាសក្តានុពលពីពាណិជ្ជសេរីភាវូបណីយកម្ម បានឆ្លុះបញ្ចាំងអំពីទស្សនៈ ខុសៗគ្នាអំពីកាលៈទេសៈ ដែលអ្នកក្រទទួលផលប្រយោជន៍ ពីការលូតលាស់ និងប្រភេទនៃការលូតលាស់ ដើម្បីកាត់បន្ថយភាពក្រីក្រ ។ ភ្នាក់ងារមួយចំនួនបន្តជជែកពិភាក្សាថា ការលូតលាស់គឺជារបៀប ដ៏ប្រសើរ ដើម្បីកាត់បន្ថយភាពក្រីក្រ ។ ចំណែកឯ អ្នកដទៃវិញបានគូសបញ្ជាក់ថា បញ្ហានេះវាពឹងផ្អែកទៅលើការលូត លាស់ ដែលត្រូវបានគេធ្វើឡើង ។ អ្នកផ្សេងទៀតបានលើកឡើងថា ការលូតលាស់ទំនងជាមិនផ្តល់ផលប្រយោជន៍ និងប្រសិទ្ធភាពស្មើៗគ្នានោះទេ ជួនកាលបង្កើតនូវសេដ្ឋកិច្ច "ពីរថ្នាក់" ដែលក្នុងនោះមនុស្សមួយចំនួនទទួលផលប្រយោជន៍ ហើយមនុស្សមួយចំនួនទៀត មិនបានទទួលផលប្រយោជន៍ឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គេយល់ស្របជាទូទៅថានៅក្នុងប្រទេសកម្ពុជា ការលូតលាស់មានតិចតួចណាស់ ដោយអាចផ្តល់ប្រយោជន៍ត្រឹមតែ៦-៧%នៃប្រជាជនកម្ពុជាប៉ុណ្ណោះ ដែលធ្វើការនៅក្នុងវិស័យឧស្សាហកម្ម ចំណែកមនុស្សភាគច្រើនស្មើនឹង ៨0% ធ្វើកសិកម្មនៅក្រៅទីក្រុង ។ ការវិនិយោគទុន ដ៏ធំជាងមុននៅក្នុងកសិឧស្សាហកម្មការធ្វើឱ្យមានផលិតផលនិងសេវា

កម្មចម្រុះ ហើយនិងការបង្កើតនូវទំនាក់ទំនងរវាងគ្នាទៅវិញទៅមកគឺជាអនុសាសន៍ ដើម្បីបង្កើតនូវប្រភេទនៃការលូតលាស់ដែលជាតម្រូវការចាំបាច់ ក្នុងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយជោគជ័យ (ប៊ើរេស ហ្វត អេ អល ២០០៤: ១៦៤ ធនាគារពិភពលោក ២០០៤) ដូចបានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងម្ចាស់មូលនិធិដែលកំពុងតែផ្តោតទៅលើយុទ្ធសាស្ត្រនិងអន្តរាគមន៍ជាច្រើនដើម្បីធ្វើឱ្យវិស័យកសិកម្មផលិតបានកាន់តែច្រើនជាងមុន ។ យុទ្ធសាស្ត្ររយៈពេលវែងទាំងនេះ មានសារៈសំខាន់ណាស់ ដើម្បីបង្កើនការងារ ក្នុងនោះសំរាប់មនុស្សថ្មី ដែលនឹងរកការងារនៅក្នុងទីផ្សារពលកម្ម ចំនួន២០០០០០ នាក់ក្នុងមួយឆ្នាំ៧ ។ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏យុទ្ធសាស្ត្រនេះនឹងមិនអាចរៀបចំឡើងទាន់ពេលវេលា ដើម្បីកាត់បន្ថយនូវផលវិបាកមិនល្អណាមួយ ដែលនឹងអាចកើតមានឡើង ចេញពីពាណិជ្ជសេរីភាវូបណីយកម្មចំពោះស្ត្រី (និងបុរស) ដែលបច្ចុប្បន្ននេះ កំពុងតែបំរើការងារនៅក្នុងវិស័យកាត់ដេរ ។

## ៣.១ ផលប៉ះពាល់ទៅលើកម្មការិនីរោងចក្រកាត់ដេរ :

វាមានការពិភាក្សាគួរឱ្យចាប់អារម្មណ៍អំពីផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបណីយកម្ម ទៅលើវិស័យកាត់ដេរនិងទៅលើសេដ្ឋកិច្ចកម្ពុជា រួមជាមួយនឹងការវិភាគជាយុទ្ធសាស្ត្រ អំពីអ្វីដែលគេត្រូវធានាឱ្យបាននូវ អនាគតនៃឧស្សាហកម្មនិងការគាំទ្រឱ្យមានការលូតលាស់ ។ បច្ចុប្បន្ននេះ ភាគច្រើននៃការពិភាក្សាបាន ផ្តោតទៅលើវិស័យឧស្សាហកម្ម តែមិនផ្តោតជាពិសេសទៅលើតែកម្មការិនី (លើកលែងតែការស្រាវជ្រាវ របស់ ធនាគារអភិវឌ្ឍន៍អាស៊ី ហើយនិងជំនួយការបច្ចេកទេសដែលពិភាក្សានៅខាងក្រោម) ។ វាក៏មិនមាន ការវិភាគដ៏លម្អិតណាមួយ អំពីផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបណីយកម្មមកលើកម្ពុជា ដោយរួមបញ្ចូល នូវទស្សនៈយេនឌ័រនោះឡើយ ។ ថ្វីបើការវិភាគ លើវិស័យច្រើនខ្វាត់ខ្វែងហួសពីអ្វី ដែលមាននៅក្នុងឯកសារបច្ចុប្បន្ននេះក៏ដោយចុះ ក៏មានការចង្អុលបង្ហាញយ៉ាងច្បាស់លាស់ថាផលប៉ះពាល់ នៃកំណែទម្រង់ ពាណិជ្ជកម្មពិតជានឹងមានភាពខុសគ្នាយ៉ាងច្រើន រវាងកម្មកររោងចក្រ ។ ទោះបីជាឧស្សាហកម្ម ទំនងជានឹងទទួលរងនូវភាពច្របូកច្របល់មួយចំនួនក្តី ក៏យើងមិនអាចទស្សន៍ទាយ បានថាតើចំនួនស្ត្រីប៉ុន្មាននាក់ ដែលនឹងទទួលផលប៉ះពាល់ ។ ការប្រមាណទុកតាមលក្ខណៈល្អវានឹងមាន ផលប៉ះពាល់តិចតួច ដោយសាររោងចក្រធំៗនឹងពង្រីក ដើម្បីអាចប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព ។ រោងចក្រនេះ អាចស្រូបយកកម្មករ ដែលត្រូវបានគេកាត់បន្ថយ ដោយសារការបិទរោងចក្រ ។ ទោះបីជាយ៉ាងណាក៏ដោយ តាមការទស្សន៍ទាយទុកជាមុនបែបជាអវិជ្ជមានថា បើសិនជាមាន១/៣ នៃរោងចក្រ (តូចៗបិទទ្វារ) (រាជរដ្ឋាភិបាល ឆ្នាំ២០០៤ :៣៨) ហើយនិងរោងចក្រដទៃៗទៀត ដែលនឹងរើទៅប្រទេសដទៃ ដែលមានច្បាប់ទម្លាប់ត្រឹមត្រូវ ចំនួនកម្មករមួយចំនួនធំ នឹងស្ថិតនៅក្នុងគ្រោះថ្នាក់នៃការកាត់បន្ថយ ពីការងារ ។ឯកសារខ្លះបានប៉ាន់ប្រមាណនឹងបាត់បង់ការងាររហូត ដល់ ៥០ ០០០ កន្លែង ។ ជាសក្តានុពលចំនួនគ្រួសារប្រហែល ២០០០០-៣០ ០០០ និងពី ២០០ ០០០-៤៥០ ០០០ សមាជិកគ្រួសារ អាចទទួលរងនូវផលប៉ះពាល់ ។ផែនការសេដ្ឋកិច្ចគំរូដែលកំពុងតែអនុវត្ត ដោយធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់នូវការប៉ាន់ប្រមាណ ជាក់លាក់ជាងអ្វីដែលបានរៀបចំនៅទីនេះ ។ នៅក្នុងការប៉ាន់ប្រមាណគ្រួសៗនេះ ពុំបានដឹងគ្រប់

គ្រាន់អំពីទំនាក់ទំនង រវាងឧស្សាហកម្មកាត់ដេរ និងវិស័យក្រៅប្រព័ន្ធ អ្នកម៉ៅការបន្ត និងអ្នកធ្វើការម៉ៅការជាដើម ដែលក្នុងនោះភាគច្រើនជាស្ត្រី ។

របាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ( ប៉េរេសហ្វុត អេ អល ២០០៤:១៥៦) បានឱ្យដឹងថា ការងារប្រមាណជា២០០ ០០០-៣០០ ០០០មានទំនាក់ទនងជាមួយ នឹងផ្នែកកាត់ដេរដែលបន្ថែមទៅលើការងារទូទាំងប្រទេស ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវបន្ថែម ត្រូវតែធ្វើដើម្បីឱ្យយល់ដឹងអំពីទំហំ និងសមាសភាពនៃវិស័យក្រៅប្រព័ន្ធ (informal sector) ដែលគាំទ្ររោងចក្រកាត់ដេរ ហើយនិងត្រូវធ្វើការប៉ាន់ប្រមាណឥទ្ធិពលនៃការផ្លាស់ប្តូររបស់រោងចក្រទៅលើស្ត្រី ដែលធ្វើការនៅក្នុងផ្នែកកាត់ដេរក្រៅប្រព័ន្ធនេះ ។

ការប៉ាន់ប្រមាណបឋម អំពីបញ្ហាមួយចំនួនដែលអាចនឹងកើតមានពីការកាត់បន្ថយចំនួនស្ត្រី ដែលបម្រើការងារនៅក្នុង រោងចក្រកាត់ដេរ ដូចខាងក្រោម :

**ការបម្រើឧស្សាហកម្មផ្លូវភេទ** : ដោយពុំអាចរកចំណូលពីប្រភពផ្សេងៗ ឬក៏មុខជំនាញ ដែលអាចទៅធ្វើការនៅកន្លែងដទៃទៀតបាន ហើយនិងមានសម្ពាធពីគ្រួសារឱ្យផ្ញើប្រាក់ទៅផ្ទះ កម្មការិនី មួយចំនួននឹងត្រូវបង្ខំចិត្តទៅធ្វើការនៅក្នុងវិស័យផ្លូវភេទ ។ ការសិក្សាស្រាវជ្រាវមួយនៅទីក្រុងភ្នំពេញ ដោយយោងទៅតាមការអះអាងរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានរកឃើញថា ចំនួនរហូត ដល់៦០%នៃកម្មកររកស៊ីផ្លូវភេទ នៅក្នុងតំបន់មួយនៃទីក្រុង គឺជាអតីតកម្មករនៃរោងចក្រកាត់ដេរ (ប៉េរេសហ្វុត អេ អល ២០០៤:១៥៧) ។ ទោះបីជាពួកគេទទួលបានប្រាក់កម្រៃច្រើនយ៉ាងណាក៏ដោយ ការងារបំរើផ្លូវភេទ កំពុងតែធ្វើឱ្យប៉ះពាល់ និងបង្កើតជាបញ្ហា ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចំពោះស្ត្រី ។

ការរកស៊ីផ្លូវភេទ ក្រៅប្រព័ន្ធ កំពុងតែកើនឡើង ឧទាហរណ៍ ដូចជាស្ត្រីដែលមានតួនាទីជាអ្នកទទួលភ្ញៀវ ឬលក់ដូរអីវ៉ាន់ ក៏មានសម្ពាធបំរើផ្លូវភេទ ជាមួយនឹងអតិថិជនផងដែរ ។ ស្ត្រីទាំងនោះ រួមមាន ស្ត្រីលក់ស្រាបៀរនិងស្ត្រីបម្រើនៅតាមភោជនីយដ្ឋានជាដើម ។ស្ត្រីដែលរកស៊ីផ្លូវភេទ កំពុងតែប្រឈមមុខនឹងគ្រោះថ្នាក់នៃរោគហ៊ីវ/ជម្ងឺអេដស៍ (HIV/AIDs) ពោលគឺនៅពេលដែលអត្រានៃរោគហ៊ីវ / ជម្ងឺអេដស៍(HIV/AIDS) បានរីករាលដាលនៅក្នុងការរកស៊ីផ្លូវភេទក្រៅប្រព័ន្ធជាកន្លែងដែលមានការលំបាកច្រើន នឹងផ្តល់ការអប់រំ និងព័ត៌មាន ជាងកន្លែងដែលមានពេស្យាកម្មមានច្បាប់ (យូនីហ្វាម អេ អល ២០០៤ បេ) ។

**ការវិលត្រឡប់ទៅស្រុកកំណើត ឬសហគមន៍ ដោយពុំមានមុខរបរ ប្រកបដោយនិរន្តរភាព** : ការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញឱ្យឃើញថា មានកម្មការិនីមួយចំនួនមានបំណងចង់វិល ត្រឡប់ទៅរស់នៅឯស្រុកកំណើតរបស់ខ្លួន ដើម្បីប្រកបមុខរបររកស៊ីធ្វើស្រែចំការ និងលក់ដូរកំប៉ិកកំប៉ុកឡើងវិញ ។ ទោះបីជាយ៉ាងណាក៏ដោយក៏គ្រួសារកសិករភាគច្រើន តែងតែពឹងផ្អែកទៅលើកូនស្រីរបស់ខ្លួន មិនត្រឹមតែដើម្បីផ្តល់ប្រាក់ចំណូលបន្ថែមប៉ុណ្ណោះទេ ថែមទាំងឱ្យឧបត្ថម្ភទៅលើការចំណាយរបស់គ្រួសារទាំងមូលទៀតផង ។ ដោយពុំមានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដូចជាការទទួលបានប្រាក់ឥណទាន ឪពុកម្តាយតែងតែដាក់សម្ពាធ ទៅលើកូនស្រីរបស់ខ្លួន ដើម្បីរកប្រាក់ថែមទៀត ដោយឱ្យពួកគេស្នាក់នៅ

ឬត្រឡប់ទៅទីក្រុង ឬក៏ធ្វើអន្តោប្រវេសន៍ទៅក្រៅប្រទេស ដើម្បីស្វះស្វែងរកការងារធ្វើ ។ លើសពីនេះទៅទៀតនោះ ស្ត្រីមួយចំនួន ក៏ហាក់ដូចជាចង់បោះបង់ដីធ្លីរបស់ខ្លួនទៅធ្វើការនៅទីក្រុងវិញ ។

**ការធ្វើអន្តោប្រវេសន៍ទៅរស់នៅក្រៅប្រទេស ដើម្បីរកការងារធ្វើ :** លំហូរនៃអន្តោប្រវេសន៍ នេះនឹងធ្វើឱ្យប៉ះពាល់ទៅលើប្រទេសជិតខាង ដូចជា ប្រទេសថៃ និងវៀតណាម ។ យោងទៅតាមការសិក្សា ស្រាវជ្រាវនាឆ្នាំ ១៩៩៩ ក្រុមគ្រួសារដែលមិនមានដីធ្លី គឺងាយបំផុតក្នុងការផ្លាស់ទីកន្លែងដើម្បីរកការងារធ្វើ ហើយកម្មករ ដែលធ្វើអន្តោប្រវេសន៍ទៅកាន់ប្រទេសទាំងនោះ ដូចជាប្រទេសថៃជាដើម តែងតែប្រឈមមុខ ទៅនឹងគ្រោះថ្នាក់គួរឱ្យកត់សម្គាល់ ( តាមសម្តីរបស់ ចាន់ សុផល និង សូ សុវ៉ាន់ណាប្ញទ្ធិ នៅឆ្នាំ ១៩៩៨) ។ ការធ្វើអន្តោប្រវេសន៍ បាននាំឱ្យស្ត្រីទាំងនោះ ងាយនឹងទទួលរងនូវការឈឺចាប់ ទទួលរងគ្រោះពីការកេងប្រវ័ញ្ច និងការរំលោភ ជារឿយៗនៅក្នុងការងារដែលខុសច្បាប់ និងគ្រោះថ្នាក់ ។ ការធ្វើអន្តោប្រវេសន៍ ក៏បណ្តាលឱ្យមានការបែកខ្ញែកក្រុមគ្រួសារ និងចំណងសហគមន៍ផងដែរ ។ ប្រសិនបើរោងចក្រកាត់ដេរ មួយចំនួនដែលកំពុងតែដំណើរការ នៅក្នុងប្រទេសកម្ពុជា រើចេញទៅប្រទេសក្រៅ វានឹងជំរុញស្ត្រីឱ្យកាន់តែធ្វើអន្តោប្រវេសន៍ ដើម្បីស្វែងរកការងារធ្វើ ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេនឹងជួបប្រទះ នូវការប្រកួតប្រជែងជាមួយនឹងស្ត្រីក្រីក្រនៃប្រទេសទាំងនោះ ដើម្បីទទួលយកការងារ ដែលមានចំនួនកំណត់ ។

**ការធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ :** ស្ត្រីមួយចំនួនតែងតែឈោងចាប់យកការងារនៅក្នុង សេដ្ឋកិច្ចក្រៅប្រព័ន្ធ ទោះបីជាពួកគេមិនមានជំនាញទីផ្សារ ពុំមានព័ត៌មានអំពីទីផ្សារ ឬក៏ពុំអាចទទួល បានឥណទាន យ៉ាងណាក៏ដោយ ក៏ពួកគេតែងតែពុះពារ ដើម្បីទទួលបានជោគជ័យក្នុងការចាប់ផ្តើមនូវមុខរបរ រកស៊ីរបស់គេ ។ ប៉ុន្តែ ពួកគេហាក់ដូចជាពុំអាចបង្កើតឱ្យមានការងារចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព សំរាប់មនុស្សដទៃៗទៀតឡើយ ។

**ការកាត់បន្ថយប្រាក់ឈ្នួល និងការរឹតបន្តឹងលក្ខខណ្ឌការងារ :** បញ្ហានេះ នឹងធ្វើឱ្យមានការកាត់បន្ថយប្រាក់ឈ្នួល និងរឹតបន្តឹងលក្ខខណ្ឌការងារ ចំពោះអ្នកដែលគេរក្សាទុកការងារឱ្យ ។ បទពិសោធន៍នេះ គឺតែងតែមាននៅក្នុង វិស័យផ្សេងៗ និងប្រទេសដែលបើកចំហការប្រកួតប្រជែងជាអន្តរជាតិ ( អង្គការអុក ស្វាមអន្តរជាតិ ២០០០:៥០ ខាតាហ្គេ) ។ គេសង្ឃឹមថា កិច្ចប្រឹងប្រែង ដើម្បីធ្វើឱ្យប្រទេសកម្ពុជាអាចទាក់ទាញនូវសាជីវកម្ម ដែលមានការទទួលខុសត្រូវផ្នែកសង្គមកិច្ច នឹងជួយកាត់បន្ថយការប៉ះពាល់នេះ ។ នៅពេលដែលរោងចក្រធ្វើការកែប្រែរចនាសម្ព័ន្ធ វាមានឱកាសជាសក្តានុពលបើកចំហឱ្យស្ត្រី ដូចជា :

- ការទាមទារឱ្យស្ត្រីមានតួនាទី ដែលមានជំនាញខ្ពស់ នៅពេលដែលរោងចក្រកាត់ដេរ រួម បញ្ចូលគ្នា និងធ្វើការកែលម្អ ដើម្បីឱ្យស្ថិតនៅក្នុងការប្រកួតប្រជែង ។
- រោងចក្រធំៗជាច្រើន អាចស្រូបយកភាគហ៊ុនទីផ្សារមួយចំនួនពីក្រុមហ៊ុនតូចៗ នៅពេលដែលគេបិទ ហើយបើកចំហ ដើម្បីពិភាក្សាអំពីតួនាទីបន្ថែមមួយចំនួនទៀត សំរាប់ស្ត្រីដែលបាត់បង់ការងារ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ស្ត្រីហាក់ដូចជាមិនមានឱកាសណាមួយ ដើម្បីឆ្លៀតយកផលប្រយោជន៍ ពីការជជែក

ពិភាក្សាខាងលើនោះទេ ប្រសិនជាពុំមានការគាំទ្រតាមរបៀបការគាំពារផ្នែកសង្គមកិច្ច និងការអភិវឌ្ឍន៍ជំនាញ ។ សេចក្តីត្រូវការទៅលើជំនាញ ដែលមានកម្រិតខ្ពស់ អាចនឹងផ្តល់នូវកម្រៃចំពោះស្ត្រី ប្រសិនបើពួកគេបានទទួលនូវការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍នូវជំនាញជាផ្លូវការ ដែលជួយឱ្យពួកគេ មានឱកាសដើម្បីទទួលយកផលប្រយោជន៍ ។ ទន្ទឹមគ្នានោះដែរ ការស្រូបយកការងារបន្ថែមម៉ោងមួយចំនួននៅក្នុងរោងចក្រធំៗ អាចនឹងជួយដល់ស្ត្រី ប្រសិនបើពួកគេបានទទួលនូវការឧបត្ថម្ភ ដែលនឹងអាចរស់បាន ឱ្យឆ្លងផុតក្នុងរយៈពេលអន្តរកាល ។

## ៤ យុទ្ធសាស្ត្រនិងអន្តរាគមន៍បច្ចុប្បន្ន

*ការឆ្លើយតបជាយុទ្ធសាស្ត្រមួយចំនួនប្រកបដោយសក្តានុពលចំពោះផលប៉ះពាល់ទៅលើស្ត្រីនៅក្នុងរោងចក្រកាត់ដេរ ក្នុងនោះមានការផ្តួចផ្តើមគំនិតរៀបចំគម្រោងផែនការ ដើម្បីឱ្យមានសន្តិសុខការងារ និងផ្តល់នូវជម្រើសការងារ បើសិនជាមានកើនឡើងនេះកាត់បន្ថយចំនួន កម្មករ ។ រីឯយុទ្ធសាស្ត្រ ទាំងនោះរួមគ្នា ៖*

- វិធានការរៀបចំដើម្បីគាំពារផ្នែកកាត់ដេរដូចជាលំហូរចូលប្រាក់កម្រៃ ដែលទីបំផុតជួយការពារលក្ខខណ្ឌការងារ និងជួយធានាការងារ ។
- វិធានការដែលរៀបចំដើម្បីបង្កើតឱ្យមានជម្រើសការងារក្នុងរយៈពេលវែង ឧទាហរណ៍ ដូចជា ការបង្កើតឱ្យមានមូលដ្ឋានឧស្សាហកម្មចម្រុះ និងតំបន់ឧស្សាហកម្មកែច្នៃនាំចេញ (Export Processing Zones)
- គំនិតផ្តួចផ្តើមរៀបចំដើម្បីជួយគាំទ្រកម្មការិនីនូវជំនាញ និងគាំទ្រឱ្យមានការបង្កើតឬទទួលបាន នូវការងារជម្រើសនៅក្នុងរយៈពេលខ្លី ។
- គំនិតផ្តួចផ្តើមរៀបចំដើម្បីផ្តល់ការគាំពារសង្គមកិច្ចនៅក្នុងរយៈពេលខ្លី គឺជួយស្ត្រីទាំងនោះឱ្យអាចឆ្លងផុតពីអន្តរកាល ដែលឈានចូលទៅរកពាណិជ្ជសេរីភាវូបនីយកម្ម ។

### ៤.១ វិធានការរៀបចំដើម្បីគាំពារផ្នែកកាត់ដេរ និង ដើម្បីធ្វើឱ្យមានមូលដ្ឋានឧស្សាហកម្មចម្រុះ ៖

នៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកនូវគំនិតផ្តួចផ្តើមដ៏សមរម្យមួយ ដោយរៀបចំគម្រោង ដើម្បីគាំពារផ្នែកកាត់ដេរ និងលើកទឹកចិត្តឱ្យមានការបន្ត និង មានវិនិយោគទុនថ្មី នៅក្នុងឧស្សាហកម្មកាត់ដេរប្រទេសកម្ពុជា។ នៅក្នុងការវិភាគ ស្តីពីការគំរាមកំហែងទៅលើឧស្សាហកម្មកាត់ដេរ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានបញ្ជាក់ថា ប្រទេសចិន ឥណ្ឌា និងប៉ាគីស្ថាន ហាក់ដូចជា "អ្នកឈ្នះ " នៅក្នុងការដាក់ទុនជាកម្រិតសាកលភាវូបនីយកម្ម។ រីឯប្រទេសនានា ក៏ដូចជាប្រទេសកម្ពុជាដែរ ក៏ធ្លាប់មានបទពិសោធន៍គំរាមកំហែង ចំពោះភាគហ៊ុនទីផ្សាររបស់ខ្លួន ។ ពីព្រោះថា ប្រទេសកម្ពុជាហាក់ដូចជាមិនអាចប្រកួតប្រជែងទៅលើតម្លៃនេះតែម្នាក់ឯងបានទេ ។ វិធានការដទៃៗទៀត បានលើកឡើង ដែលក្នុងនោះ រួមមានការដាក់ឧស្សាហកម្មជាអ្នកទទួលខុសត្រូវខាងសង្គមកិច្ច។ ដោយផ្អែកទៅលើការផ្តល់យោបល់ពីម្ចាស់មូលនិធិ ដូចជាធនាគារពិភពលោក ( World Bank ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រាជរដ្ឋាភិបាលបានសម្រេចចិត្តទទួលយកនូវវិធានការពង្រីកនូវវិនិយោគវិស័យឯកជន ដើម្បីធានាឱ្យបានថាឧស្សាហកម្មកាត់ដេរ អាចស្ថិតក្នុងការប្រកួតប្រជែង ហើយនិងបង្កើតបាននូវការងារជម្រើស ។ វិធានការទាំងនោះរួមមាន ៖

• **ការកាត់បន្ថយថ្លៃដើមនិងបង្កើនឡើងនូវអត្រានៃការផលិត ៖** រាជរដ្ឋាភិបាលបានសម្រេចចិត្ត ដើម្បីអនុវត្តនូវផែនការ១២ចំណុច ដើម្បីគាំទ្រវិនិយោគទុនផ្នែកឯកជន នៅក្នុងប្រទេសកម្ពុជា ។ ផែនការនេះ គឺផ្តោតការយកចិត្តទុកដាក់

ជាពិសេសទៅលើការកាត់បន្ថយនូវតម្លៃនៃការធ្វើពាណិជ្ជកម្ម នៅក្នុងប្រទេសកម្ពុជាដែលរាប់បញ្ចូលទាំងតម្លៃខ្ពស់នៃសេវាសាធារណៈ ដូចជាអគ្គីសនី ដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ ការចំណាយពេលវេលាយូរ ឧទាហរណ៍ដូចជាការធ្វើពាណិជ្ជកម្ម ដែលគេតម្រូវឱ្យបង់ពន្ធជាសំណូកក្រៅផ្លូវការខ្ពស់ សំរាប់ការនាំចេញ និងនាំចូល ។ រាជរដ្ឋាភិបាល នឹងផ្តួចផ្តើមបើកកិច្ចពិភាក្សា តាមរយៈសមាគម អាស៊ាន (SEAN) ដូចជាបទល្មើសពន្ធដារដើម្បីឱ្យក្រុមវិនិយោគទុន អាចមានទំនាក់ទំនងជាមួយអ្នកទិញ និងផ្តល់ការលើកទឹកចិត្តដល់អ្នកវិនិយោគទុនក្នុងតំបន់ ។

• **ការជំរុញផ្នែកសំលៀកបំពាក់កម្ពុជា ឱ្យក្លាយទៅជាឧស្សាហកម្មប្រកបដោយភាពទទួលខុសត្រូវផ្នែកសង្គមកិច្ច** ការរៀបចំផ្នែកកាត់ដេរឱ្យរួចផុតពីការរំលោភលក្ខខណ្ឌការងារ ការផ្តល់ប្រាក់ឈ្នួលទាប និងការប្រើប្រាស់កម្លាំងពលកម្មកុមារ និងជំរុញឱ្យផ្នែកកាត់ដេរអនុវត្តទៅតាមបទដ្ឋានពលកម្មអន្តរជាតិ វានឹងជួយទាក់ទាញវិនិយោគទុន ហើយនិងការគាំទ្រពីអ្នកទិញធំៗ ដូចជា ណៃគី និង ហ្គេប (Nike and Gap) ។ ថ្មីៗនេះ ធនាគារពិភពលោកកំពុងតែ ធ្វើការស្រាវជ្រាវថា តើមានចំនួនអ្នកទិញអន្តរជាតិចំនួនប៉ុន្មាន ដែលយកចិត្តទុកដាក់ទៅលើការការពារសិទ្ធិកម្មករ ក្នុងគោលបំណងផ្តល់ព័ត៌មានអំពីការបង្កើតយុទ្ធនាការ ដើម្បីឱ្យមានគុណភាពបទដ្ឋានពលកម្ម (Salinger 2004:20) ។ ការបង្កើតឱ្យមានជាគុណភាពបទដ្ឋានពលកម្ម នេះឡើង វានឹងពញ្ញាក់ស្មារតីដល់អ្នកគ្រប់គ្រងនិងបុគ្គលិករោងចក្រ ហើយវានឹងតម្រូវឱ្យមានទាំងការអភិវឌ្ឍន៍ជំនាញ និងការផ្លាស់ប្តូរឥរិយបថផងដែរ ។

• **ការកែលម្អនូវផលិតភាព និងជំនាញនៅក្នុងបរិស្ថានរោងចក្រ** បច្ចុប្បន្ននេះ អង្គការពលកម្មអន្តរជាតិ (ILO) កំពុងតែអនុវត្តការផ្តួចផ្តើមសាកល្បងមួយ ជាមួយនឹងអ្នកចាត់ចែង និងអ្នកគ្រប់គ្រង នៅក្នុងរោងចក្រ ចំនួន១៤ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវការអនុវត្តន៍ ហើយនិងចង្អុលបង្ហាញអំពីទំនាក់ទំនង រវាងការធ្វើឱ្យប្រសើរឡើង នូវការគោរពគោលការណ៍ និងការបង្កើនឡើងនូវផលិតភាព ។ គម្រោង ផ្តួចផ្តើមសាកល្បងនេះ ពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលឱ្យមានការអនុវត្តន៍វិស័យឧស្សាហកម្មបានល្អបង្កើនទំនាក់ទំនងរវាងអ្នកគ្រប់គ្រង និងបុគ្គលិក ដំណើរការការងារ និងការយល់ដឹងអំពីសិទ្ធិកម្មករ ការផ្តួចផ្តើមដទៃៗទៀត ដែលផ្តោតទៅលើការគ្រប់គ្រងរោងចក្រ ក្នុងនោះមានមជ្ឈមណ្ឌលបណ្តុះបណ្តាលកាត់ដេរកម្ពុជា ដែលឧបត្ថម្ភថវិកា ដោយអង្គការចាយកា (JICA) ។ មជ្ឈមណ្ឌលនេះ ផ្តោតសំខាន់ទៅលើការគ្រប់គ្រង ប្រតិបត្តិការការងារឱ្យមានភាពរលូន ការរៀបចំគម្រោងផលិត ព្រមទាំងការអប់រំកម្មករ (Salinger 2004:18) ។

• **ឧស្សាហកម្មកម្ពុជាចម្រុះ** : បន្ថែមទៅលើវិធានការដែលបានរៀបចំគម្រោងជាពិសេស ដើម្បីគាំពារផ្នែកកាត់ដេរ រាជរដ្ឋាភិបាលកម្ពុជា ហើយនឹងម្ចាស់មូលនិធិ បានព្រមព្រៀងថា វាជាការចាំបាច់ណាស់ ដើម្បីធ្វើឱ្យមានឧស្សាហកម្មចម្រុះ នៅក្នុងប្រទេសកម្ពុជា ជាពិសេស ផ្តោតទៅលើកសិឧស្សាហកម្ម ។ នៅក្នុងផ្នែកកាត់ដេរណាមួយ ដែលមិនអាចរីកចម្រើនទៅបាន ដោយសារតែមានបទបញ្ហាហួសហេតុពេក កសិឧស្សាហកម្ម នឹងទទួលការលំបាក ដោយសារការខ្វះខាត នូវវិទ្យាស្ថានសាធារណៈ និងទីផ្សារក្នុងស្រុក ។ វិធានការដែលគេរៀបចំដើម្បីគាំទ្រ អែសអឹមអ៊ី (SME) គឺតម្រូវឱ្យគាំទ្រទៅលើកសិឧស្សាហកម្ម ហើយនិងផ្តល់នូវការឈានទៅដល់ទីផ្សារ និងឥណទានសំរាប់ (SME) ជនបទ ។

• **ការទាក់ទាញវិនិយោគទុនមកកម្ពុជា តាមរយៈការបង្កើតតំបន់កែច្នៃនាំចេញ :** តំបន់កែច្នៃនាំចេញបានដាក់នៅក្នុងរបៀបវារៈ ដោយមានគម្រោងបង្កើតតំបន់ទាំងនេះ នៅខេត្តកោះកុង ប៉ោយប៉ែត ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ (ការសម្ភាសន៍ជាមួយនឹងមន្ត្រី UNDP ) ។ សំណង់មួយចំនួនបានសាងសងហើយនៅខេត្តកោះកុង ប៉ុន្តែមិនទាន់បានដំណើរការនៅឡើយ ។ ឥឡូវនេះ រដ្ឋាភិបាលត្រូវបានគេ ឱ្យយោបល់ថា ការបង្កើតនូវតំបន់កែច្នៃនាំចេញអាចដំណើរការទៅមុខបាន លុះត្រាតែមានច្បាប់ សំរាប់ការបង្កើតតំបន់នេះ ដែលត្រូវអនុម័តនៅឆ្នាំ២០០៤ ជាមុនសិន ដោយមានការរៀបចំច្បាប់ឱ្យមានការជួយតំបន់កែច្នៃនាំចេញនេះ មានសក្តានុពល ក្នុងការបង្កើតការងារ តាមរយៈឧស្សាហកម្មធុនស្រាល ដូចជារោងចក្រវាយនភណ្ឌ សំរាប់ប្រជាជនកម្ពុជា ជាពិសេសសំរាប់ស្ត្រី ។ តំបន់កែច្នៃនេះអាចផ្តល់ជម្រើសការងារសំរាប់ស្ត្រីដែលធ្លាប់មានបទពិសោធន៍ នៅលើផ្នែកកាត់ដេរ នៅក្នុងទីក្រុងភ្នំពេញ ។

• **ការវិយោគទុនក្នុងការអភិវឌ្ឍន៍ *(SME)* :** ដូចមានញ្ជាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាល ការអភិវឌ្ឍន៍ SME គឺជាវិស័យអាទិភាពសំរាប់ប្រទេសកម្ពុជា។ ការផ្តួចផ្តើមនៅក្នុងវិស័យនេះ រាប់បញ្ចូលទាំងសកម្មភាពម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការគាំទ្រវគ្គបណ្តុះបណ្តាលជំនាញ និងឥណទានខ្នាតតូច ដើម្បីឱ្យបានចូលរួមក្នុង SME ។ ឧទាហរណ៍ កម្មវិធីសម្របសម្រួល ការអភិវឌ្ឍន៍វិស័យឯកជនទន្លេមេគង្គ គាំទ្រការអភិវឌ្ឍន៍ SME តាមរយៈការផ្តល់ថវិកា និងជំនាញសំរាប់ការរៀបចំមុខជំនួញថ្មី ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ថវិកាគាំទ្រ ដើម្បីបង្កើនសមត្ថភាពដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដោយផ្តល់វគ្គបណ្តុះបណ្តាល់ជំនាញពាណិជ្ជកម្ម ហើយនិងឥណទានខ្នាតតូចចំពោះស្ត្រីនៅទីជនបទ។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនកំពុងតែចរចាជាមួយនឹងអង្គការអភិវឌ្ឍន៍អាស៊ី ដើម្បីស្នើសុំឱ្យផ្តល់ថវិកាបន្ថែមទៀត ដើម្បី សាងសង់អាគារថ្មី ហើយផ្តល់វគ្គបណ្តុះបណ្តាល និងគាំទ្រដល់ស្ត្រី។

• **ការផ្តោតទៅលើវគ្គបណ្តុះបណ្តាលនិងការអប់រំវិជ្ជាជីវៈ** ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទើបបង្កើតថ្មីៗនេះ មានតួនាទីធ្វើការបង្កើននូវកំរិតជំនាញដល់ប្រជាជនកម្ពុជា ហើយនិងរៀបចំវគ្គបណ្តុះបណ្តាលដែលត្រូវទៅនឹងសេចក្តីត្រូវការរបស់និយោជក ។ មជ្ឈមណ្ឌលនៅក្នុង១៦ខេត្ត នឹងពង្រីកការផ្តល់វគ្គខ្លីៗ និងចំណេះដឹងនៃការប្រើឥណទានដែលគេទទួលស្គាល់ (accredited qualification) រួមបញ្ចូលទាំងវគ្គបណ្តុះបណ្តាលធ្វើឱ្យប្រសើរឡើងនូវជំនាញពាណិជ្ជកម្ម ហើយ អង្គការពលកម្មអន្តរជាតិ នឹងផ្សព្វផ្សាយរបាយការណ៍ ក្នុងពេលឆាប់ៗនេះ ស្តីពីឧបសគ្គដែលរារាំងក្នុងការផ្តល់ការអប់រំវិជ្ជាជីវៈសំរាប់ស្ត្រី នៅក្នុងប្រទេសកម្ពុជា។

### ៤.២ យុទ្ធសាស្ត្រដែលគេលើកឡើង ដើម្បីឱ្យមានការងារជម្រើសសំរាប់ស្ត្រីនៅក្នុងផ្នែកកាត់ដេរ និង ជួយស្ត្រីក្នុងរយៈពេលអន្តរកាល :

ទីភ្នាក់ងារមួយចំនួនកំពុងតែផ្តោតទៅលើរបៀបដែលល្អប្រសើរ ដើម្បីជួយកាត់បន្ថយឥទ្ធិពលនៃផលប៉ះពាល់ ក្នុងការចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការបញ្ចប់នូវកិច្ចព្រមព្រៀងអនុគ្រោះបំផុត(MFA) នៅក្នុងផ្នែកកាត់ដេរ

។ សកម្មភាពបច្ចុប្បន្ននេះរួមមាន :

ធនាគារអភិវឌ្ឍន៍អាស៊ីរៀបចំគម្រោងជំនួយបច្ចេកទេស ដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារកម្មការិនីរោងចក្រពីការធ្លាក់ទៅក្នុងភាពក្រីក្រ ។ ជំនួយបច្ចេកទេស ធ្វើការសហការជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន។ ជំនួយបច្ចេកទេស មានកម្មវិធីពីរសំខាន់ ទី១-ផ្តោតទៅលើច្បាប់ការងារ និងលក្ខខណ្ឌការងារ ទី២-ផ្តោតទៅលើកម្មវិធីសាកល្បង ដើម្បីគាំទ្រកម្មការិនីក្នុងរយៈពេលអន្តរកាល ។កម្មវិធីទី១ រួមមានការរៀបចំគំរូ សេដ្ឋកិច្ចនៃឥទ្ធិពលដែលធ្វើឱ្យមានការប្រែប្រួលនៅក្នុងរោងចក្រ។ កម្មវិធីសាកល្បងពាក់ព័ន្ធទៅនឹង (១)ការអភិវឌ្ឍន៍ជំនាញដើម្បីឱ្យមានជម្រើសការងារនៅក្នុងវិស័យទេសចរណ៍ ព័ត៌មានវិទ្យា សេវាកម្ម និងកសិឧស្សាហកម្ម (២)ការបង្កើតក្រុមជួយខ្លួនឯងដើម្បីលើកទឹកចិត្តស្ត្រីឱ្យសន្សំប្រាក់ (៣) និងកម្មវិធីអភិវឌ្ឍន៍សហគ្រិន។ ការកសាងសមត្ថភាព សំរាប់ភ្នាក់ងារដែលពាក់ព័ន្ធក៏មានបញ្ចូលនៅក្នុងជំនួយបច្ចេកទេសដែរ ។ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏កំពុងតែផ្តល់ថវិកាសំរាប់វគ្គបណ្តុះបណ្តាលចំពោះអ្នកគ្រប់គ្រង ដែលធ្វើការលើវិស័យសិទ្ធិមនុស្សនៅក្នុង រោងចក្រ ដោយផ្តោតសំខាន់ទៅលើការធ្វើឱ្យប្រសើរឡើងនូវការគោរពលក្ខខ័ណ្ឌការងារក្នុងភាពជាដៃគូជា មួយនឹងសមាគមផលិតករសំលៀកបំពាក់កម្ពុជាកម្ពុជា (GMAC) ។

ក្នុងនោះមានកម្មវិធីសាកល្បង ដែលរៀបចំដោយក្រុមសម្របសម្រួលបណ្តុះបណ្តាលពលកម្មកម្ពុជា នៅក្នុងរោងចក្រចំនួន៤ ដែលមានប្រធានបទ ស្តីពីការគ្រប់គ្រងនិងវគ្គបណ្តុះបណ្តាលកម្លាំងពលកម្ម ។ចំណែកឯវគ្គបណ្តុះបណ្តាលបុគ្គលិក មានរួមបញ្ចូលព្រមទាំងច្បាប់ការងារ ក្រមសីលធម៌នៃការរកស៊ីកំប៉ិកកុំប៉ុក (retailer codes of conduct) ជំនាញចរចានិងទំនាក់ទំនងសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី (Salinger 2004:18) ។

កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ (WAC) ជាអង្គការមួយដែលពីមុនផ្តល់ថវិកាដោយអង្គការអុកស្វាម ហុងកុង ធ្វើការជាមួយនឹងស្ត្រីក្នុងផ្នែកកាត់ដេរនៅក្នុងកំរិតមូលដ្ឋាន ( grassroots level) ។ កម្មវិធីវិស័យកាត់ដេររបស់ WAC គឺ ផ្តោតទៅលើការបង្កើនការយល់ដឹង ការអប់រំ និងការគាំទ្រ ហើយនិងការតស៊ូមតិ សំរាប់កម្មការិនី។ WAC បានបង្កើតបណ្តាញស្ត្រីនៅក្នុងរោងចក្រកាត់ដេរជាច្រើន (កន្លែងបី three drop) ដែលស្ត្រីអាចមកសុំយោបល់និងការគាំទ្រ)និងថ្មីៗនេះបានធ្វើការផ្តល់ព័ត៌មាន និងអប់រំស្ត្រីអំពីសិទ្ធិនិងឥទ្ធិពល ដែលមានសក្តានុពលពីពាណិជ្ជសេរីភាវូបនីយកម្ម ។WAC គាំទ្រយ៉ាងខ្លាំងលើចលនា ដើម្បីដាក់ផ្លាកកម្ពុជា ហើយនិងរោងចក្រកាត់ដេរជាអ្នកទទួលខុសត្រូវលើសង្គមកិច្ច និងអនុវត្ត ទៅតាមបទដ្ឋានពលកម្មអន្តរជាតិ ដើម្បីធានាបាននូវអនាគតនៃរោងចក្រ ការពារសិទ្ធិកម្មករ ហើយនិងធ្វើការស្រាវជ្រាវ ជម្រើសយ៉ាងសកម្មដើម្បីភាពជាម្ចាស់ការរួម (cooperative ownership)នៃរោងចក្រ។

ទោះបីជាមិនបានផ្តោតទៅលើសិទ្ធិកម្មករក៏ដោយ ក៏អង្គការឃែរកម្ពុជាកំពុងតែធ្វើការយ៉ាងសកម្ម ជាមួយរោងចក្រកាត់ដេរចំនួន២៥ ដើម្បីធ្វើឱ្យប្រសើរឡើង នូវសុខភាពបន្តពូជនិងផ្លូវភេទរបស់កម្មករកាត់ដេរ ។ កម្មវិធីនោះមានការអប់រំក្រុមយុវជន ជំនាញបំនិន និងការផ្តល់ព័ត៌មានអំពីសេវាកម្មសុខភាព ។ បន្ថែមទៅលើការផ្តួចផ្តើមបច្ចុប្បន្នភ្នាក់ងារមួយចំនួន កំពុងតែធ្វើផែនការរៀបចំអន្តរាគមន៍ផ្សេងៗទៀត ដើម្បីដោះស្រាយឥទ្ធិពលនៃពាណិជ្ជសេរីភាវូបនីយកម្ម ដោយធ្វើឱ្យ

ប្រសើរឡើងនូវលក្ខខណ្ឌការងារ និងគាំទ្រស្ត្រីឱ្យឆ្លងផុត ពីរយៈពេលអន្តរកាល ។ ប្រហែលជាមានការផ្តួចផ្តើមដែលបានធ្វើផែនការរួចហើយ ដែលពុំបានរៀបរាប់នៅទីនេះ ប៉ុន្តែយ៉ាងណាក៏ដោយ ឯកសារស្រាវជ្រាវនេះ បានរកឃើញនូវសកម្មភាពដូចខាងក្រោម :

ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជនបានបញ្ជាក់ថា ការទប់ស្កាត់កម្មការិនីរោងចក្រ ពីការធ្លាក់ចូល ទៅក្នុងភាពក្រីក្រ ជាធាតុមួយដ៏សំខាន់នៃផែនការ៥ឆ្នាំរបស់ក្រសួង ដែលបច្ចុប្បន្ននេះ កំពុងតែរៀបចំឡើង ក្រោមការដឹកនាំរបស់បណ្ឌិតផាវី (សម្ភាសន៍ជាមួយនឹងក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន) ។ ជម្រើសសំរាប់ ពង្រីកជំនួយការបច្ចេកទេសដែលកំពុងគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីគាំទ្រកម្មការិនីរោងចក្រ និងដើម្បីពង្រីកតួនាទីរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីត្រូវបានគេកំពុង តែពិភាក្សាជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី ។

ថ្មីៗនេះ ទីភ្នាក់ងារអភិវឌ្ឍន៍ជំនួយសហរដ្ឋអាមេរិក (USAID) កំពុងតែពិចារណាលើការផ្តល់ថវិកាសំរាប់គំនិតផ្តួចផ្តើមរួមគ្នាពីរ ។ ការផ្តួចផ្តើមទី១ ត្រូវបានគេរៀបចំឡើងដើម្បីប៉ាន់ប្រមាណទៅលើ សេចក្តីត្រូវការជំនាញរបស់កម្មការិនីរោងចក្របច្ចុប្បន្ន ហើយនិងធ្វើផែនការ ផ្តល់វគ្គបណ្តុះបណ្តាលថ្មីៗ ដោយផ្តោតការយកចិត្តទុកដាក់ ទៅលើការបង្កើតយុទ្ធសាស្ត្រ ដើម្បីបង្កើនជំនាញកម្មករដែលមានស្រាប់ ។ ទីភ្នាក់ងារអភិវឌ្ឍន៍ជំនួយសហរដ្ឋអាមេរិក ក៏កំពុងតែគិតគូរផងដែរ ទៅលើវិធីដើម្បីបង្កើនការចូលទៅដល់ទីផ្សារពិភពលោកនូវជំនាញកាត់ដេរ ជំនាញវាយនភណ្ឌនិងសរសៃអំបោះដែលគាំទ្រដោយកម្មវិធីមួយ ដោយផ្តោតទៅលើការអភិវឌ្ឍន៍កម្លាំងពលកម្ម ហើយនិងការនាំទៅរកទីផ្សារ (សម្ភាសន៍ជាមួយនឹងទីភ្នាក់ងារអភិវឌ្ឍន៍ជំនួយសហរដ្ឋអាមេរិក ) ។

អង្គការពលកម្មអន្តរជាតិ បានធ្វើផែនការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួនថ្មីៗនេះ ដោយផ្តោតការយកចិត្តទៅលើសិទ្ធិនៅកន្លែងធ្វើការងារ ក្នុងនោះមានការដោះស្រាយបញ្ហា ដូចជាការយាយីផ្លូវភេទ (Sexual harassment) (សម្ភាសន៍ជាមួយនឹងអង្គការពលកម្មអន្តរជាតិ) ។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ មានបំណងធ្វើការប៉ាន់ប្រមាណអំពីឥទ្ធិពលនៃការអភិវឌ្ឍន៍ធនធានមនុស្សទៅលើពាណិជ្ជកម្ម ដែលនឹងពិចារណាទៅលើឥទ្ធិពលនៃយេនឌ័រ និងសង្គមដោយពាណិជ្ជសាកលភាវូបនីយកម្ម (សម្ភាសន៍ជាមួយ នឹងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) ។ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងកំពុងតែពិចារណារកគំនិតផ្តួចផ្តើម ដើម្បីអភិវឌ្ឍន៍ជំនាញកម្លាំងពលកម្ម ហើយនិងចូលរួមចំណែក នៅក្នុងការទទួលខុសត្រូវ សង្គមកិច្ចនៅក្នុងនោះ រួមមានការបន្ថែម ការផ្តល់ថវិកាទៅលើកម្មវិធីត្រួតពិនិត្យរបស់អង្គការពលកម្មអន្តរជាតិ លើសពីឆ្នាំ ២០០៥ ដែលបានកំណត់ ហើយនិងបង្កើតនូវថវិកាលើកទឹកចិត្ត ដើម្បីជំរុញការអភិវឌ្ឍន៍សេវាកម្មគាំទ្រសង្គមកិច្ច ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពកម្មករ (Salinger 2004: 16) ។

## ៤.៣ ព្រំដែនហើយនិងចន្លោះប្រហោងនៅក្នុងការជួយអន្តរាគមន៍

ការពិចារណាប្រកបដោយយុទ្ធសាស្ត្រ វិភាគ និងថាមពល បានធ្វើឡើងដោយរដ្ឋាភិបាល និងភ្នាក់ងារម្ចាស់ជំនួយ ដើម្បីធ្វើផែនការសំរាប់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងឆ្លើយតបទៅនឹងការបញ្ចប់ប្រព័ន្ធកូតា ហើយ ដំណាក់កាលនៃសកម្មភាពគ្រោងទុកមួយចំនួនទៀតកំពុងតែពិភាក្សា ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ គ្រោះថ្នាក់និងឱកាស មួយចំនួន ទំនងដូចជាមិនអាចដោះស្រាយបានទាំងស្រុង ឱ្យទាន់ពេលវេលានៅឡើយ ។

វិធានការខ្នាតធំដែលរៀបចំឡើងដើម្បី (១)ការពារផ្នែកកាត់ដេរនិងការធ្វើឱ្យមាន មូលដ្ឋានឧស្សាហកម្មចម្រុះដែលតម្រូវឱ្យមានការវិនិយោគរយៈពេលវែង និងការពិចារណាទៅលើឆន្ទៈនយោបាយ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយជោគជ័យ (២) ដើម្បីការពារការងារស្ត្រី នៅក្នុងរយៈពេលអន្តរកាល ។ នៅក្នុងសុន្ទរកថាថ្មីៗ រដ្ឋមន្ត្រីក្រសួងពាណិជកម្មបានទទួលស្គាល់ថាយុទ្ធសាស្ត្រ ដែលបានលើកឡើងដូចបានពិភាក្សា ខាងលើហាក់បីដូចជា "តូចបំផុត យឺតបំផុត " សំរាប់ផ្នែកកាត់ដេរ បើប្រៀបធៀប ទៅនឹងប្រទេសដទៃៗទៀត ដែលគេបានឆ្លងកាត់ការ រៀបចំការងារនេះ រហូតដល់ទៅ ៥-៨ ឆ្នាំមកហើយ ។ បើសិនជាយុទ្ធសាស្ត្រស្នើឡើងនេះ បានទទួលយក ដោយរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយហើយពុំ បានអនុវត្តនោះទេ ផ្លូវមួយដ៏សំខាន់បើកចំហទៅរកការប្រកួតប្រជែងជានិរន្តរ៍ទៅលើ វិស័យឧស្សាហកម្មគ្មានអ្វីក្រៅអំពីការកាត់ បន្ថយប្រាក់ឈ្នួលនិងការរឹតបន្តឹងលក្ខខណ្ឌការងារ ។

នៅពេលដែលមានការប្តេជ្ញាចិត្តច្បាស់លាស់ពីរាជរដ្ឋាភិបាល ទៅលើគំនិតផ្តួចផ្តើមពាណិជ្ជកម្មសំរាប់សហគ្រិនខ្នាតតូចនិងមធ្យម ហើយនិងកិច្ចប្រឹងប្រែង ដោយយកចិត្តទុកដាក់ពីអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងវិស័យនេះ ការវិនិយោគទុនធំៗ រយៈពេលវែងនៅក្នុងការអភិវឌ្ឍន៍ សហគ្រិនខ្នាតតូចនិងមធ្យម ហើយនិងការផ្តោតដ៏ធំធេងទៅលើសេចក្តីត្រូវការរបស់ស្ត្រីនៅក្នុងការផ្តួចផ្តើមនេះ គឺជាការចាំបាច់ ។ លើសពីនេះទៅទៀត ដោយហេតុថាចំនួនស្ត្រីច្រើនជាងចំនួនបុរសនៅក្នុងមុខជំនួញតូចៗដូចជា ការរកស៊ីលក់រាយ (retail) វគ្គបណ្តុះបណ្តាលជំនាញពិសេស ហិរញ្ញវត្ថុខ្នាតតូច ហើយនិងការអភិវឌ្ឍន៍ជំនាញមុខរបរ ចាំបាច់ត្រូវតែផ្តល់ដល់ស្ត្រីនៅក្នុងសហគ្រាសខ្នាតតូច ។ កម្មវិធីជំនួយបច្ចេកទេស/TA ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការពាក់ព័ន្ធនឹងការធ្វើការពង្រឹងសមត្ថភាពជាមួយនឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីចំនួន៨ ដើម្បីផ្តល់ការអភិវឌ្ឍន៍ ជំនាញឥណទានខ្នាតតូច និងដើម្បីរកទីផ្សារសំរាប់ស្ត្រី ។ ដូចបានកំណត់ចំណាំខាងលើ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនកំពុង តែចរចាជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីពង្រីកជំនួយបច្ចេកទេស និងដើម្បីជួយថវិកា ដល់មជ្ឈមណ្ឌល និងបើកមជ្ឈមណ្ឌលថ្មីក្នុង ការផ្តល់វគ្គបណ្តុះបណ្តាលនិងអប់រំវិជ្ជាជីវៈ ហើយនិងជំនាញអភិវឌ្ឍន៍មុខរបរ ។ ទោះបីយ៉ាងណាក៏ដោយ កម្មវិធីរបស់ជាតិ ដែលផ្តល់មជ្ឈមណ្ឌលនៅតាមខេត្ត ជាជាងការផ្តួចផ្តើមកម្មវិធីសាកល្បងគឺជាតម្រូវការមួយដ៏ចាំបាច់ ។ លើសពីនេះទៅទៀត ការផ្តល់ឥណទាន ខ្នាតតូច ដោយមានការប្រាក់ទាបគឺជាលក្ខណៈមួយសំខាន់បំផុត សំរាប់ជួយស្ត្រីនៅ ក្នុងសហគ្រាសខ្នាតតូច និងមធ្យម( ធនាគារអភិវឌ្ឍន៍ ២០០១:៤៩) ។

បទពិសោធន៍នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃៗទៀត បានលើកឡើងថា ទោះបីជាតំបន់កែច្នៃ នាំចេញពេលខ្លះ

មានផលប្រយោជន៍យ៉ាងណាក៏ដោយ ក៏តំបន់ទាំងនោះមិនអាចធ្វើឱ្យមានជោគជ័យ ស្របទៅតាម គោលបំណងដែលបានព្រាងនៅក្នុងយុទ្ធសាស្ត្រពាណិជ្ជកម្មគាំទ្រជនក្រីក្រ ហើយនិងយុទ្ធសាស្ត្រ ជាតិកាត់បន្ថយភាពក្រីក្រនោះបានឡើយ (ធនាគារ ពិភពលោក ២០០៤ និង អង្គការអុកស្វាម អន្តរជាតិ ២០០៤) ។ នៅក្នុងការប៉ាន់ប្រមាណលើផលប៉ះពាល់កិច្ចការសង្គមថ្មីៗនេះ ទៅលើគម្រោងបង្កើតតំបន់ឧស្សាហកម្មកែច្នៃ នៅក្នុងខេត្តកោះកុងកម្មវិធី អភិវឌ្ឍន៍អង្គការសហប្រជាជាតិបានរកឃើញថា នៅពេលដែលតំបន់កែច្នៃនាំចេញទាំងនោះ អាចផ្តល់ការងារជាសក្តានុពលដល់ស្ត្រីជំទង់ៗ ទាំងនោះ ក្នុងមូលដ្ឋានរហូត ទៅដល់៥០០០នាក់ក៏ដោយ ក៏ការងារភាគច្រើន អាចនឹងទទួលបានដោយអ្នកមកពីខាងក្រៅច្រើនជាង ដូចជាអ្នកចំណាកស្រុកនៅក្នុង ប្រទេសកម្ពុជា ឬក៏ទៅរកការងារធ្វើនៅប្រទេសថៃជាដើម ។ ជាលទ្ធផលតំបន់ទាំងនេះ នឹងផ្តល់ឥទ្ធិពលសង្គមកិច្ចនិងសេដ្ឋកិច្ចល្អ ដល់ ប្រជាជនដែលរស់នៅក្នុងតំបន់នោះ ។ ប្រសិនបើស្ត្រីជំទង់ៗ ទាំងនោះ បានទទួលផលប្រយោជន៍អំពីការបង្កើតតំបន់នេះ គេគួរតែដោះស្រាយបញ្ហា ទាក់ទងទៅនឹងការមានជំនាញដ៏តិចតួចគួរឱ្យពិចារណា ដែលគេបានរកឃើញដោយសារការ ផ្តល់ ការអប់រំនៅមានកំរិតទាប ចំពោះស្ត្រីជំទង់ៗ នៅតំបន់នោះ (UNDP 2003) ។ តាមការសិក្សាស្រាវជ្រាវរបស់ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បញ្ហាធ្ងន់ធ្ងរ គឺថាតំបន់កែច្នៃនាំចេញនឹងផ្តល់ផលប្រយោជន៍តិចតួចដល់ស្ត្រី ឬក៏ទៅដល់ សេដ្ឋកិច្ចថ្នាក់មូលដ្ឋាន ។ តំបន់កែច្នៃទាំងឡាយនោះ ទំនងដូចជាលើកទឹកចិត្តទាំងអន្តោប្រវេសន៍ក្នុងស្រុក ហើយនិងអន្តោប្រវេសន៍ មកពីប្រទេសដទៃៗ ដែលយើងឃើញថាលទ្ធផលដែលជាឱកាសផ្តល់ ការងារពុំបានទទួលដោយស្ត្រីទាំងនោះទេ ហើយថែមទាំងនាំមកនូវគ្រោះថ្នាក់ ពីការធ្វើអន្តោប្រវេសន៍ ទៀតផង ។ បើសិនជាតំបន់ឧស្សាហកម្ម កែច្នៃនៅតែបន្ត គេចាំបាច់ត្រូវតែផ្តល់ ការអភិវឌ្ឍន៍ជំនាញ និងវិធានការ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់អាក្រក់ ដល់សង្គម និងបរិស្ថាន ។

ការផ្តួចផ្តើមគំនិត ដែលគេគ្រោងឡើងជាពិសេសដើម្បីជួយគាំទ្រដល់កម្មការិនីកាត់ដេរនោះ ទំនងជាអន្តរាគមន៍ទ្រង់ទ្រាយតូចឬក៏ជាអន្តរាគមន៍សាកល្បងតែប៉ុណ្ណោះ ។ គេមិនអាចមានសមត្ថភាព ដើម្បីគាំទ្រស្ត្រី ១០០ ០០០ នាក់ ដែលប្រហែលនឹងទទួលផលប៉ះពាល់នោះទេ ។ ឧទាហរណ៍ ការផ្តួចផ្តើមសាកល្បង របស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលគម្រោងនឹងចាប់ ផ្តើមក្នុងឆ្នាំ២០០៥ ជាមួយនឹងលទ្ធផល ដែលរកឃើញថា ការផ្តល់ថវិកាទៅលើការផ្តួចផ្តើមទ្រង់ទ្រាយធំ ដែលគាំទ្រទៅនឹងចំនួន ដ៏ច្រើននៃស្ត្រី មិនអាចធ្វើបាន នៅពេលនេះឡើយ ។ ការចំណាយទៅលើសកម្មភាពបែបនេះទំនងជានឹងត្រូវបានគេពិចារណា ។

ដូចបានកត់សម្គាល់នៅក្នុងឯកសារកម្មវិធីជំនួយបច្ចេកទេស ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី គម្លាតសំខាន់ពីរក្នុងពេលបច្ចុប្បន្ននេះ ទំនងជាជួយការពារកិច្ចការសង្គម ដែលអាចជួយស្ត្រីឱ្យមានជីវភាពអាចឆ្លងផុតពីរយៈពេលអន្តរកាល ។ ចំណែកឯការអភិវឌ្ឍន៍ជំនាញដែលអាចជួយស្ត្រីមួយចំនួន ដើម្បីទទួលយកឱកាស ដែលមាននៅក្នុងរោងចក្រកាត់ ដេរ ហើយដើម្បីអភិវឌ្ឍន៍ជំនាញផ្លូវការ និងជំនាញអាចនាំស្ត្រីទៅរកការងារនៅកន្លែងផ្សេងបាន (transferable skill) ។

វិធានការគាំពារសង្គមកិច្ច គឺសំខាន់ណាស់ដើម្បីជួយស្ត្រីឱ្យឆ្លងផុត ពីរយៈពេលអន្តរកាល ។ កម្មវិធីជំនួយបច្ចេកទេស

ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីគាំទ្រស្ត្រីនៅក្នុងផ្នែកកាត់ដេររបស់ប្រទេស បឹងក្លាដេស តាមរយៈពាណិជ្ជកម្មសេរីភាវូបនីយកម្ម កំណត់នូវវិធានការសំរាប់បញ្ចូល នៅក្នុងការផ្តួចផ្តើម កម្មវិធីសាកល្បង ដូចខាងក្រោម :

- គាំទ្រស្ត្រីដែលត្រូវគេកាត់បន្ថយពីការងារ ដើម្បីអាចឱ្យរកចំណូលបាន ឧទាហរណ៍ ដូចជាការធ្វើជំនួញខ្លួនឯង ការបង្កើនសហគ្រិនខ្នាតតូច និងដើម្បីជួយធ្វើការទំនាក់ទំនងទៅនឹងសហគ្រិនទាំងឡាយ ដែលមានបំណង ជួលស្ត្រីធ្វើការបន្ទាប់ ពីពួកគេបានទទួលបានវគ្គបណ្តុះបណ្តាល ជំនាញថ្មីៗទៀតហើយ ។
- ផ្សារភ្ជាប់ស្ត្រីទៅនឹងឱកាសការងារ ឧទាហរណ៍តាមរយៈប្រព័ន្ធព័តិមានការងារ ដែលរៀបចំដោយ សមាគមពាណិជ្ជកម្មក្នុងស្រុកដែលមានបណ្តាញល្អៗ ។
- ផ្តល់ការគាំទ្រទីជម្រកដោយពង្រីកនូវកម្មវិធី ដែលមានស្រាប់កំពុងដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ជម្រក និងម្ហូបអាហារក្នុងពេលទទួលវគ្គបណ្តុះបណ្តាលជំនាញថ្មី ។
- ធានារ៉ាប់រងជាក្រុម ឬខ្នាតតូច ហើយនិងថវិកាសន្សំដើម្បីគាំទ្រស្ត្រីឱ្យឆ្លងផុតពីអន្តរកាល ទៅដល់ការទទួលការងារ ( ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៤ b ) ។

ដូចបានកំណត់ខាងលើ វិធានការមួយចំនួនកំពុងតែធ្វើតេស្ត ដោយកម្មវិធីសាកល្បងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ យោងទៅតាមព័តិមាន កំពុងសរសេរទទួលបាន អ្វីដែលទំនងជាភ្លេចបញ្ចូល គឺការគាំទ្រឱ្យមានប្រាក់ចំណូល ដើម្បីជួយស្ត្រីបានឆ្លងផុតពីអន្តរកាល ដោយអ្នកទិញឬការរៀបចំ ធ្វើឱ្យស្ត្រីទទួលបាន នូវព័តិមានការងារ ជាអ្នកទិញអ្នកលក់ ដើម្បីឱ្យពួកគេទទួលបានការងារថ្មី និងអភិវឌ្ឍជំនាញក្នុងគោលបំណងធ្វើការនៅក្នុងផ្នែកកាត់ដេរ ហើយឈានទៅដល់តួនាទីប្រកបដោយជំនាញ ប្រសិនបើតួនាទីនេះគេត្រូវការ ។ ការវិនិយោគទ្រង់ទ្រាយធំទៅលើវគ្គបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈដល់មនុស្សពេញវ័យ ហើយនិងការពង្រីកឱកាសអប់រំវិជ្ជាជីវៈសំរាប់ស្ត្រីជាតម្រូវការចាំបាច់ ។

## ការគាំទ្រឱ្យមានប្រាក់ចំណូល និងសេវាកម្មបន្ត

ការគាំទ្រឱ្យមានប្រាក់ចំណូលគឺជាបញ្ហាគន្លឹះមួយដែលមិនត្រូវបានគេយកចិត្តទុកដាក់ពេញទំហឹង ។សព្វថ្ងៃនេះជំនាញ និងសិទ្ធិនៅកន្លែងធ្វើការងារជាចំណុចមួយសំខាន់ ប៉ុន្តែសមត្ថភាពដើម្បីរស់រានមានជីវិត ក្នុងរយៈពេលអន្តរកាលនៃការបាត់បង់ការងារដែលបណ្តាលមកពីការកាត់បន្ថយចំនួនកម្មករដ៏ច្រើននោះ វារឹតតែជាបញ្ហា សំខាន់ទៅទៀត ។ កម្មវិធីសាកល្បងជំនួយបច្ចេកទេស ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីនេះរួមមានក្រុម សន្សំប្រាក់គឺជាវិធានការមួយដែលអាចប្រព្រឹត្តទៅបាន ដើម្បីគាំទ្រឱ្យមានប្រាក់ចំណូល ។លើសពីនេះទៅទៀត ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជនកំពុងតែពិភាក្សាជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីអំពីជម្រើស ដើម្បីពង្រីកសេវាសុវត្ថិភាពសង្គមកិច្ចចំពោះស្ត្រីនៅក្នុងផ្នែកកាត់ដេរ ហើយធ្វើការពិនិត្យលើលទ្ធភាពសេវាសង្គមកិច្ច ។ ប៉ុន្តែកិច្ចការនេះ ត្រូវតែមានការចូលរួមចំណែកពីនិយោជិត និង និយោជក ដោយសារប្រទេសកម្ពុជា ពុំដែលមានវប្បធម៌ ដែលធ្លាប់គាំទ្រការផ្តល់ថវិកា សន្តិសុខសង្គម ទៅឱ្យបុគ្គល ឬពុំមានសមត្ថភាព

ហិរញ្ញវត្ថុ ដើម្បីរៀបចំ ។ ដូច្នេះ ត្រូវតែធ្វើការស្រាវជ្រាវរាវរកជម្រើសផ្សេងៗទៀត ។ យុទ្ធសាស្ត្រ ទីពីរគឺសេវាបញ្ជូនបន្ត ដើម្បីជួយស្ត្រីឱ្យបានចុះឈ្មោះរកការងារធ្វើ នៅពេលដែលគេបាត់បង់ ការងារនិងដើម្បីផ្តល់ព័ត៌ មានទាក់ទងទៅនឹងការងារ ។ នៅពេលដែលស្ត្រីនៅក្នុងផ្នែកកាត់ដេរ មានបណ្តាញក្រៅប្រព័ន្ធនោះ ស្ត្រីទាំងនោះបានឮអំពីរោងចក្រ ដែលជ្រើសរើសកម្មករថ្មី ក្នុងប្រព័ន្ធដែលទាក់ទងនឹង នៃការចុះឈ្មោះនិងព័ត៌មានទាក់ទងទៅនឹងការងារដែលអាចជួយស្ត្រី រកបាននូវការងារថ្មី។ លើស ពីនេះទៅទៀត ការងារនេះនឹងជួយការពារនូវផលវិបាកអវិជ្ជមាន ដែលចេញ ពីការកាត់បន្ថយចំនួនកម្មករ ។ ការប៉ាន់ប្រមាណ ទៅលើជំនាញដែលមានស្រាប់និងទៅលើដំណើរការ នៃការទទួលស្គាល់ជា ផ្លូវការរបស់ស្ត្រីទៅលើជំនាញ និងសមត្ថភាពនឹង ជួយស្ត្រីផងដែរ ដើម្បីទទួលបាននូវការងារថ្មី ។ គេគិតថាមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តថ្មី នឹងមានសមត្ថភាព ដើម្បីប៉ាន់ ប្រមាណវាយតម្លៃទៅលើជំនាញ ដែលមានស្រាប់របស់កម្មករ ហើយនិងអាច ផ្តល់នូវវិញ្ញាបនបត្រនៃជំនាញនេះទៀតផង ។ កម្មវិធីសិក្សា មុនការទទួលស្គាល់ជំនាញ (Recogni-sed Prior Learning) អាចជាកម្មវិធីសាកល្បងមួយ ដែលមានសក្តានុ ពលសំរាប់កម្មកររោងចក្រកាត់ដេរ ដើម្បីជួយពួកគេក្នុងការទទួលបាននូវ ការទទួលស្គាល់ ជាផ្លូវការ លើជំនាញរបស់ពួកគេ ហើយកំណត់បាននូវឱកាសផ្សេងទៀត សំរាប់ការអភិវឌ្ឍន៍ជំនាញនិងបណ្តុះបណ្តាល ។ កម្មវិធីសាកល្បងរបៀបនេះអាច នឹង រៀបចំឡើងក្នុងភាពជាដៃគូជាមួយនឹង អង្គការផ្សេងៗទៀត ដូចជាសមាគមផលិតករសំលៀកបំពាក់កម្ពុជា និងអង្គការ ពលកម្មអន្តរជាតិ ដែលមានបទពិសោធន៍ រួចស្រេចក្នុងការផ្តល់វគ្គបណ្តុះ បណ្តាលដល់កម្មករ ។

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជាអង្គការឃែរកម្ពុជា WAC មានបណ្តាញរបស់ខ្លួនរួចស្រេចនៅក្នុងរោងចក្រ និងជាមួយកម្មការិនីរោងចក្រ ដែលអាចជាការងាយស្រួល ក្នុងការធ្វើឱ្យស្ត្រីទាំងនោះចូលរួម នៅក្នុងការធ្វើផែនការ និងទទួល ព័ត៌មាន អំពីការរៀបចំកម្មវិធីនេះ ។ សេវាកម្មបញ្ជូនបន្តអាចរៀបចំដោយ មានសក្តានុពលក្នុងភាពជាដៃគូ ជាមួយអង្គការ មិនមែនរដ្ឋាភិបាល អង្គការជំនួញផ្សេងៗ ដែលមានបទពិសោធន៍ នៅក្នុងការផ្តល់ការងារ ដល់ក្រុមដែលបាត់បង់ផល ប្រយោជន៍ ។

## ការអភិវឌ្ឍន៍ជំនាញដើម្បីស្ថិតនៅក្នុងរោងចក្រកាត់ដេរ

ការខ្វះនូវការផ្តួចផ្តើមបង្កើនជំនាញ ក្នុងពេលបច្ចុប្បន្ន ដើម្បីជួយឱ្យស្ត្រីអាចធ្វើការនៅក្នុងរោងចក្រ និងដើម្បីអាចរក ប្រាក់ចំណូលបានខ្ពស់ វាជាបញ្ហាមួយគួរឱ្យព្រួយបារម្ភផងដែរ ។ តាមរយៈបទពិសោធន៍ បានចង្អុលបង្ហាញថា នៅពេលដែល តម្រូវឱ្យមានកម្មករជំនាញកើនឡើង ស្ត្រីត្រូវបាត់បង់ឱកាស ពីព្រោះបុរស អាចទទួលការងារនេះបានច្រើនជាង (Catagay 2001, GADC 2002 ) ។ បើសិនជាមានតម្រូវការឱ្យកម្មករ មានជំនាញខ្ពស់ ដើម្បីធ្វើការ នៅក្នុងផ្នែកកាត់ដេរមានការកើន ឡើងមែននោះ ស្ត្រីចាំបាច់ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពមួយដែលអាចទទួលយកផលប្រយោជន៍ពីតម្រូវការនេះ ។

ការស្រាវជ្រាវមួយ ដែលធ្វើឡើងជាមួយនឹង កម្មការិនីរោងចក្រ បានបង្ហាញឥតផ្លាស់ប្តូរថា គេចង់បាននូវជំនាញថ្មីៗ ប៉ុន្តែគេពិបាកនឹងរកប្រភព ហើយនិងពេលវេលាដើម្បីចូលរួម ។ ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់នោះ ការអភិវឌ្ឍន៍ជំនាញ ត្រូវ

តែផ្តល់នូវកន្លែងធ្វើការ (ធនាគារអភិវឌ្ឍន៍អាស៊ី២០០១:៦០) ។ ថ្មីៗនេះគេបានការធ្វើអន្តរាគមន៍ប្រកបដោយជោគជ័យតាមរយៈការផ្តល់ជំនាញ និងវគ្គបណ្តុះបណ្តាល នៅកន្លែងធ្វើការ ឬនៅកន្លែងដែលស្ត្រីទាំងនោះរស់នៅ ដោយសហការជាមួយនឹងអ្នកគ្រប់គ្រងរោងចក្រ ។

ចំណែកឯការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្ត្រីពុំបានបង្ហាញចេញនូវការចាប់អារម្មណ៍ពិសេសណាមួយក្នុងការអភិវឌ្ឍន៍ជំនាញ ដើម្បីទទួលយកផលប្រយោជន៍ពីឱកាសថ្មី ដែលនឹងកើតមានឡើង ពីរោងចក្រកាត់ដេរនោះទេ ។ ការស្រាវជ្រាវដទៃទៀតបានបង្ហាញថា ស្ត្រីមួយចំនួនចាប់អារម្មណ៍ក្នុងការធ្វើការនៅក្នុងរោងចក្រកាត់ដេរ ហើយចង់ទទួលយកនូវផលប្រយោជន៍ពីឱកាសថ្មីនេះផងដែរ ។ វាជាការបំពេញបន្ថែមមួយ ដ៏សំខាន់ទៅលើការផ្តួចផ្តើម អភិវឌ្ឍន៍ជំនាញដទៃៗទៀត ។ ការគាំទ្រនឹងផ្តល់ជំនាញ ដល់ស្ត្រីក្នុងចំនួនដ៏ច្រើន ដើម្បីឱ្យពួកគេត្រឡប់ទៅភូមិកំណើត ដើម្បីរៀបចំមុខរបររបស់ពួកគេ ឬដើម្បីទៅធ្វើការនៅរោងចក្រដទៃ តម្រូវឱ្យមានការបង្កើត នូវឱកាសការងារថ្មី ហើយនិងបង្កើនផលិតផលនិងសេវាកម្ម ទៅតាមតម្រូវការរបស់ទីផ្សារដែលស្ត្រីអាចជួយបំពេញការងារនេះ ។ ការងារនេះមិនអាចធានាថាបានជោគជ័យឡើយ បើសិនជាគេរៀបចំគម្រោងផែនការក្នុងរយៈពេលខ្លី គំនិតផ្តួចផ្តើមដែលលើកឡើងដោយទីភ្នាក់ងារអភិវឌ្ឍន៍ជំនួយសហរដ្ឋអាមេរិកដើម្បីកំណត់នូវសេចក្តីត្រូវការជំនាញរបស់កម្មករនិងដើម្បីបន្ស៊ីជំនាញទាំងនេះទៅនឹងការផ្តល់វគ្គបណ្តុះបណ្តាល គឺជាការចូលរួមចំណែកយ៉ាងសកម្មទៅក្នុងការអភិវឌ្ឍន៍ ។

## ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈសំរាប់ស្ត្រី :

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទើបតែបង្កើតថ្មីៗនេះ មានតួនាទីមួយដើម្បីអភិវឌ្ឍជំនាញកម្លាំងពលកម្ម ក្នុងនោះសំរាប់មនុស្សធំពេញកម្លាំងក្នុងការងារ ។ យុទ្ធសាស្ត្រអប់រំវិជ្ជាជីវៈ ថ្នាក់ជាតិ គឺជាផែនការគន្លឹះ នៅក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រនិងលើកទឹកចិត្ត អ្នកវិនិយោគទុន វិស័យឯកជននៅក្នុងប្រទេសកម្ពុជា ។ តាមរបាយការណ៍យុទ្ធសាស្ត្រវិស័យឯកជន របស់ធនាគារពិភពលោក បានគូសបញ្ជាក់ថា :

*ការផ្តល់ជំនាញបច្ចុប្បន្នគឺមិនបានគ្រប់គ្រាន់ស្របទៅតាមគម្រោងការអភិវឌ្ឍន៍ដែលបានលើកឡើយ ។ ដូច្នេះ ដើម្បីអនុវត្តតាមគម្រោងផែនការនេះឱ្យបានជោគជ័យបាន និងគុណភាពនៃការអប់រំ ត្រូវតែធ្វើឱ្យមានភាពប្រសើរឡើង (ធនាគារពិភពលោក ២០០៤:១០៣) ។*

ទោះបីយ៉ាងណាក៏ដោយ ទិសដៅយុទ្ធសាស្ត្រដ៏ធំ ដែលបានអនុម័តដោយក្រសួងត្រូវតែគាំទ្រ ដោយការផ្តល់សេវាកម្មទូទាំងប្រទេស ហើយផ្តោតជាពិសេសទៅលើស្ត្រីដែលពេញវ័យ ។ តាមរបាយការណ៍ ហិរញ្ញវត្ថុខ្នាតតូចរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បើសិនជាគោលនយោបាយអប់រំគាំទ្រស្ត្រីពេញកម្លាំងក្នុងការងារ វាអាចត្រឹមតែចូលរួមចំណែក ដើម្បីកាត់បន្ថយភាពក្រីក្រតែប៉ុណ្ណោះ ។ ហើយវាមិនអាច ធ្វើឱ្យមានការផ្លាស់ប្តូរក្នុងពេលបច្ចុប្បន្ននោះឡើយ :

*ការផ្តោតទៅលើគោលនយោបាយអប់រំ គឺស្ថិតនៅលើកម្លាំងពលកម្មអនាគត ជាជាងកម្លាំងពលកម្មបច្ចុប្បន្នហើយ លក្ខណៈសំខាន់របស់វាគឺរើសអើង ជាពិសេស ទៅលើស្ត្រីមួយចំនួនធំដែលជាផ្នែកមួយ នៃកម្លាំងពលកម្មដែលមានស្រាប់ (Beresford et al 2004: 170) ។*

ការចូលរួមរបស់ស្ត្រីក្នុងវិស័យអប់រំបានបង្កើតជាកម្រៃគួរឱ្យចាប់អារម្មណ៍ទៅលើវិនិយោគទុន ក្នុងនោះ រួមមានការកើនឡើងនូវការទទួលបានការងារ ដែលមានប្រាក់ឈ្នួល និងប្រាក់ចំណូលដែលមានកំរិតខ្ពស់ ។ ការចូលរួមរបស់ស្ត្រីពេញវ័យនៅក្នុងការអប់រំក៏មានសក្តានុពលផងដែរ ក្នុងការបង្កើននូវវិនិយោគទុន សំរាប់ក្មេងជំនាន់ក្រោយ (រាជរដ្ឋាភិបាល ២០០៣:២០) ។ ប្រជាជនកម្ពុជា ភាគច្រើនទទួលស្គាល់ថា ការផ្តត់ផ្គង់កូនស្រីឱ្យសិក្សារៀនសូត្រ គឺត្រូវការចំណាយខ្ពស់ហើយ គេគិតថា ការចូលសិក្សារបស់កូនស្រី ទទួលបានកម្រៃតិចជាងកូនប្រុស ទោះបីវាផ្ទុយនឹងការពិតក៏ដោយ *(Beresford et al 2004: 44)* ។ បទពិសោធន៍ផ្ទាល់ខ្លួន នៃការទទួលផលប្រយោជន៍ពីការអប់រំសំរាប់ស្ត្រីពេញវ័យជំនាន់បច្ចុប្បន្ន អាចជួយកែប្រែឥរិយាបថប្រពៃណីដែលទុកកូនស្រីមិនឱ្យទៅរៀន ឬក៏ឱ្យគេឈប់មុនរៀន ដើម្បីជួយរកកម្រៃ ប៉ុន្តែ បងប្រុស របស់ពួកគេបែរជាអាចបន្តការសិក្សាបាន ។

ដោយសារថា ថវិកាមួយចំនួនត្រូវបានគេលៃលកជាអាទិភាពសំរាប់ការអប់រំជាមូលដ្ឋាន ការផ្គត់ផ្គង់ ថវិកាសំរាប់ការអប់រំវិជ្ជាជីវៈ វាជាបញ្ហាគន្លឹះ ក្នុងការធានាបានការប្រសើរឡើងនូវការរចេះអាន និងការគិតលេខ (GAD 2002)។ លើសពីនេះទៅទៀត ការរៀបចំមួយដ៏ទូលំទូលាយ ដើម្បីឱ្យស្ត្រីមានឱកាសចូលរួមក្នុងការអប់រំវិជ្ជាជីវៈជាតម្រូវការមួយយ៉ាងចាំបាច់ ។ នេះគឺដោយសារតែការផ្តល់ការអប់រំ មានគោលបំណង ដើម្បីឆ្លើយតបទៅតាមតម្រូវការនៃទីផ្សារ ហើយនិងការកើនឡើងនូវឧស្សាហកម្ម ដែលស្ត្រីប្រាកដជាអាចទទួលបានផលប្រយោជន៍ ពីឱកាសទាំងនេះ។ អង្គការពលកម្មអន្តរជាតិ ហើយក្រសួងការងារនឹងចាប់ផ្តើមធ្វើការស្រាវជ្រាវមួយស្តីពីឧបសគ្គ ដែលរារាំងស្ត្រីក្នុងការទទួលបាននូវការអប់រំវិជ្ជាជីវៈ ហើយគេសង្ឃឹមថា ការស្រាវជ្រាវនេះ នឹងអាចកំណត់បាននូវគន្លឹះអនុសាសន៍សំខាន់ៗ ក្នុងការជួយឱ្យស្ត្រីអាចទទួលបាននូវឱកាសទាំងនេះ កាន់តែប្រសើរឡើង ។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក៏បានគូសបញ្ជាក់ផងដែរថា ការពង្រីកឱកាសបណ្តុះបណ្តាលសំរាប់ស្ត្រី តាមរបៀបទំនើប (non-traditional fields) គឺជាអាទិភាពមួយដ៏ចម្បង ហើយរបៀបនេះ ត្រូវធ្វើឱ្យស្របទៅនឹងស្ថានភាព ហើយលក្ខណៈពិសេស ដើម្បីទាក់ទាញការយកចិត្តទុក ឱ្យបានច្រើនថែមទៀត។

មកទល់បច្ចុប្បន្ននេះ មានការខ្វះខាត នូវការតម្រូវឱ្យមានការរៀបចំការបណ្តុះបណ្តាលដោយនិយោជក និងការខ្វះខាតនូវថ្នាលវប្បធម៌បណ្តុះបណ្តាល ដែលជួយគាំពារការធ្វើវិនិយោគទុន ដើម្បីផ្តល់ជំនាញ ដល់កម្លាំងពលកម្មបច្ចុប្បន្ន (ធនាគារពិភពលោក ២០០៤:២៤) ។ បទពិសោធន៍នៅប្រទេសដទៃ បានបង្ហាញ ឱ្យឃើញថា គេមិនអោចជឿទុកចិត្តទៅលើការដែលថា និយោជកអាចផ្តល់ការអភិវឌ្ឍន៍ជំនាញ និងការបណ្តុះបណ្តាលគ្រប់គ្រាន់ ហើយនយោជកមួយចំនួនទៀត សោតនោះ អាងតែជួលអ្នកដែលមានជំនាញ គ្រប់គ្រាន់ ស្រាប់ពីបរទេស បើសិនជាអ្នកទាំងនោះ ពុំអាចរកបាននៅក្នុងប្រទេស (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ២០០៣:៩) ។ ទោះបីយ៉ាងណាក៏ដោយ នៅពេលដែលប្រទេសកម្ពុជាកំពុងតែឈានទៅរក

ការប្រកួតប្រជែងដោយចំហថែមទៀត ការតម្រូវឱ្យមានកម្លាំងពលកម្មដែលប្រកបដោយជំនាញ ត្រូវតែមានផែនការពង្រីក។ ការផ្តល់វគ្គបណ្តុះបណ្តាលដល់មនុស្សពេញវ័យកម្ពុជា ការផ្តួចផ្តើមសំខាន់ៗជាច្រើន និង កម្មវិធីបណ្តុះបណ្តាលជាច្រើនទៀតដែលម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ដូចជា មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី កំពុងអនុវត្ត បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយឱ្យស្ត្រីយកជំនាញ របស់ពួកគេទៅរកការងារធ្វើបាន។ បើយើងមើលត្រឡប់ទៅក្រោយវិញ ការផ្លាស់ប្តូរ ឥរិយាបថ គឺជាតម្រូវការមួយដ៏សំខាន់ ទាំងក្នុងចំណោមកម្មករ និងក្នុងចំណោមប្រជាជនទូទៅ ដើម្បីគាំទ្រឱ្យមានវប្បធម៌បណ្តុះបណ្តាល ដែលផ្តោតទៅលើ ការអប់រំលើបុរស និងស្ត្រីដែលពេញវ័យ។

ការផ្តួចផ្តើមក៏រិតតូច ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រី នៅក្នុងរោងឧស្សាហកម្មសំខាន់ៗ និងទៅលើស្ត្រីក្នុងសហគ្រាសធុនតូចនិងមធ្យម រួមជាមួយនឹងការវិនិយោគទុនទ្រង់ទ្រាយធំ ក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដោយជួយឱ្យស្ត្រីទទួលយកផលប្រយោជន៍ពីឱកាសការងារ ហើយនិងទទួលបាននូវប្រាក់ចំណូលប្រកបដោយនិរន្តរភាព ។ ដូចដែលកម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ បានគូសបញ្ជាក់ថា :

*[ជាពិសេស]បើគេកំណត់យកស្ត្រីជាក្រុមគោលដៅ [វិធានការទាំងឡាយនេះ] នឹងជួយកាត់បន្ថយនូវអតុល្យភាពយេនឌ័រ ដែលនាំមកនូវភាពក្រីក្រ ហើយនិងធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថរបស់ម្តាយ ចំពោះការអប់រំនិងបណ្តុះបណ្តាលដល់កូនស្រីរបស់ពួកគេ (បើរីសេហ្វដ អេ អល ២០០៤ ១៧០)*

## ៥ គំរូការយុទ្ធសាស្ត្រនិងអន្តរាគមន៍បន្ថែម

*ការធ្វើឱ្យគុណភាពនៃជីវិតកាន់តែប្រសើរឡើងសំរាប់... ស្ត្រីគឺជារបៀបមួយឆាប់បំផុតដែលប្រហែលជាជួយកាត់បន្ថយអ្នកគ្មានការងារធ្វើ បង្កើនផលិតផលនិងធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន ។ ការវិនិយោគទុន នៅក្នុងវិស័យអប់រំនិងសុខភាពរបស់ស្ត្រីត្រូវបានគេចាត់ទុកថាជាការវិនិយោគមួយដែលមានតម្លៃវិសេសវិសាលចំពោះសេដ្ឋកិច្ចជាតិ (បើរីសែហ្វដ អេអល ២០០៤ : ១៧០) ។*

ផ្តើមចេញពីការពិភាក្សាខាងលើ វាឃើញយ៉ាងជាក់ច្បាស់ថា ការធ្វើអន្តរាគមន៍ក្នុងករិតណាមួយ ដោយផ្តោតទៅលើកម្មករដែលបំរើការងារ នៅក្នុងផ្នែកកាត់ដេរ ត្រូវបានគេរៀបចំផែនការ ឬបានដំណើរការរួចរាល់ហើយ ។ ចំពោះសកម្មភាពដទៃទៀត ដែលគេអាចនឹងរៀបចំផែនការនោះ បានកំណត់ក្នុងឯកសារស្រាវជ្រាវនេះ ដូចបានសង្ខេបនៅក្នុងតារាងខាងក្រោម :

| អង្គការ | សកម្មភាព | ក្រុមគោលដៅ | រយៈពេល |
|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន និង ក្រសួងពាណិជ្ជកម្ម (ADB, MoWVA, Moc) | TA ផ្តល់នូវការឧបត្ថម្ភដល់ស្ត្រីនៅក្នុងផ្នែកកាត់ដេរ ដើម្បីឱ្យឈានទៅដល់ការធ្វើពាណិជ្ជកម្មដោយសេរី ក្នុងនេះរួមមានកម្មវិធីសាកល្បង ដើម្បីគាំទ្រកម្មការិនីតាមរយៈការបណ្តុះបណ្តាលនូវអាជីវកោសល្យក្រុមសន្សំ ប្រាក់ និង ភាពជាសហគ្រាស | កម្មការិនីរោងចក្រកាត់ដេរ ភ្នំពេញ | កម្មវិធីសាកល្បង ចាប់ផ្តើមថ្មី១និង ដំណើរការរយៈពេល ៦-៧ ខែ |
| ឃែ (CARE) | ធ្វើការអប់រំដល់ក្រុមដែលធ្វើការទាក់ទងទៅនឹងសុខភាពបន្តពូជ និងផ្លូវភេទ | កម្មកររោងចក្រ និងការគ្រប់គ្រង ភ្នំពេញ | កំពុងតែបន្ត |
| សមាគមផលិតករសំលៀកបំពាក់កម្ពុជា(GMAC) | បញ្ចូលវគ្គបណ្តុះបណ្តាលសំរាប់កម្មការិនីថ្មីដែលចូលធ្វើការក្នុងរោងចក្រ | កម្មកររោងចក្រ, ភ្នំពេញ | ទើបតែពិចារណា |
| FDA | ផ្តល់ថវិកាលើកទឹកចិត្តដើម្បីជំរុញនិយោជកឱ្យផ្តល់សេវាសង្គមសំរាប់កម្មករ | ការគ្រប់គ្រងរោងចក្រភ្នំពេញ | ទើបតែពិចារណា |
| អង្គការពលកម្មអន្តរជាតិ (ILO) | ពង្រីកការផ្តួចផ្តើមឱ្យមានវគ្គបណ្តុះបណ្តាលនៅក្នុងរោងចក្រកាត់ដេរ ដោយបញ្ចូលវគ្គបណ្តុះបណ្តាលដល់កម្មករ ស្តីពីសិទ្ធិរបស់ពួកគេ និងការរំលោភផ្លូវភេទ ជាដើម... ។ល ។ | កម្មកររោងចក្រ, ភ្នំពេញ | ទើបតែពិចារណា |

| | | | |
|---|---|---|---|
| ក្រសួងការងារ (MoL) | ពង្រីកតួនាទីរបស់មជ្ឈមណ្ឌលបណ្ដុះ បណ្ដាលខេត្ត ដើម្បីផ្ដល់នូវវគ្គខ្លីៗ និង លក្ខណៈសម្បត្តិ គ្រាប់គ្រាន់ដើម្បីរកការងារ ផ្ដោតលើតំបន់ជនបទ កសិឧស្សាហកម្ម និងការអភិវឌ្ឍន៍ SME ។ បញ្ចូលជំនាញប៉ាន់ប្រមាណ និងការទទួលស្គាល់គុណភាព | តំបន់ជនបទ មនុស្សវ័យក្មេង និងកម្មករថ្មីៗ ទូទាំង ១៦ខេត្ត | បានធ្វើផែនការ ហើយ |
| MoWVA, ជាមួយការឧបត្ថម្ភ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន MoWVA ដោយមានការឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍ អាស៊ី ADB | ការពង្រីកតួនាទីរបស់មជ្ឈមណ្ឌល អភិវឌ្ឍន៍ស្ត្រី ដើម្បីរួមបញ្ចូលនូវការបណ្ដុះបណ្ដាលជំនាញ ការអភិវឌ្ឍន៍ជំនាញពាណិជ្ជកម្ម បំនិនជីវិត និងអក្ខរកម្ម ។ | ស្ត្រីនៅក្នុង SMEs ចាប់ផ្ដើមពី ៤ ខេត្តដំបូង | ទើបតែពិចារណា |
| USAID | TA ធ្វើការប៉ាន់ប្រមាណនូវសេចក្ដីត្រូវការ ជំនាញ និងធ្វើផែនការផ្ដល់វគ្គ បណ្ដុះបណ្ដាល ដើម្បីអភិវឌ្ឍជំនាញដល់រោងចក្រកាត់ដេរ ។ | កម្មកររោងចក្រកាត់ដេរ ភ្នំពេញ | ទើបតែពិចារណា |
| WAC | អប់រំសិទ្ធិ និង ការផ្ដល់សិទ្ធិអំណាច | ស្ត្រីកម្មកររោងចក្រ ភ្នំពេញ | កំពុងតែបន្ត |

ផ្នែកខាងលើនេះជាក់ស្ដែងផ្ដោតទៅលើអ្វីដែលអាចមានប្រយោជន៍ដើម្បីបន្ថែមទៅលើការងារអភិវឌ្ឍន៍ គោលនយោបាយទៅលើការវិភាគ និង សកម្មភាពកម្មវិធីទ្រង់ទ្រាយធំ ។

## ៥.១ អនុសាសន៍អន្តរាគមន៍ ដើម្បីគាំទ្រកម្មការិនីរោងចក្រក្នុងពេលអន្តរកាល

បន្ថែមទៅលើអន្តរាគមន៍និងគំនិតផ្ដួចផ្ដើមសាកល្បង ដែលកំពុងចាប់ផ្ដើមអនុវត្តដោយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល មានគំនិតផ្ដួចផ្ដើមផ្សេងៗ ដែលត្រូវបានគេស្នើសុំឱ្យពិចារណាដូចខាងក្រោម :

***បង្កើតជម្រើសផ្សេងៗសំរាប់វិធានការគាំទ្រឱ្យមានប្រាក់ចំណូលបន្ថែម :*** ពិភាក្សាជាមួយស្ថាប័ន រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល តាមរបៀបផ្សេងៗដែលអាច ធ្វើទៅបានក្នុងគោលបំណងផ្ដល់ការគាំទ្រប្រាក់ចំណូល (អាហារ និង ទីជម្រក) ផ្ដល់ចំពោះស្ត្រី ដែលត្រូវបានគេបញ្ឈប់ពីការងារ ។ តាមដែលអាចធ្វើទៅបាននៅទីណាក៏ដោយ កិច្ចការនេះគួរតែជួយបន្ថែមទៅលើសេវាកម្មដែលមានស្រាប់ និងកម្មវិធីបាន (Outreach Program) ដែលកំពុងតែផ្ដល់ដល់ស្ត្រី ប៉ុន្តែត្រូវមានការគាំទ្រពីម្ចាស់ជំនួយ ។

***បង្កើតការចុះបញ្ជីការងារនិងផ្តល់ព័ត៌មានអំពីការងារ (Referral) :*** ផ្តល់ដល់ស្ត្រីដែលត្រូវបានកាត់ចោលបន្ថយប្រាក់បៀវត្សរ៍នូវឱកាសដើម្បីចុះបញ្ជីការងារ ធ្វើការប៉ាន់ប្រមាណនិងផ្តល់នូវការ ទទួលស្គាល់សមត្ថភាពជំនាញថ្មីរបស់ពួកគេ (សូមអានអត្ថបទខាងក្រោម) ទទួលនូវវគ្គបណ្តុះបណ្តាលនិងការអភិវឌ្ឍន៍ជំនាញនិងគំនិតផ្តួចផ្តើមផ្សេងៗហើយទទួលបានព័ត៌មានអំពីឱកាសការងារ នៅពេលដែលរោងចក្រទាំងឡាយត្រូវបានរួមបញ្ចូលគ្នា ។ ជាមតិយោបល់ កិច្ចការនេះគួរតែរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដើម្បីជាសេវាកម្មមួយ (stop shop service) សំរាប់ស្ត្រីហើយសេវាកម្មនេះទំនងជាអាចធ្វើក្នុងភាពជាដៃគូជាមួយអ្នកជំនួញ ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានបទពិសោធន៍ក្នុងការផ្តល់កន្លែងធ្វើការ ហើយនិងព័ត៌មានការងារនៅក្នុងទីក្រុងភ្នំពេញ ។ ប៉ុន្តែយ៉ាងណាក៏ដោយកិច្ចការនេះ ក៏ត្រូវមានការសហការ និងការគាំទ្រពីអ្នកគ្រប់គ្រងរោងចក្រផងដែរ ។

***ការសាកល្បងនូវការផ្តល់ជំនាញបឋម (Prior learning) :*** ក្នុងភាពជាដៃគូជាមួយ ក្រសួងការងារ អង្គការពលកម្មអន្តរជាតិ និង **GMAC** ការសាកល្បងទៅលើការផ្តួចផ្តើមមួយដើម្បីប៉ាន់ប្រមាណ ហើយនិងផ្តល់នូវការទទួលស្គាល់ជាផ្លូវការលើលទ្ធភាព និងជំនាញរបស់ស្ត្រីតាមរយៈការប្រើនូវ កម្មវិធី ជំនាញបឋម ដែលថ្មីៗនេះក្រសួងការងារកំពុងតែពិចារណាដើម្បីយកមកប្រើនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត ។

***ផ្តល់ការអភិវឌ្ឍន៍ជំនាញបន្ថែមនិងសកម្មភាពបណ្តុះបណ្តាល :*** បន្ថែមទៅលើសកម្មភាពផ្តួចផ្តើម ដែលបានធ្វើផែនការរួចហើយ (រួមមាន ភ្នាក់ងារជំនួយអភិវឌ្ឍន៍សហរដ្ឋអាមេរិក) ដើម្បីជួយបង្កើនជំនាញពួកគេឱ្យកាន់តែប្រសើរឡើង ឧទាហរណ៍ដូចជា បច្ចេកវិជ្ជាថ្មីដែលមាននៅក្នុងរោងចក្រកាត់ដេរ ។ វគ្គបណ្តុះបណ្តាលនេះគួរតែធ្វើនៅជុំវិញរោងចក្រដោយ មានការគាំទ្រពីអ្នកគ្រប់គ្រងរោងចក្រ និងស្ត្រីដោយផ្ទាល់ ។ រោងចក្រកាត់ដេរគួរតែបរិច្ចាគថវិកាមួយចំនួនណា ចំពោះការចំណាយលើវគ្គបណ្តុះបណ្តាលនេះ ។

***ពង្រីកការផ្តួចផ្តើមសាកល្បង ដើម្បីផ្តល់នូវវគ្គបណ្តុះបណ្តាលនិងការអភិវឌ្ឍន៍ជំនាញដើម្បីជួយដល់ស្ត្រីអាចទទួលបានការងារផ្សេងទៀត ឬក៏បង្កើតនូវមុខរបរសំរាប់ខ្លួនឯង :*** ជួយរៀបចំការងារ ទាំងនេះឱ្យបានដល់កម្មការិនី ដើម្បីមានការចាប់អារម្មណ៍ក្នុងការផ្លាស់ប្តូរស្ថានភាពការងាររបស់ពួកគេ ។ ការឈានទៅទទួលបាននូវឥណទានដែលមានកម្រិតការប្រាក់ដែលអាចទទួលយកបាន វាជាផ្នែកមួយដ៏សំខាន់នៃការផ្តួចផ្តើមនេះ ។ ជាគំនិតយោបល់កិច្ចការនេះគួរតែជាតួនាទីរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ។ ប្រភេទនៃវគ្គបណ្តុះបណ្តាលនេះចាំបាច់ត្រូវតែអមជាមួយនិងការផ្តល់យោបល់ប្រាកដនិយមហើយនិង ព័ត៌មានទីផ្សារអំពីតម្រូវការផលិតផល សេវាកម្ម និង ចំនួនកំណត់សំរាប់ការបើកចំហការចរចា ស្របទៅនឹងប្រាក់ខែទីផ្សារការងារ ។

***ធ្វើការស្រាវជ្រាវទៅលើទំហំ និងរបៀបនៃការបង្កើតតំបន់ក្រៅផ្លូវការ ដែលឋិតនៅជុំវិញឧស្សាហកម្មកាត់ដេរ:*** ធ្វើការប៉ាន់ប្រមាណទៅលើឥទ្ធិពលដែលទំនងជាអាចធ្វើឱ្យផ្លាស់ប្តូរក្នុងវិស័យកាត់ដេរ ទៅលើស្ត្រីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធការគាំទ្រ និងការអភិវឌ្ឍន៍ជំនាញដែលពួកគេអាចត្រូវការ ។ លើសពីនេះទៅទៀត ការស្រាវជ្រាវអំពីស្ត្រីនៅក្នុងតំបន់

ក្នុងប្រព័ន្ធ កាន់តែទូលំទូលាយគួរតែ គិតគូរដើម្បីបង្កើនការយល់ដឹងឱ្យច្បាស់ថែមទៀត អំពីការចូលរួមចំណែករបស់ស្ត្រីទៅក្នុងសេដ្ឋកិច្ចជាតិ និងប្រាក់ចំណូលដែលពួកគេរកបាន តាមរយៈការងារក្រៅប្រព័ន្ធ ។ ពិភាក្សាជាមួយ PMATU ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដើម្បីបញ្ជាក់ថា នេះគឺជាព័ត៌មានគន្លឹះដែលត្រូវបំពេញចន្លោះខ្វះខាត ។

*ការទាយទុកជាមុនអំពីការធ្វើអន្តោប្រវេសន៍ទៅកាន់តំបន់ឧស្សាហកម្មនាំចេញពិសេស* **(EPZs)** *និងក្រៅប្រទេស* **:** ស្វែងយល់ពីផលប៉ះពាល់ ដែលមានសក្តានុពលទៅលើអត្រានៃការធ្វើអន្តោប្រវេសន៍ទាំងក្នុងនិងក្រៅប្រទេសដោយធ្វើការប៉ាន់ប្រមាណទៅលើគ្រោះថ្នាក់ជាសក្តានុពលចំពោះស្ត្រី និងប្រឈមមុខដោះស្រាយតាមរបៀបល្អបំផុត ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ដែលបានគិតទុករួចជាស្រេច ។ ការទាយទុកមុននេះនឹងត្រូវយកមកពិចារណាលើចំនួនទីតាំង និងបែបផែននៃតំបន់ឧស្សាហកម្ម ពិសេស១ទីមួយៗ រួមជាមួយនឹងការកំណត់ពេលវេលាសំរាប់ ការបង្កើតតំបន់ឧស្សាហកម្មនីមួយៗ ប៉ុន្តែត្រូវតែទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា ។

## ៥.២ អនុសាសន៍ដែលបានស្នើឡើងដើម្បីធានានូវសន្តិសុខការងារនិងជម្រើសការងារសំរាប់ស្ត្រី

មានចំណុចពីរដែលទាក់ទង ហើយសំខាន់ដើម្បីបន្ថែមទៅលើគំនិតផ្តួចផ្តើមទាំងឡាយ ដែលកំពុងតែអនុវត្តនៅក្នុងក៏រិតខ្នាតធំ ដើម្បីធានានូវអនាគត នៃឧស្សាហកម្មកាត់ដេរ និងដើម្បីបង្កើតនូវជម្រើសការងារ :

ការវិនិយោគទុនទ្រង់ទ្រាយធំនៅក្នុងការអភិវឌ្ឍន៍*SME*ដោយកំណត់យកស្ត្រីនិងឧស្សាហកម្មជាក្រុមគោលដៅដែលមានស្ត្រីកំពុងធ្វើការនៅទីនោះ ដោយមានការផ្តល់ថវិកា រយៈពេលវែងក្នុងការផ្តល់ការអភិវឌ្ឍន៍ជំនាញ ការគាំទ្រមុខជំនួញ ហើយនិងជួយឱ្យទទួលបាននូវឥណទាន ដែលសមស្រប : កិច្ចការនេះទាមទារឱ្យមានការផ្តោតជាអាទិភាពទៅលើការគាំទ្រស្ត្រីនៅក្នុង SMEs ហើយនិងគាំទ្រ SMEs នៅក្នុងរោងចក្រជាកន្លែងដែលស្ត្រីមានឥទ្ធិពល ដូចជាការលក់ដូរកំប៉ិកកំប៉ុក និងលក់រាយជាដើម ។ វិធានការពីរដែលគេត្រូវការគឺ ទីមួយត្រូវតែពិនិត្យឡើងវិញទៅលើគំនិតផ្តួចផ្តើមដែលមានស្រាប់ដែលកំណត់យក SMEs ជាក្រុមគោលដៅ ដើម្បីធានាថា គេកំពុងតែកំណត់យកនិងគាំទ្រស្ត្រីយ៉ាងមានប្រសិទ្ធភាព ។ វិធានការទីពីរគឺធ្វើយ៉ាងណា ដើម្បីឱ្យការអនុវត្តគម្រោងផែនការប្រព្រឹត្តទៅបានឆាប់រហ័ស តាមរយៈការបង្កើនតួនាទីរបស់មជ្ឈមណ្ឌល អភិវឌ្ឍន៍ស្ត្រី ដោយបញ្ចូលការអភិវឌ្ឍន៍ជំនាញ ក្នុងនោះរួមមាន ជំនាញទីផ្សារ វគ្គបណ្តុះបណ្តាលគ្រប់គ្រងជំនួញ បំនិនជំនាញ ហើយនិងអក្ខរកម្ម ។ ក្នុងខណៈពេល ដែលការពិភាក្សាទាំងឡាយ កំពុងតែដំណើរការដើម្បីបង្កើនការសម្របសម្រួលនិងការផ្តល់នូវសេវាកម្មសាធារណៈរហូតដល់៤ខេត្ត ។ ទន្ទឹមនឹងនេះ យើងត្រូវការផ្តល់សេវាកម្មសាធារណៈពីថ្នាក់ជាតិទៅគ្រប់ខេត្តទាំងអស់ ។

ការបង្កើនការផ្តល់ការអប់រំវិជ្ជាជីវៈដល់ស្ត្រីដែលពេញវ័យ និងឱ្យមានការចូលរួមយ៉ាងច្រើន ក្នុងវគ្គបណ្តុះបណ្តាលដើម្បីឈានទៅដល់ការទទួលបានការងារធ្វើក្នុងក៏រិតមួយដ៏ទូលំទូលាយ ។ យុទ្ធសាស្ត្រជាតិសំរាប់ការអប់រំវិជ្ជាជីវៈដែលមានរួចហើយ និងគម្រោងផែនការសំរាប់ការប្រតិបត្តិ ដែលក្នុងនោះរៀបចំតាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត

កំពុងតែដំណើរការ ។ ការស្រាវជ្រាវរបស់អង្គការពលកម្មអន្តរជាតិ និង ក្រសួងការងារ ហើយការស្រាវជ្រាវបានកំណត់នូវរបាំងមួយចំនួន ដែលរារាំងការចូលទៅដល់ស្ត្រី និងកំណត់អនុសាសន៍ដើម្បីបង្កើន នូវការទទួលបាននូវការបណ្តុះបណ្តាល និងការងារផងដែរ ។ ការិយាល័យដើម្បីយេនឌ័រមួយត្រូវបានគេបង្កើតឡើងនៅក្នុង ក្រសួងការងារ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។កិច្ចប្រឹងប្រែងនេះ គឺធ្វើយ៉ាងណាដើម្បីពង្រីកឱកាសចំពោះស្ត្រី ក្នុងការទទួលបាននូវការងារដ៏ទូលំទូលាយ ( មិនត្រឹមតែការកាត់សក់និងកាត់ដេរប៉ុណ្ណោះទេ) និង ដើម្បីធានាថា ទីនោះមានការផ្សារភ្ជាប់រវាងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីទៅនឹង PTCs ហើយនិង PTCs ទៅនឹងក៏រិតមូលដ្ឋាន ដើម្បីលើកទឹកចិត្តអ្នកដែលផ្តល់ព័ត៌មានអំពីការងារ និងជួយជំរុញស្ត្រី ឱ្យទទួលបាននូវវគ្គបណ្តុះបណ្តាល ។

ប្រសិនបើជាមានការគាំទ្រ និងផ្តល់ថវិកាត្រឹមត្រូវ ហើយមានលក្ខណៈយូរអង្វែងទៀតនោះ ការអភិវឌ្ឍន៍ និងការអនុវត្តន៍យុទ្ធសាស្ត្រទាំងនេះ នឹងមានសារៈសំខាន់មិនត្រឹមតែសំរាប់ស្ត្រីនៅក្នុងឧស្សាហកម្មកាត់ដេរ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំខាន់សំរាប់កម្លាំងកម្មករទាំងបច្ចុប្បន្ន និងនាពេលអនាគតទៀតផង ។ លើសពី នេះទៅទៀតនោះ ភ្នាក់ងារគួរតែពិចារណាទៅលើចំណុចមួយចំនួនដូចខាងក្រោមៈ

- ***អនុវត្តការវិភាគយេនឌ័រលើវិស័យនានា ដែលប៉ះពាល់ដល់យុទ្ធសាស្ត្រពាណិជ្ជសេរីភាវូបនីយកម្ម ក្នុងប្រទេសកម្ពុជា :*** ជាអាទិភាពគេគួរតែបញ្ចូលការប៉ាន់ប្រមាណអំពីផលប៉ះពាល់យេនឌ័រនៃ EPZs ដែល ក្នុងនោះរាប់បញ្ចូលទាំងការធ្វើអន្តោប្រវេសន៍ និងក៏រិតនៃភាពក្រីក្រ ។ កិច្ចការនេះគេគួរតែបញ្ចូលឱ្យបានត្រឹមត្រូវទៅក្នុងការប៉ាន់ប្រមាណផលប៉ះពាល់ការអភិវឌ្ឍន៍មនុស្ស នាពេលខាងមុខ ទៅលើបញ្ហាពាណិជ្ជកម្មដែល រៀបចំគម្រោងដោយ **UNDP** នៅចុងឆ្នាំក្រោយ ។
- ***ជំរុញការផ្តួចផ្តើមដែលផ្តល់ព័ត៌មានដល់កម្មការិនីកាត់ដេរអំពីសិទ្ធិរបស់ពួកគេ :*** ក្នុងកិច្ចសហការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដូចជា **WAC** និង **CARE** ជាផ្នែកនៃការបន្តផ្តោតការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តដើម្បីឈានទៅដល់ក៏រិតបទដ្ឋានការងារអន្តរជាតិ ដើម្បីធ្វើឱ្យប្រាកដថាប្រទេសកម្ពុជាអាចមានលទ្ធភាពប្រកួតប្រជែងជានិច្ច ព្រមទាំងអាចការពារនូវសិទ្ធិកម្មករទៀតផង ។ ការបង្កើននូវការផ្តួចផ្តើមដែលមានបច្ចុប្បន្ន ដោយរោងចក្រកាត់ដេរ និងអង្គការពលកម្មអន្តរជាតិ ក្នុងនោះរាប់បញ្ចូលទាំងវគ្គបណ្តុះបណ្តាលលើវិស័យផ្សេងទៀត (sector-wide training) សំរាប់អ្នកគ្រប់គ្រងរោងចក្រ និងបុគ្គលិក ។ ការប្រើយីហោជាតិ តម្រូវឱ្យមានការគាំទ្រ ហើយការផ្តោតយកចិត្តទុកដាក់ទៅលើលក្ខខណ្ឌការងារ ដើម្បីបង្ហាញថាប្រទេសកម្ពុជា និងរោងចក្រកម្ពុជា ពិតជាធ្វើ "ពាណិជ្ជកម្មត្រឹមត្រូវ" ហើយនឹងមានការលើកទឹកចិត្តអ្នកលក់រាយ និងអ្នកប្រើប្រាស់ដែលទិញផលិតផលរបស់កម្ពុជា ។

ដូចបានកំណត់ខាងលើ ទីភ្នាក់ងារមួយចំនួន កំពុងធ្វើការប៉ាន់ប្រមាណអំពីអនាគតនៃរោងចក្រកាត់ដេរ ដែលកំពុងតែធ្វើការស្រាវជ្រាវ និងកំពុងផ្តួចផ្តើមរៀបចំកម្មវិធី ដើម្បីរកវិធីទប់ទល់ និងដោះស្រាយចំពោះផលប៉ះពាល់ក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងបញ្ហាសាកលភាវូបនីយកម្ម ។ ទោះបីយ៉ាងណាក៏ដោយ

បញ្ហាទាក់ទងនឹងសមត្ថភាព និងការសម្របសម្រួលអាចរារាំងដំណើរការនៃកិច្ចប្រឹងប្រែងនេះ ។

ការផ្តួចផ្តើមជាច្រើន មានលក្ខណៈត្រឹមតែសំរាប់ស្ថានភាពពិសេសតែប៉ុណ្ណោះ ហើយអន្តរាគមន៍ ក្នុងទ្រង់ទ្រាយតូចនឹងចោទជាបញ្ហាចំបង នៅពេលគេគិតថា ការកាត់បន្ថយតម្លៃផលិតនោះសមរម្យ ហើយប្រសិនបើគេរៀបចំផែនការអនាគតមិនបានល្អ មានរោងចក្រមួយភាគបីនឹងត្រូវបិទទ្វារ ។ ការប៉ាន់ប្រមាណមើល លើកំរិតណាមួយក្នុងការគាំទ្រវាប្រហែលជាតម្រូវការមួយចាំបាច់ ។ សមត្ថភាពដែលត្រូវការ ដើម្បីផ្តល់នូវសេវាកម្មសមស្រប និងផ្តួចផ្តើមគំនិតបានត្រឹមត្រូវរួមផ្សំជាមួយការចំណាយសមស្របដែលពាក់ព័ន្ធក្នុងការពង្រីកកំរិតការគាំទ្រដល់ស្ត្រីមួយចំនួនធំ ប៉ះពាល់ដោយការកាត់បន្ថយតម្លៃផលិត ក៏ជាតម្រូវការមួយដ៏ចាំបាច់ផងដែរ ។ ការចំណាយចំពោះការផ្តួចផ្តើមការកាត់បន្ថយផលប៉ះពាល់សង្គម ត្រូវតែមានផែនការអនាគតផ្សេងៗពីគ្នា ហើយកិច្ចការនេះ ត្រូវធ្វើដោយភ្នាក់ងារ ដែលសហការគ្នា ជាជាងការធ្វើដាច់ដោយឡែកពីគ្នា ។

លើសពីនេះទៅទៀត វាមានការសម្របសម្រួលទាក់ទង ទៅនឹងផ្នែកតូចៗនៃកម្មវិធីនិងគំនិតផ្តួចផ្តើម ដែលគេកំពុងអនុវត្ត ឬក៏កំពុងតែរៀបចំផែនការ ។ ការខ្វះការសម្របសម្រួលពីម្ចាស់ជំនួយក៏ជាបញ្ហា កំពុងកើតមាននៅក្នុងប្រទេសកម្ពុជាហើយការកើតមានឡើងនេះ វាគឺជាបញ្ហាបន្ទាន់ ដែលភ្នាក់ងារទាំងឡាយ រួមមាន : ម្ចាស់ជំនួយ រដ្ឋាភិបាល និងអង្គការមិនមែន រដ្ឋាភិបាលរួបរួមគ្នា ដើម្បីចែករំលែកព័ត៌មាន អំពីការវិភាគនិងការព្យាករណ៍ ដែលពួកគេបានអនុវត្តការធ្វើអន្តរាគមន៍និងសកម្មភាពដែលពួកគេកំពុងរៀបចំផែនការ ។ សិក្ខាសាលាមួយដែលនិងមានការរៀបចំរួមដោយម្ចាស់ជំនួយ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមស្ត្រីគួរតែរៀបចំឱ្យឆាប់ តាមដែលអាចធ្វើទៅបាន ដើម្បីជួយសម្រួលការចែករំលែកព័ត៌មាន ផែនការសហការ និងការអនុវត្តន៏ដោយ ភ្នាក់ងារទាំងនេះ។

## ៦ សន្ទស្សន៍ដែលអាចធ្វើទៅបាននៃគម្រោងយេនឌ័រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍

ឯកសារនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីផ្តល់ព័តិមានអំពីយេនឌ័រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដោយបង្កើតនូវសន្ទស្សន៍បន្ថែមយោងតាមចំណុចទី១ និង ទី៦នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ សន្ទស្សន៍បន្ថែមដែលបានស្នើឡើងបានបញ្ចូលនៅទីនេះ សំរាប់ការពិភាក្សា និងពិចារណា ។ ហើយក្នុងកិច្ចការមួយចំនួន វាទាមទារឱ្យមានការរៀបចំនិងប្រមូលទិន្នន័យសម្រាប់វាស់វែងពីទីកន្លែងណា ដែលអាចរកបាន ប៉ុន្តែជាការល្អ គួរតែបានមកពីប្រភពទិន្នន័យដែលមានស្រាប់ ។ សន្ទស្សន៍ទាំងឡាយនេះ ត្រូវបាន គេរៀបចំ ដើម្បីតាមដានពិនិត្យមើលផលប៉ះពាល់ នៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និង ការបញ្ចប់កូតា សំរាប់ស្ត្រី រួមទាំងឥទ្ធិពលនៃគំនិតផ្តួចផ្តើមដែលបានរៀបចំឡើង ដើម្បីបង្កើតការងារ និងគាំទ្រស្ត្រីសំរាប់រយៈពេលអន្តរកាល ។

ក្រុមបច្ចេកទេសវិភាគនិងត្រួតពិនិត្យភាពក្រីក្រថ្មីនេះ ផ្តល់ជាយោបល់ទៅលើសន្ទស្សន៍មួយចំនួន ដើម្បីបញ្ចូលទៅក្នុងសន្ទស្សន៍ត្រួតពិនិត្យការអភិវឌ្ឍន៍ និង ភាពក្រីក្រនៃប្រទេសកម្ពុជានៅពេលដែលគេរៀបចំវេទិកាភាពក្រីក្រថ្នាក់ជាតិនៅក្នុងខែតុលា ឆ្នាំ ២០០៤ ។ ពេលនោះ គេបានលើកឡើងថា សន្ទស្សន៍ខាងក្រោមត្រូវផ្ញើជូនទៅក្រុមបច្ចេកទេសវិភាគនិងវាយតម្លៃភាពក្រីក្រ PMATU ដើម្បីពិចារណា និងអនុម័តលើសេចក្តីព្រាងសន្ទស្សន៍ចុងក្រោយ ។

- សមាមាត្រនៃមេផ្ទះដែលជាស្ត្រីក្នុងពេលបច្ចុប្បន្ន ឬពីមុនមកដែលបំរើការងារនៅក្នុងផ្នែកកាត់ដេរ ដែលទទួលប្រាក់ចំណូលទាបជាងបន្ទាត់នៃភាពក្រីក្រ ។
- សមាមាត្រនៃស្ត្រីដែលមានអាយុចាប់ពី ១៥-២៤ឆ្នាំ ឋិតនៅក្នុងក្រុមដែលក្រជាងគេបំផុត ។
- សមាមាត្រនៃមេផ្ទះដែលមានចំនួនមួយ ឬច្រើនជាងដែលមានអាយុចាប់ពី ១៥-២៤ឆ្នាំ ឋិតនៅក្រោមក្រុមដែលក្រជាងគេបំផុត ។
- ចំនួនភាគរយនៃស្ត្រីដែលមានអាយុចាប់ពី ១៥-២៤ឆ្នាំ គឺជាអ្នកដែលពុំទាន់គ្រប់អាយុធ្វើការងារ ឬក៏ពុំមានការងារធ្វើ ។
- សមាមាត្រនៃស្ត្រីដែលមានមុខរបរខ្លួនឯង ។
- ចំនួនភាគរយនៃកម្មការិនីរោងចក្រកាត់ដេរទាំងឡាយ ដែលត្រូវបានគេបញ្ឈប់ពីការងារ ។ សមាមាត្រ នៃស្ត្រីដែលបញ្ឈប់ពីការងារនោះ គឺជាអ្នកដែលអាចទទួលប្រាក់បៀវត្សរ៍ពីកន្លែងផ្សេង អាចមានមុខរបរផ្ទាល់ខ្លួន ឬក៏ជាអ្នកដែលពុំទាន់គ្រប់អាយុធ្វើការងារ ។
- ចំនួនភាគរយនៃស្ត្រីដែលមានអាយុពី ១៥-២៤ឆ្នាំ និងលើសពីនេះ ដែលជាអ្នកចូលរួមនៅក្នុងការបណ្តុះបណ្តាលនិង

អប់រំខាងវិជ្ជាជីវៈរួមមាន វគ្គខ្លី វគ្គបណ្តុះបណ្តាលអនុវត្តការងារ (On the job training skill) កម្មវិធីអភិវឌ្ឍន៍ជំនាញនិងវគ្គបណ្តុះបណ្តាលទទួលស្គាល់ជំនាញផ្លូវការ (formally accredited training) ។

- អត្រាស្ត្រីដែលបានបញ្ចប់មធ្យមសិក្សាដោយប្រៀបធៀបទៅនឹងបុរស ។ កំរិតបញ្ជាក់គុណសម្បត្តិ (qualification) នៃស្ត្រីដោយប្រៀបធៀបទៅនឹងបុរស ។
- សមាមាត្រនៃស្ត្រីដែលរកស៊ីផ្លូវភេទ ក្នុងនិងក្រៅប្រព័ន្ធ និងនៅទីក្រុង ឬនៅតាមខេត្ត ។
- អត្រារីកដុះដាលនៃមេរោគហ៊ីវ (HIV) ក្នុងចំណោមអ្នករកស៊ីផ្លូវភេទនៅទីក្រុង ។
- អត្រានៃស្ត្រីអន្តោប្រវេសន៍ស្វែងរកការងារធ្វើទាំងក្នុងប្រទេសនិងក្រៅប្រទេសដោយ ប្រៀបធៀបទៅនឹងបុរស ។
- សមាមាត្រនៃស្ត្រីដែលមានអាយុពី ១៥-២៤ឆ្នាំ ដែលធ្វើអន្តោប្រវេសន៍នៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេសសម្រាប់ធ្វើការ ។
- អត្រាស្ត្រីនៅក្នុងមុខរបរសម័យថ្មី ប្រៀបធៀបជាមួយបុរស ។
- ចំនួនភាគរយនៃស្ត្រីដែលអាចរកស៊ីសេវាកម្មជំនួញ ក្នុងនោះមានឥណទានខ្នាតតូច ។

## ៧) សកម្មភាពតាមដានជាយុទ្ធសាស្ត្ររបស់ UNIFEM

សកម្មភាពជាអនុសាសន៍ដែលបានស្នើឡើងដើម្បីអោយ UNIFEM អនុវត្តមានដូចខាងក្រោម៖

- ធ្វើការស្រាវជ្រាវស្តីពីការងាររបស់ស្ត្រីនៅក្នុងផ្នែកក្រៅប្រព័ន្ធ ហើយផ្សារភ្ជាប់ទៅនឹងភាពក្រីក្ររបស់ស្ត្រី (feminisation of poverty) ។
- រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីភាពក្រីក្ររបស់ស្ត្រី (feminisation of poverty) ។

លើសពីនេះ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជនបានកំណត់យកនូវចំណុចមួយចំនួនដូចខាងក្រោម ដែល UNIFEM អាចផ្តល់ការប្រឹក្សា និងគាំទ្របន្ថែម ៖

- ផ្តល់ការប្រឹក្សាទៅលើវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលតម្រូវឱ្យត្រូវទៅនឹងទីផ្សារថ្មី និងទីផ្សារដែលនឹងកើតឡើង ហើយនិងអ្វីដែលគេអាចធ្វើបាន ដើម្បីគាំទ្រនិងលើកទឹកចិត្តដល់ស្ត្រី ដើម្បីទទួលបានជំនាញពាក់ព័ន្ធ ដើម្បីរកការងារបានក្នុងវិស័យទាំងនេះ ប៉ុន្តែឋិតនៅក្នុងការពិគ្រោះគ្នាជាមួយអង្គការពលកម្មអន្តរជាតិ ។
- ផ្តល់ប្រឹក្សាទៅលើវគ្គបំណិនជីវិត (Life-skill) សំរាប់ស្ត្រី និងផ្តល់អ្វីដែលតម្រូវនៅក្នុងជំនាញអភិវឌ្ឍន៍ ដែលក្នុងនោះរួមមានព័ត៌មានអំពីសិទ្ធិស្ត្រីនៅក្នុងកម្លាំងពលកម្ម ព្រមទាំងផ្តល់ប្រឹក្សាអំពីអ្វីដែលត្រូវការ ដើម្បីការពារស្ត្រីកុំឱ្យធ្វើអន្តោប្រវេសន៍ ដោយសារការស្វែងរកការងារ ។
- រដ្ឋមន្ត្រីបានគាំទ្រយ៉ាងខ្លាំងក្លាផងដែរ នូវតម្រូវការសំរាប់ការស្រាវជ្រាវស្តីពីស្ត្រី នៅក្នុងវិស័យក្រៅប្រព័ន្ធដោយផ្តោតទៅ លើទំហំ តួនាទី និងការចូលរួមចំណែកក្នុងវិស័យសេដ្ឋកិច្ចរបស់ស្ត្រីលើវិស័យ ផ្សេងៗ ក្នុងប្រទេសកម្ពុជា ។

# ឧបសម្ព័ន្ធ ក៕ ការសុំយោបល់

លោកជំទាវ អ៊ឹង កន្ថាផាវី

រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

ឯកឧត្តម ពេជ្រ សោភ័ណ្ឌ

រដ្ឋលេខាធិការ នៃក្រសួងការងារ

លោកស្រី រ៉ូហ្សាណា បាបារ៉ូ និង ក្រុមការងារ

គម្រោងវិស័យកាត់ដេរ

កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ

លោកស្រី វិខា ដាយ៉ាល

អ្នកពិគ្រោះយោបល់អភិវឌ្ឍន៍សង្គម

ធនាគារអភិវឌ្ឍន៍អាស៊ី ម៉ានីឡា

លោកបណ្ឌិត ខេត ហ្វ្រីសិន

ប្រធានគម្រោងយេនឌ័រ និង អភិបាលកិច្ច

ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

លោកស្រី រ៉ូស ហារី

ទីប្រឹក្សាប្រធានបច្ចេកទេសគម្រោងលើក

កំពស់លក្ខខណ្ឌការងារវិស័យកាត់ដេរ

អង្គការពលកម្មអន្តរជាតិ

លោកស្រី សាមវ៉ាដា ខេង

អ្នកឯកទេសយេនឌ័រ និងអភិវឌ្ឍន៍

បេសកជន ប្រចាំប្រទេសកម្ពុជា

ធានាគារអភិវឌ្ឍន៍អាស៊ី

លោកស្រី សារី ឡាអាក សូណេន

អ្នកឯកទេសពាណិជ្ជកម្ម និងវិស័យឯកជន

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ

លោកបណ្ឌិត គែន លូ

អគ្គលេខាធិការ

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

លោកស្រី ដាញ៉ា ម៉ាហ្សូគី

មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ

ក្រុមត្រួតពិនិត្យលើភាពក្រីក្រ

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

លោកស្រី អេឡេន ម៉ាគី

អ្នកដឹកនាំ គោលនយោបាយ និងគ្រប់គ្រងជាន់ខ្ពស់

ភាពជាដៃគូ ដើម្បីសមធមិយេនឌ័រ : ដំណាក់កាលទីពីរ

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

លោកស្រី សូហ្សាន មេរីល

នាយិកា

ការិយាល័យអភិវឌ្ឍន៍ទូទៅ នៃជំនួយអភិវឌ្ឍន៍សហរដ្ឋអាមេរិក

បណ្ឌិត មូស្តាហ្វា យេ មូជីរ

ទីប្រឹក្សា PMA

ក្រុមបច្ចេកទេសវិភាគ និងត្រួតពិនិត្យភាពក្រីក្រ

ក្រសួងផែនការ

លោកស្រី ជី សុជាតិ

មន្ត្រីគ្រប់គ្រងកម្មវិធី

សុខភាពបន្តពូជ

អង្គការយែរ កម្ពុជា

លោកស្រី អ៊ុច សារ៉ុម និង លោកស្រី ឈើរីល អ៊ូរ៉ាស៊ីម៉ា

កម្មវិធីលើកកំពស់និរន្តរភាពការងារ សំរាប់ស្ត្រីក្រីក្រ

ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

# ឧបសម្ព័ន្ធ ២

## ឧទាហរណ៍នៃ គម្រោង និង ការផ្តួចផ្តើមគំនិតបច្ចុប្បន្ន ផ្តោតទៅលើស្ត្រីនៅក្នុងឧស្សាហកម្មកាត់ដេរ

### *ធនាគារអភិវឌ្ឍន៍អាស៊ី – ជំនួយខាងបច្ចេកទេសដល់រដ្ឋាភិបាលកម្ពុជា*

ធនាគារអភិវឌ្ឍន៍អាស៊ីជាដៃគូជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងកិច្ចការនារីនិងអតីតយុទ្ធជនបានផ្តល់ជាជំនួយខាងបច្ចេកទេស ដើម្បីដោះស្រាយឥទ្ធិពលដ៏មានសក្តានុពល នៃការចូលជាសមាជិក ក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងការបញ្ចប់របបកូតា កិច្ចព្រមព្រៀងពហុវាយភណ្ឌ (MFA) ដល់ស្ត្រីនៅក្នុងវិស័យកាត់ដេរ ដើម្បីរៀបចំគម្រោងជួយការពារស្ត្រីទាំងនោះ កុំឱ្យធ្លាក់ចូលក្នុងភាពក្រីក្រ ។

*ជំនួយការបច្ចេកទេស មានធាតុគន្លឹះសំខាន់ ៣គឺ :*

- ធ្វើការវិភាគស្ថានភាព
- ផ្តល់ថវិកា សំរាប់ការអនុវត្តន៍គម្រោងសាកល្បង ដើម្បីបង្កើតបណ្តាញ ហើយផ្សាភ្ជាប់ទៅនឹងឱកាសការងារមានជំរើស និងដើម្បីបង្កើត និងធ្វើតេស្ត វិធានការគាំពារសង្គមកិច្ចរយៈពេលខ្លី
- ពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល ផ្នែកឯកជន និងអង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហាគ្រោះថ្នាក់ដែលបណ្តាលមកពីការបញ្ចប់របបកូតាកិច្ចព្រមព្រៀងពហុវាយនភណ្ឌ (MFA) ។

ការវិភាគស្ថានភាពរួមមាន សិក្ខាសាលាដែលរៀបចំឡើងជាមួយដៃគូសំខាន់ៗ ការស្រាវជ្រាវដើម្បីបង្កើតឯកសារសង្គមសេដ្ឋកិច្ច សំរាប់កម្មករនៅក្នុងវិស័យកាត់ដេរ និងស្រាវជ្រាវច្បាប់ការងារ និងលក្ខខណ្ឌការងារ ។

កម្មវិធីសាកល្បង កំពុងតែប្រតិបត្តិបច្ចុប្បន្ននេះ ហើយរៀបចំដើម្បីផ្តល់ការអភិវឌ្ឍន៍ជំនាញលើកទឹកចិត្តឱ្យមានការសន្សំប្រាក់ និងអភិវឌ្ឍន៍បំនិនជំនាញ ដោយមានការចូលរួមពីកម្មករ ។ គម្រោងនេះ កំពុងតែគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលសកម្មភាពរួមមាន :

- បណ្តុះបណ្តាលបំនិនជំនាញ ក្នុងភាពដៃគូ ជាមួយអង្គការពលកម្មអន្តរជាតិ
- វគ្គណ្តុះបណ្តាល អភិវឌ្ឍន៍ជំនាញ ដើម្បីធ្វើឱ្យស្ត្រីមានលទ្ធភាពផ្លាស់ប្តូរទៅធ្វើការក្នុងផ្នែកផ្សេងៗ ដូចជាព័ត៌មានវិទ្យាទេសចរណ៍ សេវាកម្មនិងការកែច្នៃផលិតផលកសិកម្ម
- ក្រុមជួយខ្លួនឯង ដើម្បីលើកកំពស់ និងលើកទឹកចិត្តការសន្សំប្រាក់ក្នុងចំណោមស្ត្រី
- កម្មវិធីអភិវឌ្ឍន៍សហគ្រាស ដើម្បីគាំទ្រស្ត្រីក្នុងការបង្កើតអាជីវកម្មខ្នាតតូចផ្ទាល់ខ្លួន ។

លើសពីនេះទៅទៀត ការផ្ដួចផ្ដើមពីរ កំពុងតែផ្ដោតទៅលើការគ្រប់គ្រងរោងចក្រដើម្បីលើកកំពស់ លក្ខខណ្ឌការងារ ក្នុង ភាពជាដៃគូជា សមាគមផលិតផលរោងចក្រកាត់ដេរកម្ពុជា ( GMAC):

- ការបណ្ដុះបណ្ដាល អ្នកគ្រប់គ្រងធនធានមនុស្សក្នុងរោងចក្រ
- បង្កើតគោលការណ៍ណែនាំ (Guideline) ដើម្បីដោះស្រាយបញ្ហាពិសេស ដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារ ។

## អង្គការ CARE នៅកម្ពុជា-ការកាត់ដេរជាគម្រោងសំរាប់សុខភាពពេលអនាគត (Sewing a Healthy Future Project)

ការរីករាលដាលមេរោគហ៊ីវ(HIV) នៅក្នុងទេសកម្ពុជាមានកំរិតខ្ពស់ជាងគេ បើធៀបទៅនឹងប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ ។កម្មកររោងចក្រដែលភាគច្រើនជាស្ត្រីកំពុងតែប្រឈមមុខជាមួយគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារការធ្វើអន្តោប្រវេសន៍ក្នុងប្រទេស និងភាពមិនយល់ដឹងអំពីសុខភាពផ្លូវភេទ និងបន្តពូជ និងការទទួលបានសេវាកម្ម។ គម្រោងនេះកំពុងដំណើរការនៅក្នុងរោងចក្រចំនួន២៥ ដោយផ្ដោតចំពោះកម្មករចំនួន ៥០ ០០០នាក់ ក្នុងគោលដៅធ្វើឱ្យប្រសើរឡើងនូវសុខភាពផ្លូវភេទ និងបន្តពូជចំពោះកម្មករកាត់ដេរ ។ កម្មវិធីនេះ បានអនុវត្តសាកល្បង នៅឆ្នាំ ១៩៩៨ ជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៥ ដោយផ្ដោតទៅលើធាតុ បីសំខាន់ :

១-អភិវឌ្ឍន៏សមត្ថភាព ដល់អ្នកផ្ដល់សេវាសុខភាពក្នុងរោងចក្រ ដើម្បីផ្ដល់សេវាសុខភាពប្រកបដោយគុណភាពដល់កម្មករក្មេងៗ និងពង្រឹងបណ្ដាញបញ្ជូនសេវាបន្ត ទៅដល់អ្នកផ្ដល់សេវាសុខភាពនៅខាងក្រៅ ។

២-ផ្ដល់វិធីអប់រំសុខភាពនៅក្នុងរោងចក្រ ដោយបណ្ដុះបណ្ដាលកម្មករកាត់ដេរ ឱ្យក្លាយទៅជា ក្រុមអ្នកស្ម័គ្រចិត្តអប់រំសុខភាព និងជំរុញក្រុមបណ្ដាញក្រៅប្រព័ន្ធ នៅក្នុងរោងចក្រ ក្នុងគោលបំណងផ្សព្វផ្សាយព័ត៌មានអំពីសុខភាពផ្លូវភេទ និងបន្តពូជ និងធ្វើឱ្យប្រសើរឡើង នូវសេវាបញ្ជូនបន្ត ។

៣-រៀបចំការតស៊ូមតិ ជាមួយអ្នកគ្រប់គ្រងរោងចក្រដើម្បីលើកកំពស់ សុខភាពផ្លូវភេទ និងបន្តពូជនិងព័ត៌មានសំរាប់កម្មករ ។

គម្រោងបានទទួលជោគជ័យជាពិសេសនៅក្នុងការធ្វើការជាមួយអ្នកគ្រប់គ្រងរោងចក្រហើយនិងទទួលបានការគាំទ្រ និងលើកទឹកចិត្ត ឱ្យមានវគ្គបណ្ដុះបណ្ដាលអំពី ហ៊ីវ /អេដស៍ ( HIV/AIDs)ពីអ្នកគ្រប់គ្រង និងថែមទាំងបានបង្កើតគោលនយោបាយសំរាប់ ហ៊ីវ/អេដស៍នៅក្នុងរោងចក្រកាត់ដេរទៀតផង ។

## អង្គការពលកម្មអន្តរជាតិ

## គម្រោងកែលម្អលក្ខខណ្ឌការងារវិស័យកាត់ដេរ

បន្ថែមទៅលើការត្រួតពិនិត្យលក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរ ដើម្បីធ្វើការស្ទាបស្ទង់ទៅលើការអនុវត្តន៏តាមបទដ្ឋានការងារ អង្គការពលកម្មអន្តរជាតិ កំពុងតែរៀបចំសកម្មភាព ដោះស្រាយបញ្ហាផងដែរជាមួយរោងចក្រ ដើម្បីធ្វើឱ្យមានភាពប្រសើរឡើង នូវការអនុវត្តន៏លក្ខខណ្ឌការងារ ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកទិញធំៗ អ្នកគ្រប់គ្រងរោងចក្រ និងម្ចាស់រោងចក្រ ។ កម្មវិធីសាកល្បងថ្មីនេះ កំពុងតែដំណើរការ នៅក្នុងរោងចក្រចំនួន១៤ ដើម្បីធ្វើឱ្យមានភាពប្រសើរ នូវការអនុវត្តន៏ការងារនៅ ក្នុងឧស្សាហកម្ម រាប់បញ្ចូលទាំងការទំនាក់ទំនងរវាង អ្នកគ្រប់គ្រង និងនិយោជិត លក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងការកែប្រែរបៀបគ្រប់គ្រង ការធ្វើឱ្យប្រសើរឡើង នូវប្រព័ន្ធនិងដំណើរការដើម្បីឈានទៅរកការអនុវត្តន៏ទៅតាមច្បាប់ការងារនិងបង្កើនផលិតភាព ។អង្គការពលកម្មអន្តរជាតិកំពុងមានផែនការពង្រីកគម្រោងនេះ រហូតដល់២៨រោងចក្រ និងដោយបញ្ចូល បន្ថែមការផ្តោតសំខាន់ ទៅលើសិទ្ធិកម្មករ ព័ត៌មាន និងការអប់រំអំពីការយាយីផ្លូវភេទ។

## ស្ត្រីនៅក្នុងកម្មវិធីដើម្បីផ្លាស់ប្តូរ (WAC)

## គម្រោងវិស័យកាត់ដេរ

មានដើមកំណើតចេញពីអង្គការអុកស្វាមហុងកុង ស្ត្រីក្នុងកម្មវិធីដើម្បីផ្លាស់ប្តូរ (WAC) បច្ចុប្បន្នជាអង្គការឯករាជ្យមួយ ដែលធ្វើការពាក់ព័ន្ធជាមួយ ក្រុមសកម្មជនមូលដ្ឋានដែលមួយចំនួនជាស្ត្រីកម្ពុជា ដែលងាយរងគ្រោះ ក្នុងនោះមានស្ត្រីរកស៊ីផ្លូវភេទ និងកម្មកររោងចក្រ។

គម្រោងវិស័យកាត់ដេររោងចក្ររបស់ WAC ដែលផ្តោតលើការអប់រំ និងការប្រមូលផ្តុំកម្មការិនី ការចងក្រង ឯកសារ និងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ នៅក្នុងរោងចក្រកាត់ដេរ និងការបង្កើនការយល់ដឹងអំពីបរិបទអន្តរជាតិ ដែលថាវិស័យកាត់ដេរកម្ពុជាប្រតិបត្តិ នៅក្នុងក៏រិតមួយ ដែលទទួលឥទ្ធិពល ពីសកលភាវូបនីយកម្ម និងការចូលជាសមាជិកអង្គការពាណិកម្មពិភពលោក។ ស្ត្រីក្នុងកម្មវិធីដើម្បីផ្លាស់ប្តូរ (WAC) បានគាំទ្រនិងបង្កើត បណ្តាញកម្មការិនី ពីរោងចក្រមួយទៅរោងចក្រមួយទាំងនៅជុំវិញ និង ក្នុងទីក្រុងភ្នំពេញ ។ ស្ត្រីក្នុងកម្មវិធីដើម្បីផ្លាស់ប្តូរ (WAC) បានរៀបចំការិយាល័យក្នុងមជ្ឈមណ្ឌលនីមួយៗ ដែលស្ត្រីអាចមកសុំយោបល់និងការគាំទ្រ ។ គម្រោងក៏ផ្តោតទៅការផ្តល់សិទ្ធិអំណាចដល់ស្ត្រីការគាំទ្រកម្មកររោងចក្រ ឱ្យប្រាប់រឿងរ៉ាវរបស់ពួកគេផ្ទាល់ខ្លួន និងបញ្ចេញមតិយោបល់របស់ពួកគេ ដោយគ្មានអ្នកណាបង្ខំ ។ អង្គការនេះ ក៏បានរៀបចំ និងចូលរួមផងដែរ ក្នុងសកម្មភាពបង្កើនការយល់ដឹង អំពីលក្ខខណ្ឌការងារ និងអនាគតរបស់ស្ត្រីក្នុងវិស័យកាត់ដេរ ទាំងក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស ។ នេះរួមទាំងការឧបត្ថម្ភ កម្មករការិនី ដើម្បីឱ្យបានចូលរួមប្រជុំអន្តរជាតិស្តីពីឧស្សាហកម្មកាត់ដេរ និងចូលរួមក្នុងក្រុមសកម្មអន្តរជាតិ ឧទាហរណ៍ ជុំវិញពហុកីឡាឋានអូឡាំពិចជាដើម ។

# ឧបសម្ព័ន្ធ គ

## កំណត់សំគាល់ប្រភពឯកសារគន្លឹះធ្វើការសិក្សា នៅលើកម្មការិនីហើយ និង អនាគតឧស្សាហកម្មកាត់ដេរនៅកម្ពុជា

### ១, ស្រាវជ្រាវនៅលើស្ត្រីក្នុងឧស្សាហកម្មកាត់ដេរ ៖

អ្នកស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៍ (CRD) ២០០៤ និយោជិតកាត់ដេរនៅក្នុងកម្ពុជា ៖
ការស្ទាបស្ទង់សេដ្ឋកិច្ចសង្គម ដោយធនាគារអភិឌ្ឍន៍អាស៊ី នៅភ្នំពេញ
ទទួលបានពី ធានាគារអភិវឌ្ឍន៍អាស៊ី (មិនមាននៅក្នុងវេបសាយទេ)

ការស្រាវជ្រាវ ត្រូវបានអនុវត្តន៍ ដោយធានាគារអភិវឌ្ឍន៍អាស៊ី ដើម្បីផ្តល់ព័ត៌មានអំពីជំនួយបច្ចេកទេស(AT) ដែលបានរៀបចំដើម្បីកាត់បន្ថយ នូវឥទ្ធិពលនៃការបញ្ចប់របបកូតាឧស្សាហកម្មកាត់ដេរ ដែលនឹងប៉ះពាល់ចំពោះស្ត្រីហើយ វាជាការសិក្សាមួយដ៏ធំផងដែរ ទៅលើកម្មករក្នុងវិស័យកាត់ដេរបច្ចុប្បន្ន ។ ការស្រាវជ្រាវនេះ មានការចូលរួមពីកម្មករ ១៥៣៨នាក់ ក្នុង១០រោងចក្រផ្សេងគ្នា ដោយបែងចែកជា១០ក្រុម ។ ការស្រាវជ្រាវនេះ បានការសម្ភាសន៍ ជាមួយនឹង អ្នកផ្តល់ព័ត៌មាន(អ្នកឱ្យដំណឹង informant) ដែលអាចផ្តល់ព័ត៌មានច្បាស់ការណ៍ និងព្រមទាំងធ្វើការសង្កេតនៅក្នុងតំបន់ ដែលបានជ្រើសរើសនេះផងដែរ ។ ការសិក្សាក៏បានផ្តោតទៅលើចរិតលក្ខណៈសេដ្ឋកិច្ចសង្គមរបស់កម្មកររោងចក្រកាត់ដេរទៅ លើទឹកចិត្តរបស់ពួកគេ ចំពោះការបន្ត និងការបោះបង់ចោលការងាររោងចក្រ ព្រមទាំងបានសិក្សា ទៅលើចំនួនកម្មករចេញចូល និងសេចក្តីប្រាថ្នារបស់ពួកគេ សំរាប់ពេលអនាគត ។ គំហើញបានមកពីការស្រាវជ្រាវ ត្រូវបានគេយកទៅប្រើដើម្បីបង្កើតកម្មវិធីសាកល្បងក្នុងការគាំទ្រស្ត្រី ឱ្យត្រៀមខ្លួនចំពោះរយៈពេល អន្តរកាល ដែលកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការបញ្ចប់របបកូតា (សូមមើលនៅ ក្នុងឧបសម្ព័ន្ធ ខ) ។

លោក ជា ហ៊ួត និង លោក សុខ ហាច ២០០១ « ឧស្សាហកម្មកាត់ដេរកម្ពុជា » ទស្សនៈអភិវឌ្ឍន៍ កម្ពុជា លេខ៥ (៣) ខែកក្កដា ដល់ ខែកញ្ញា ២០០១ , CDRI , ភ្នំពេញ។ លោកសុខហាច et al ២០០១ ឧស្សាហកម្មកាត់ដេរនៅកម្ពុជា៖ ការអនុវត្តន៍ការងារ ការប្រឈមមុខ និងគោលនយោបាយ ទំព័រទី ៤៧-៦២ ទស្សនៈសេដ្ឋកិច្ចប្រចាំឆ្នាំកម្ពុជា ២០០១ CDRI ភ្នំពេញ
អាចរកបានឯកសារ CDRI វេបសាយ៖ WWW. cdri.org.kh, CDRI library

អ្នកស្រាវជ្រាវ CDRI បានធ្វើការពិនិត្យឡើងវិញនូវការចងក្រង និងសម្ភាសន៍យ៉ាងស៊ីជម្រៅ ជាមួយម្ចាស់រោងចក្រ មន្ត្រីរដ្ឋាភិបាល កម្មកររោងចក្រ ហើយនិងមេដឹកនាំសហជីព ។ គំហើញ នៃការស្រាវជ្រាវនេះ គឺស្របទៅជាមួយនឹងការ សិក្សាផ្សេងៗទៀតដែលធ្វើជាមួយកម្មករ ក្នុងវិស័យកាត់ដេរដែរ ។ អ្នកនិពន្ធទាំងអស់ បានសន្និដ្ឋានថាការធ្វើឱ្យប្រសើរ

ឡើង នៃបទបញ្ញត្តិរបស់រដ្ឋាភិបាល ដើម្បីលុបបំបាត់នូវអ្វីដែលធ្វើឱ្យបាក់ទឹកចិត្ត និងកាត់បន្ថយការពន្យាពេលក្នុងការពង្រឹងការអនុវត្តន៍ច្បាប់ការងារ ការបង្កើនផលិតភាព ហើយនិងគុណភាពនៃផលិតផលកាត់ដេរការបង្កើនសមាជិកភាព ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ការកាត់បន្ថយតម្លៃសេវាសាធារណៈ (ទឹក ភ្លើង ទូរស័ព្ទ) និងតម្លៃដីធ្លីនិងការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននឹងធ្វើឱ្យមានទីផ្សារនាំចេញចំរុះដើម្បីធានាឱ្យបានថា ឧស្សាហកម្មកាត់ដេរនៅកម្ពុជា នៅតែអាចប្រកួតប្រជែងជាមួយទីផ្សារអន្តរជាតិបាននាពេលអនាគត ។

អិងគ្វិសថ៏(Engquist), អឹម ( M ) ២០០១ ការធ្វើឱ្យផលិតកម្មកាត់ដេរនៅមានតម្លៃ : ការស្ទាបស្ទង់ ទៅលើចលនាក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា, ភ្នំពេញ

ឯកសារបានមកពីបណ្ណាល័យ CDRI

ការសិក្សានេះ បានផ្តោតទៅលើចលនាសហជីពកម្មករ ក្នុងប្រទេសកម្ពុជា ដោយរាប់បញ្ចូលទាំង ការស្ទាបស្ទង់ទៅលើលក្ខខណ្ឌការងារ នៅក្នុងរោងចក្រកាត់ដេរ ។ របាយការណ៏ បានបង្ហាញឱ្យឃើញថា លក្ខខណ្ឌការងារក្នុងរោងចក្រ គឺស្ថិតនៅក្រោមក៏រិតបទដ្ឋាន ដូចជាការបង្ខំឱ្យធ្វើការថែមម៉ោង ការយាយី ផ្លូវភេទ បរិយាកាសការងារអាក្រក់ ពុំមានអនុញ្ញាតឱ្យឈប់សំរាក( ថ្ងៃបុណ្យ រៀបការ) ការចងស្រងបណ្តេញកម្មករតាមទំនើងចិត្ត ហើយនិងការអាក់ខានមិនបើកប្រាក់ដ៏តិចតួចក្លាយទៅជាបញ្ហាធម្មតា របស់និយោជកទៅហើយ ។

អង្គការឃែ អន្តរជាតិ ១៩៩៩ កាត់ដេរសំលៀកបំពាក់ដើម្បីអនាគតដ៏ប្រសើរ ឃែរ ភ្នំពេញ Available from: CDRI library

នេះ គឺជាការសិក្សាដ៏តូចមួយ ជាមួយកម្មករចំនួន ៧៧នាក់ នៅក្នុងរោងចក្រចំនួន៣ ដែល គេធ្វើឡើង ដើម្បីឱ្យគម្រោងកម្មវិធីផ្លូវភេទ និងសុខភាពបន្តពូជមានលក្ខណៈពិសេស ។ គម្រោងនេះ កំពុងអនុវត្តដោយអង្គការឃែរកម្ពុជា (សូមមើលឧបសម្ព័ន្ធខ) ។ ទោះបីការសិក្សានេះ បានផ្តោតទៅលើឥរិយាបថ និងការអនុវត្តន៏ពាក់ព័ន្ធទៅនឹងសុខភាពផ្លូវភេទការសិក្សាក៏មានការពិភាក្សាផងដែរ អំពីលក្ខខណ្ឌការងារ និងបទពិសោធន៏កម្មករនៅក្នុងរោងចក្រ ។ ការសិក្សាបានបង្ហាញឱ្យឃើញថា ខណៈដែលភាពក្រីក្រ ជាកម្លាំងចលករមួយបង្ខំឱ្យក្មេងពេញវ័យសំរុកមកធ្វើការងារ នៅតាមរោងចក្រកាត់ដេរនៅទីក្រុង អ្នកដែលត្រូវផ្ញើលុយទៅផ្ទះ នឹងត្រូវធ្វើការយ៉ាងខ្លាំង ដើម្បីទទួលបាននូវប្រាក់ឈ្នួល ដែលអាចចិញ្ចឹមជីវិតខ្លួនឯងផង ផ្ញើទៅគ្រួសារខ្លួនផង ។ កម្មករជាច្រើនមានបំណងចង់ផ្លាស់ប្តូរ ការងាររបស់គេ ដើម្បីទទួលបាននូវប្រាក់ចំណូលច្រើន ។

**ហ្គតមែនស៊ីអូហែន (Gorman,Siobhan) ១៩៩៧ ប្រសិទ្ធភាពនៃការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គមសំរាប់ការងារស្ត្រីក្នុងកម្ពុជា : ករណីសិក្សានៃកម្មកររោងចក្រកាត់ដេរ មជ្ឈមណ្ឌលសំរាប់ការអប់រំកំរិតខ្ពស់ និងមនុស្សពេញវ័យ ម៉ាំឆែសស្ទើរ (Manchester)**

**ឯកសារបានមកពី បណ្ណាល័យ ស៊ីឌី អ អាយ (CDRI)**

ការសិក្សាតូចនេះ ផ្អែកទៅលើការសម្ភាសន៏ពាក់កណ្តាលរចនាសម្ព័ន្ធ (emi-structured inter-views) ជាមួយកម្មករ នៅក្នុងរោងចក្រ២ ក្នុងទីក្រុងភ្នំពេញ ហើយនិងសម្ភាសន៏ជាមួយសមាជិក គ្រួសារនៃអ្នកទាំងនោះ ។ គំឃើញពីការស្រាវជ្រាវនេះ ត្រូវបានគេបញ្ជាក់ដូចមាននៅក្នុង ការសិក្សាស្រាវជ្រាវ របស់ធនាគារអភិវឌ្ឍន៏អាស៊ី ដែលធ្វើការស្រាវជ្រាវលម្អិត ជាមួយនឹងជំរើស នូវអ្នកដែលត្រូវ សម្ភាសន៏ក្នុងចំនួនច្រើន (large survey samples) ។ គំហើញនេះ មានរៀបរាប់អំពី ការសង្កេតដែលថា ស្ត្រីមានបំណងវិលត្រឡប់ទៅស្រុកពួកគេវិញ ដើម្បីបន្តធ្វើស្រែចំការនិងបង្កើតមុខរបរខ្លួនឯង តែពួកគេខ្វះ ជំនាញ និងដើមទុន ។

## ២. អនាគតនៃ ឧស្សាហកម្មកម្ពុជា និងឥទ្ធិពល នៃសាកលភាវូបនីយកម្ម

**ប៊ើរ៉េសហ្វត អឹម អេ អល ២០០៤ (Beresford, M.et al 2004) ម៉ាក្រូសេដ្ឋកិច្ច សំរាប់កាត់បន្ថយភាពក្រីក្រនៅកម្ពុជា កម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ (*UNDP*) ភ្នំពេញ**

ការសិក្សាយូអិនឌីភី នេះផ្តល់យោបល់ថា បច្ចុប្បន្ននេះ ការផ្តល់ជំនួយរបស់ម្ចាស់មូល និធិសំរាប់ ការវិនិយោគទៅលើវិស័យកសិកម្មនៅកម្ពុជា គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយដែលថាការរីកចំរើនបច្ចុប្បន្នផ្នែកសេវាកម្ម និងឧស្សាហកម្មដែលផ្តល់ប្រយោជន៏បន្តិចបន្តួច ចំពោះប្រជាជនកម្ពុជា គឺមាន តែនៅទីក្រុងប៉ុណ្ណោះ ។ ការសិក្សានេះបានអះអាងថា វិស័យកាត់ដេរបានផ្តល់ឱកាស ដ៏តូចចង្អៀត ចំពោះស្ត្រី ដែលនឹងត្រូវបានគេរឹតបន្តឹងថែមទៀត ដោយសារតែការបញ្ចាប់កូតា និងការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក ។ ការមានមូលដ្ឋានគ្រឹះនាំចេញដ៏តិចតួច ធ្វើឱ្យកម្ពុជាពិបាកនឹងធ្វើការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ជាពិសេសប្រទេសដទៃ១ ដូចជាប្រទេសចិន ។ យុទ្ធសាស្ត្រដើម្បីគាំពារឧស្សាហកម្ម រួមមានការបង្កើតទំនាក់ទំនងគ្នាទៅវិញទៅមក ផលិតកម្មផលិតផលសំរេច ការកាត់បន្ថយពេលវេលាក្នុងការនាំចេញ វិនិយោគក្នុងការអភិវឌ្ឍន៏ជំនាញ សំរាប់កម្លាំងពលកម្មបច្ចុប្បន្ន និង បង្កើតឱ្យមានមូលដ្ឋានឧស្សាហកម្មចំរុះនៅកម្ពុជា ។ ការធានាថាស្ត្រីត្រូវបានគេជួយដោះស្រាយ តាមយុទ្ធសាស្ត្រខាងលើ ជាការធានាមួយដ៏សំខាន់ ក្នុងការនាំឱ្យស្ត្រី អាចទាញយកផលប្រយោជន៏ពីឱកាសថ្មី ដែលនឹងកើតឡើង ហើយអាចប្រយុទ្ធជាមួយនឹងភាពក្រីក្របានទៀតផង ។

**មូលនិធិរូបិយប័ណ្ណអន្តរជាតិ ២០០៤ (IMF 2004) កម្ពុជា : របាយការណ៍សន្និដ្ឋាន សំរាប់ការពិភាក្សាពិគ្រោះយោបល់ មាត្រា ៤ ២០០៤ អាយ អឹម អែស (The 2004 Article IV Consultation Discussion)**

មូលនិធិរូបិយប័ណ្ណអន្តរជាតិ ផ្តល់នូវការទស្សន៍ទាយយ៉ាងត្រឹមត្រូវ អំពីភាពអ័ព្ទអួរ ដែលលើកឡើងថា វានឹងមានការមិនសូវរីកចំរើន ក្នុងឆ្នាំ ២០០៥ ដែលបណ្តាលមកពីការបំបាត់នូវប្រព័ន្ធកូតា ការប្រឈមមុខ នឹងការប្រកួតប្រជែង ដោយផ្ទាល់ជាមួយនឹងបណ្តាប្រទេសជិតខាង ។ ការលូតលាស់អាចមាន ត្រឹមតែ ពី ២ ដល់ ៦ភាគរយ ក្នុងមួយឆ្នាំ តែប៉ុណ្ណោះសំរាប់រយៈពេលខ្លី ។

**ណារ៉ុង ហង្សឈុន ២០០២ ឥទ្ធិពលនៃការចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ទៅលើសហគ្រាសធុនតូច និងមធ្យម ( SME ) និងវិស័យកាត់ដេរ នៅកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ភ្នំពេញ**

លោកបណ្ឌិត ហេងឈុនណារ៉ុង បានផ្តល់នូវការវិភាគយ៉ាងពិស្តារ ចំពោះអនាគតឧស្សាហកម្ម កាត់ដេរដោយបានបរិយាយឡើងវិញ អំពីឯកសារចំណាយរបស់រដ្ឋាភិបាលកម្ពុជា (មាននៅខាងក្រោម) ។ ប្រទេសចិនត្រូវបានគេមើលឃើញថាជាឧបសគ្គមួយដ៏ធំសំរាប់ការនាំចេញ នូវផលិតផលកាត់ដេរកម្ពុជា រួមទាំងឧបសគ្គខាងក្នុង មួយចំនួនទៀត ដូចប្រាក់ខែតិចតួច ការចំណាយ សំរាប់ការអនុវត្តនីបទដ្ឋាន ដើម្បីឱ្យស្របទៅនឹងបទដ្ឋានរការងារ និងការរឹតបណ្តឹងការផ្លាស់ប្តូរវេនធ្វើការ ។ យុទ្ធសាស្ត្រ ដែលមាននៅក្នុងឯកសារនេះ មានរាប់បញ្ចូលទាំងការដោះស្រាយការចំណាយលើកម្លាំងពលកម្មហេដ្ឋារចនាសម្ព័ន្ធ និងការចំណាយលើការប្រើប្រាស់សេវាសាធារណៈ (ទឹកភ្លើង) ការបង្កើតទីផ្សារ ដោយគ្មានរបបកូតា និងការបង្កើតតំបន់កែច្នៃនាំចេញ ដើម្បីទាក់ទាញ វិនិយោគបរទេស ។

**រាជរដ្ឋាភិបាលកម្ពុជា ២០០៤ គម្រោងផែនការចំណាយ រយៈពេលមធ្យមសំរាប់សេចក្តីព្រាង របស់កម្ពុជាឆ្នាំ ២០០៥-២០០៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភ្នំពេញ**

សេចក្តីព្រាងគម្រោងផែនការចំណាយ អមដោយការវិភាគពិស្តារលើវិស័យកាត់ដេរ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង លើវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ដោយឈរលើមូលដ្ឋាន នៃការលូតលាស់ ដ៏តិចតួចនៃសេដ្ឋកិច្ច។ ដោយសារការនាំចេញ នូវវិស័យកាត់ដេរ មានការធ្លាក់ចុះ ការលុបចោលកូតា នឹងនាំឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងដល់វិស័យឧស្សាហកម្ម ការប្រឹងប្រែងកាត់បន្ថយ ការចំណាយលើវិស័យឧស្សាហកម្ម រាប់បញ្ចូលទាំងការចំណាយលើតម្លៃពលកម្ម សេវាកម្មសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ ជាការសំខាន់បំផុត។ ការពង្រីកកំរិត នៃផលិតកម្ម និងទីផ្សារក៏ជាការសំខាន់ផងដែរ ។ ការប្រកួតប្រជែង ជាមួយប្រទេសចិន វានឹងជារបៀបវារៈមួយដ៏សំខាន់ ហើយវានឹងមានផលវិបាកមួយចំនួនដូចជា ការបាត់បង់ ការនាំចេញ ការបាត់បង់ការងារ ការផ្តល់ប្រាក់ឈ្នួលទាបដល់កម្មករ នៅក្នុងវិស័យកាត់ដេរ ។ គេព្យាករណ៍

ថាការធ្លាក់ចុះដ៏ខ្លាំងនេះ នឹងកើតមាននៅឆ្នាំ ២០០៥ ដោយសារមាន មួយភាគបី នៃក្រុមហ៊ុន នឹងបិទទ្វារ ដែលពេលនេះ ទន្ទឹមនឹងក្រុមហ៊ុនធំៗ មួយចំនួននឹងស្រូបយកភាគហ៊ុនទីផ្សារដែលកំពុងតែមាន ក្រុមហ៊ុនមួយចំនួន នឹងត្រូវផ្លាស់ប្តូរទីតាំង ដូចជា ទៅប្រទេសថៃជាដើម ។ គេបានព្យាករណ៍ថា បើសិនជាការកែទម្រង់ មិនត្រូវបានគេអនុវត្តទាន់ពេលទេនោះ វិស័យនេះ និងមិនអាចគេចផុតពីបញ្ហានៅឆ្នាំ២០០៥ នោះឡើយ ហើយក្រុមហ៊ុន ដែលមានចំណែក ក្នុងការផលិតរហូតដល់៣០ភាគរយ នៃទិន្នផលរួម នឹងត្រូវបង្ខំចិត្តបិទទ្វារ ។

## សាលីងជើរអែល ២០០៤ (SalingerL.2004) ការយល់ដឹង និងការមិនយល់ដឹងអំពី ការប្រឈមមុខ របស់វិស័យកាត់ដេរនៅកម្ពុជា បន្ទាប់ពីឆ្នាំ ២០០៤ : លទ្ធផលនៃការពិនិត្យមើលឱកាសសំរាប់បេសកកម្ម របស់ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក

ឯកសារពិនិត្យមើលឱកាស ដែលចងក្រងដោយ ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក ដើម្បីស្វែងយល់អំពីទំហំនៃការវិភាគ និងការគាំទ្រ ដែលម្ចាស់មូលនិធិ និងភ្នាក់ងារដទៃៗទៀត កំពុងតែផ្តល់ឱ្យទៅវិស័យកាត់ដេរ ក្នុងគោលបំណងកំណត់យកចំណុចវិភាគបន្ថែម លើកិច្ចការណាមួយ ដែលទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក អាចចូលរួមចំណែក។ ឯកសារនេះ កំណត់នូវទំហំនៃការសិក្សា និង អន្តរាគមន៍ ដែលរួមចំណែកក្នុងការពិនិត្យ នូវបទដ្ឋានប្រកួតប្រជែង ក្នុងនោះមានទស្សនៈវិស័យទៅលើវិស័យកាត់ដេរ ផលប៉ះពាល់នៃសង្គម និងពលកម្ម ការវិភាគទៅលើការប្រែប្រួលតម្លៃក្នុងការចំណាយ (value-chain cost analysis) កាវិភាគទៅលើស្ថាប័ន ការវិភាគទៅលើម៉ាក្រូសេដ្ឋកិច្ច និងការវិភាគលើទំនាក់ទំនងនៃ ការលួតលាស់ ។ ឯកសារនេះ វិភាគទៅលើ ទំហំនៃការធ្វើអន្តរាគមន៍ ដោយកំណត់យកអ្នកគ្រប់គ្រង និងនិយោជិតរោងចក្រជាក្រុមគោលដៅ ។ ឯកសារនេះ មានស្នើឡើងថា កិច្ចការពីរដែលទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក អាចចូលរួមចំណែក (១) គឺការសិក្សាមួយដើម្បីយល់ដឹងថា កត្តាអ្វីខ្លះ ដែលចូលរួមចំណែក ទៅលើសំរាប់ផលិតភាពពលកម្ម ដែលក្នុងនោះរួមមាន ការអភិវឌ្ឍន៏កម្លាំងពលកម្ម (២) ធ្វើការស្រាវជ្រាវអំពីរបៀប ដែលជួយបង្កើននូវជំនាញក្នុងការឈានចូលទៅដល់ទីផ្សារពិភពលោក នៃរោងចក្រសរសៃអំបោះ វាយនភណ្ឌ និងកាត់ដេរ ។

## ក្រុមធនាគារពិភពលោក ឆ្នាំ ២០០៤កម្ពុជា : ការចាប់យកឱកាសពិភពលោក : បរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកែទំរង់

របាយការណ៍នេះ បានរៀបចំឡើង ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពទៅលើ ការបង្កើតឡើង នូវគម្រោងយុទ្ធសាស្ត្រវិស័យឯកជន ដោយរាប់បញ្ចូលទាំងគម្រោងសកម្មភាព ១២ចំនុច ដែលអនុម័តដោយរដ្ឋាភិបាល កម្ពុជា ក្នុងការសម្របសម្រួលចំពោះការអភិវឌ្ឍន៍ ផ្នែកឯកជន នៅកម្ពុជាឱ្យមានភាពមាំមួន ។ របាយការណ៍នេះ បានពិភាក្សាលើអន្តរាគមន៍គន្លឹះពីរ ដើម្បីពង្រឹងវិស័យឯកជននិងដើម្បីបង្កើនការលូតលាស់ មានន័យថាការបង្កើតឧស្សាហកម្មចំរុះនិងបង្កើនអត្រានៃផលិតផល ។

ទោះបី កំណើនផលិតផល សរុប(GDP) ក្នុងមួយឆ្នាំមានពី ៥ភាគរយទៅ ៦ភាគរយក៏ដោយ ការលូតលាស់នៅកម្ពុជា ត្រឹមកំរិតនេះពុំបានជួយកាត់បន្ថយភាពក្រីក្រនៅឡើយ ។ កត្តានេះ គឺដោយសារតែកំរិតនៃការរីកចម្រើន មានតិចតួច ជាពិសេសនៅក្នុងវិស័យកាត់ដេរតែម្តង ។ ម្យ៉ាងវិញទៀត ការលូតលាស់ដ៏តិចតួចនេះ ក៏ពុំបានធ្វើឱ្យមានការប្រែប្រួល ទៅលើវិស័យកសិកម្ម ដែលមានកសិករ៨០ភាគរយនៃប្រជាជនទាំងមូល ហើយក្នុងនោះ ក៏មានអ្នកក្របំផុតផងដែរ ។ របាយការណ៍បានលើកឡើងថា ការលូតលាស់ក្នុងវិស័យកាត់ដេរ អាចទទួលរងនូវឥទ្ធិពលពីការបញ្ចប់កូតា ហើយបានលើកឡើងថា ឥទ្ធិពលជាសក្តានុពលទាំងនេះ អាចមានទាំង ការប្រកួតប្រជែង ដោយមានការចំណាយដ៏ច្រើន និងផ្នែកមួយដែលមានរោងចក្រពីរបី និងច្រើនបញ្ចូលគ្នា ។

បើសិនជា យុទ្ធសាស្ត្របន្ថែមទាក់ទងនឹងគុណតម្លៃ ដូចជាការរៀបចំឱ្យឧស្សាហកម្មមានការទទួលខុសត្រូវលើសេវាសង្គមកិច្ច អាចត្រូវបានគេយកទៅប្រើដើម្បីជួយគាំពាររោងចក្រនោះ ជំនាញបច្ចុប្បន្នពុំទាន់គ្រប់គ្រាន់សំរាប់ការអនុវត្តនីគំនិតផ្តួចផ្តើមនេះឡើយ ។

## ៣. ឯកសារយោងបន្ថែម :


- អានស៊ូថាណាសម្បត្តិ ខេ អេ អល ២០០១ (Angsuthanasombat, K. et all 2001) ស្ថានភាព ហើយនិងករណីសិក្សាស្តីពីកម្លាំងពលកម្មក្រៅប្រព័ន្ធក្នុងក្រុងបាងកក ។ លទ្ធផល នៃវិបត្តិសេដ្ឋកិច្ច គណៈកម្មការដើម្បីស្ត្រីនៅអាស៊ី បាងកក ។
- អាចារីយ៉ា អេ អល ២០០៣ ( Archarya, S. et all 2003 ) ការបំរើការងារ នៅក្រៅកសិដ្ឋាន និងមិនមែនក្នុងកសិដ្ឋាន (off-farm and non-farm employment): ទស្សនៈវិស័យលើការបង្កើនការងារក្នុងប្រទេសកម្ពុជា ឯកសារការងារ ២៦វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា ភ្នំពេញ ។
- ធនាគារអភិវឌ្ឍន៍អាស៊ី ទស្សនៈវិស័យអភិវឌ្ឍន៍អាស៊ាន ២០០៤អេ(2004a) ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីល ។
- ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៤អេ ជំនួយការបច្ចេកទេស ចំពោះសាធារណរដ្ឋបង់ក្លាដេស ដើម្បីការពារសង្គមកិច្ចកម្មការិនីក្រីក្រក្នុងរោងចក្រកាត់ដេរ ក្នុងបរិបទនៃគម្រោងផ្លាស់ប្តូរបរិស្ថាន ពាណិជ្ជកម្មអន្តរជាតិ ធានាគាអភិវឌ្ឍន៍អាស៊ី ទីក្រុង ម៉ានីល ។
- ធនាគារអភិវឌ្ឍន៍អាស៊ី២០០៣ ជំនួយការបច្ចេកទេស ចំពោះព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារភាពក្រីក្រ និងផ្តល់សិទ្ធិអំណាចដល់កម្មការិនីរោងចក្រ ដែលប៉ះពាលដោយសារបរិស្ថាន ពាណិជ្ជកម្មពិភពលោកមានការផ្លាស់ប្តូរ ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីល ។
- ធនាគារអភិវឌ្ឍន៍អាស៊ី ២០០២ ជំនួយការបច្ចេកទេស ចំពោះព្រះរាជាណាចក្រកម្ពុជា សំរាប់ការ លើកតម្កើងការងារប្រកបដោយនិរន្តរភាព ចំពោះស្ត្រី ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីល ។

- ធនាគារអភិវឌ្ឍន៍អាស៊ី ២០០១ ការស្ទាបស្ទង់ភាពក្រីក្រដោយមានការចូលរួម ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីល ។
- ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៣ ជំនួយបច្ចេកទេស ដល់ព្រះរាជាណាចក្រកម្ពុជាដើម្បីបង្ការភាពក្រីក្រ និងផ្តល់សិទ្ធិអំណាចដល់កម្មការិនីកាត់ដេរដែលប៉ះពាល់ដោយការផ្លាស់ប្តូរស្ថានភាពពាណិជ្ជកម្ម ជាអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ី២០០២ ជំនួយបច្ចេកទេសដល់ព្រះរាជាណាចក្រកម្ពុជាសំរាប់លើកកំពស់ការងារជានិរន្តរភាព ដល់នារីក្រីក្រ ADB Manila
- ធនាគារអភិវឌ្ឍន៍អាស៊ី២០០១ ការប៉ាន់ប្រមាណមើលនូវភាពក្រីក្រនៅកម្ពុជាដែលមានការចូលរួម ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីល ។
- ប៊ីយូហ្វិល អិល ២០០០( Beautifils L 2000 ) បញ្ហាកំណើនប្រជាពលរដ្ឋ នៅកម្ពុជា :ការសិក្សា មួយលើបញ្ហាភេទ សុខភាពបន្តពូជ និងការពាក់ព័ន្ធ និងអត្រាកំណើនប្រជាពលរដ្ឋ ដោយផ្តោតលើ កម្ពុជា យូអិនអែហ្វភីអេ ( UNFPA ) ភ្នំពេញ ។
- ប៊ូជ អិន និងអល ២០០៣ ( Bouche, N. et al 2003 ) ការវាយតម្លៃលើការប៉ះពាល់លើសង្គម (Social Impact Assessment) នៅខេត្តកោះកុងៈ គម្រោងតំបន់ កំពុងមានដំណើរនាំចេញ សេចក្តី ព្រាងរបាយការណ៍ចុងក្រោយ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ។
- កាហ្គេតេ លេខ ២០០១ យេនឌ័រ (Catgatay N 2001 Gender) ភាពក្រីក្រ និង ពាណិជ្ជកម្មកម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ យែនីវ៉ា ។
- អង្គការយៃរ កម្ពុជា២០០២ក្រុមជួយសង្គ្រោះដោយឱសថព្យាបាលទាន់ពេលដែលមានសមាជិក៩ នាក់ : សុខមាលភាពក្នុងរោងចក្រកាត់ដេរ : ការវាយតម្លៃនិងការប្រៀបធៀបគម្រោងសុខភាពផ្លូវភេទនិងបន្តពូជ ក្នុងរោងចក្រដែលមានការអន្តរាគមន៍និងគ្មានអន្តរាគមន៍ អង្គការយៃរកម្ពុជា : ភ្នំពេញ
- ចាន់ សុផល និងសូ សុវណ្ណារិទ្ធិ ១៩៩៩ : កម្មករកម្ពុជាធ្វើអន្តោប្រវេសន៍ទៅប្រទេសថៃ : វាយតម្លៃ លើកដំបូងមាននៅក្នុងឯកសារការងារ ១១ វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកម្ពុជា ២០០៤ : សន្ទស្សន៍ការត្រួតពិនិត្យ ការអភិវឌ្ឍន៍ភាពក្រីក្រកម្ពុជា (CPDMI) និយមន័យ និងប្រភពទិន្នន័យ រៀបចំដោយក្រុមជំនួយការបច្ចេកទេស វិភាគនិងការត្រួតពិនិត្យភាពក្រីក្រ (នឹងមានចេញផ្សាយពេលខាងមុខ )
- យេនឌ័រ និងការអភិវឌ្ឍន៍សំរាប់កម្ពុជា ២០០២ៈ យេនឌ័រ នៅក្នុងការអប់រំនិងវគ្គបណ្តុះបណ្តាល វិជ្ជាជីវៈ និងបច្ចេកទេស ភ្នំពេញ

ហ្គតហ្វ្រេ អឹម អេ ២០០១ ( Godfrey, M. et at 2001) ការសិក្សាលើពលកម្មទីផ្សារកម្ពុជា: យោងទៅលើឯកសារដើម្បីកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការដោះស្រាយវិបត្តិ ឯកសារការងារ ១៨ វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( CDRI ) ភ្នំពេញ

ហ្គមែន ស៊ីបហែន អេ អល ១៩៩៩ ( Gorman, Siobhan et al 1999 ) យេនឌ័រ និងការ អភិវឌ្ឍន៍នៅកម្ពុជា : ទស្សនៈឯកសារការងារ ១០ វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា ភ្នំពេញ

ហ្គតថូស្កា ២០០១ ( Gohoskar, S. 2001 ) ស្ត្រីក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ នៅអាស៊ីអាគ្នេយ៍ : ការ ពិនិត្យ លើអក្ខរភាពគណៈកម្មការសំរាប់ស្ត្រីនៅអាស៊ាន បាងកក

ការកាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០០ របស់អង្គការពលកម្មអន្តរជាតិ តាមរយៈការអភិវឌ្ឍន៍ សហគ្រិនខ្នាតតូច និងម៉ាក្រូ នៅក្នុងប្រទេសកម្ពុជា អង្គការពលកម្មអន្តរជាតិ បាងកក។

ណដាស ហុង កុង ២០០៤ (Nordas, HK. ២០០៤) ឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌពិភពលោក ចុះកិច្ចសន្យាទៅលើវិស័យកាត់ដេរ និងវាយនភណ្ឌ អង្គការពាណិជ្ជកម្មពិភពលោក (WTO) ហ្សឺនីវ៉ា ។

នូរីន អេ ២០០២ ( Nurin, A. 2002) ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅអាស៊ី តាមរយៈការងារចក្ខុវិស័យដ៏ត្រឹមត្រូវអង្គការពលកម្មអន្តរជាតិ (ILO) ហ្សឺនីវ៉ា។

អុកស្វាម អន្តរជាតិ ២០០៤ អេ ពាណិជ្ជកម្មស្ថិតនៅឆ្ងាយពីសិទ្ធិរបស់យើង អុកស្វាមអន្តរជាតិ អុកស្វត

អុកស្វាមអន្តរជាតិ ២០០៤ប៊ី ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក របស់ប្រទេសកម្ពុជា : របៀបដែលគេអនុវត្តច្បាប់ ទៅលើប្រទេសមួយ ដែលក្រីក្រជាងគេនៅក្នុងពិភពលោក? អុកស្វាមអន្តរជាតិ អុកស្វត

អុកស្វាមអន្តរជាតិ ឆ្នាំ ២០០១ ការធ្វើឱ្យប្រសើរឡើងនូវពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ អុមស្វាមអន្តរជាតិ អុកស្វត

ភីត អឹម អេ អល ២០០៣ ( Pitt, M., et al 2004) តើឥណទានខ្នាតតូច ផ្តល់អំណាចដល់ស្ត្រីទេ? ភស្តុតាងពីប្រទេសបង់ក្លាដេស ការអភិវឌ្ឍន៍ជនបទនៃក្រុមអ្នកស្រាវជ្រាវដើម្បីអភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍ពិភពលោក វ៉ាស៊ីនតោន

រដ្ឋាភិបាលនៃប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០៣ ប្រទេសកម្ពុជា : យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០៣-២០០៤ របស់រដ្ឋាភិបាលកម្ពុជា ភ្នំពេញ

សម្តេច ហ៊ុន សែន ២០០៤ សុន្ទរកថាស្តីពី "យុទ្ធសាស្ត្រចតុកោណ" ដើម្បីការរីកចម្រើន ភាពមានការងារធ្វើ យុត្តិធម៌ សមភាព និងភាពប្រសើរ កិច្ចប្រជុំគណៈរដ្ឋមន្ត្រីទី១ នីតិកាល ទី៣ នៃរដ្ឋសភាជាតិ នៅការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី ភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤។

ឯកឧត្តម សុខ ស៊ីផាណា ២០០៣ យូណែសស្កែប "UNESCAP សិក្សាទៅលើការចូលជា សមាជិកអង្គការពាណិជ្ជកម្មពិភពលោក:(WTO)" "ការសិក្សាអំពីប្រទេសកម្ពុជា:" អត្ថបទនេះ បង្ហាញអំពី ការដាក់បញ្ចូលគ្នានៃគម្រោង និងការចូលរួមជា

មួយអង្គការពាណិជ្ជកម្មពិភពលោក *(WTO)* កិច្ចប្រឹងប្រែង និងឱកាសសំរាប់កាត់បន្ថយភាពក្រីក្រ នៅថ្ងៃទី ១-៣ ខែឧសភា ឆ្នាំ ២០០៣ ភ្នំពេញ ។

- យូណេសស្កេប អេ អល ២០០៤បី ( UNESCAP et al 2004a ) ការបែងចែកសិទ្ធិស្មើគ្នាសំរាប់ស្ត្រី : តម្រូវការសកម្មភាពដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ សំរាប់ស្ត្រី និងបុរស យូនីហ្វាម ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិអភិវឌ្ឍន៍សហប្រជាជាតិ ឌីហ្វីត ( DFID/UK ) ភ្នំពេញ
- យូនីហ្វាម អេ អល ២០០៤បី ( UNIFEM et al 2004 b ) ការចែករំលែកស្មើគ្នាសំរាប់ស្ត្រី: ការស្ទាបស្ទង់អំពីយេនឌ័រនៅកម្ពុជា យូនីហ្វាម ធនាគារពិភពលោក ធនាគារភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ឌីហ្វីត ភ្នំពេញ ។

# I. ទិសដៅ/គោលបំណង

គម្រោងនេះស្វែងបញ្ជ្រាបយេនឌ័រ ទៅក្នុងកិច្ចការរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(MDGs)ដែលមានស្រាប់ដោយសម្តៅដល់ការកសាងសមត្ថភាពថ្នាក់ជាតិ និងការងារតស៊ូមតិឬការងារស្វែងរកការគាំទ្រ (Advocacy) ។ គម្រោងនេះនឹងជួយធ្វើជាយាន្តសំរាប់ធានាថា ទំហំយេនឌ័រនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវបានគេលើកឡើង ធ្វើវិភាគ និងឆ្លុះបញ្ចាំងក្នុងក្រុម គោលដៅថ្នាក់ជាតិ ហើយទស្សនវិស័យយេនឌ័រ ត្រូវបានថែរក្សានៅរាល់ដំណើរការនៃការធ្វើរបាយការណ៍ត្រួតពិនិត្យ និង ការតស៊ូមតិ លើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅគ្រប់កំរិតថ្នាក់ជាតិ ។

គម្រោងនេះមានស្ថាប័នគាំទ្រសំខាន់បីនៅគ្រប់លំដាប់ថ្នាក់ក្នុងប្រទេសគឺៈ រដ្ឋាភិបាល សង្គមស៊ីវិល និង ក្រុមការងារសហប្រជាជាតិ (UN Country Team) ។ ស្ថាប័នគាំទ្រនីមួយៗនេះមានតួនាទីសំខាន់ណាស់ ដើម្បីឱ្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចាក់ឫសបាននៅក្នុងប្រទេសទាំងឡាយ ។

**គោលដៅតូចបន្ទាប់(Sub-goals) នៃគម្រោងទាក់ទិននឹងស្ថាប័នគាំទ្រទាំងបីខាងលើនេះគឺ :**

១ ដើម្បីធ្វើការតស៊ូមតិជាមួយអ្នកធ្វើនយោបាយ និង អ្នកធ្វើផែនការកម្មវិធីទាំងឡាយថា ការបញ្ជ្រាបសមភាពយេនឌ័រក្នុងរាល់គោលដៅអភិវឌ្ឍន៍សហប្រជាជាតិ ជាស្នូលសំខាន់សំរាប់ការអភិវឌ្ឍន៍ជាតិ ។

២ ដើម្បីពង្រឹងមធ្យោបាយសំរាប់ការត្រួតពិនិត្យមើល នូវការឆ្លើយតបយេនឌ័រ (Gender Sensitive) និងរបាយការណ៍អំពីការរីកចំរើនទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។

# II យុទ្ធសាស្ត្រ

ប្រទេសទាំងឡាយសំរាប់ការអនុវត្តសាកល្បងគម្រោងនេះគឺៈ កម្ពុជា (Cambodia) កេនយ៉ា (Kenya) គាហ្គីស្តង់ (Kyrgyzstan) ម៉ារ៉ុក (Maroc) និងប៉េរូ (Peru) ។

**យុទ្ធសាស្ត្រពីរជាគន្លឹះនៃគម្រោងនេះគឺ:**

**ក.ការតស៊ូមតិ**– ការប្តេជ្ញាចិត្តដើម្បីឱ្យមាន សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចស្ត្រីត្រូវបានគេអនុវត្តនៅក្នុងប្រទេសកម្ពុជា តាមរយៈកិច្ចព្រមព្រៀងតាមផែនការសកម្មភាព (PFA) នៃទីក្រុងប៉េកាំង អនុសាសន៍ស្តីពីការលុបបំបាត់រាល់ទំរង់រើសអើងប្រឆាំងនឹងនារីភេទ និងលំដាប់ថ្នាក់ធំៗនៃផែនការសកម្មភាពថ្នាក់តំបន់ ថ្នាក់ជាតិនិងកិច្ចព្រមព្រៀង។ ជាពិសេសដៃគូគម្រោង នឹងបង្កើតយុទ្ធសាស្ត្រតស៊ូមតិ សម្ភារៈនិងវិធីសាស្ត្រដែលទាក់ទិននឹងពតិមានក្នុងការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងយុទ្ធនាការតស៊ូមតិ លើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលមានស្រាប់ ។ ប្រទេសដែលធ្វើការសាកល្បងអនុវត្តនីមួយៗ នឹងរៀបចំបង្កើតយុទ្ធសាស្ត្រដ៏សមស្រប សម្ភារៈ និងយន្តការចែកចាយទាំងអស់នេះត្រូវបានគូសវាសឡើង ដើម្បីឱ្យ

សម្រេចបាននូវគោលដៅរួម ។

**៦.ការកសាងសមត្ថភាព**-ដំណើរការគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នឹងបន្តទៅអនុវត្តនៅគ្រប់កំរិតប្រទេសនៅឆ្នាំ២០១៥ ។ សារៈសំខាន់នៃការបង្កើនសមត្ថភាពកំរិតមូលដ្ឋាន តាមរយៈដំណើរការអនុវត្តគម្រោងនេះគឺ ត្រូវបានភ្ជាប់ជាមួយនឹងនិរន្តរភាពយូរអង្វែង ។ការកសាងសមត្ថភាព នឹងផ្តោតលើការតស៊ូមតិ ការសន្ទនានយោបាយ និងការអភិវឌ្ឍន៍ និងការសង្កេតមើលនូវសូចនាករ នៃការឆ្លើយតបយេនឌ័រ ការប្រើប្រាស់ និងបង្ហាញនូវទិន្នន័យខូចព្រហ្មចារី ប្រពន្ធ័ផ្សព្វផ្សាយ និងគមនាគមន៍ ហើយនិងវិធីផ្សេងៗ ដើម្បីបង្កើនលើកទឹកចិត្ត ឱ្យចូលជាប់ទាក់ទិនគ្នារវាងការអនុវត្តន៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។

## III យុទ្ធសាស្ត្រនៅកម្ពុជា

យេនឌ័រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជារបស់យូនីហ្វាមនិងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ស្វែងរកដៃគូជាមួយនឹងក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស) និងបណ្តាញ អង្គការសង្គម ស៊ីវិលដើម្បី :

- បង្កើនការយល់ដឹងតាមរយៈការកសាងសមត្ថភាពអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង សង្ខេបគោលនយោបាយយេនឌ័រដល់ក្រុមស្ត្រីក្នុងរាជរដ្ឋាភិបាលកម្ពុជា និង សង្គមស៊ីវិលពីកំរិតថ្នាក់ជាតិ ដល់កំរិតមូលដ្ឋាន ។
- ធ្វើការតស៊ូមតិជាមួយអ្នកធ្វើនយោបាយលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចំណុចទី១ និងទី៦ លើ ភាពក្រីក្រ របស់នារីកម្ពុជានិងភាពងាយរងគ្រោះឆ្លងរោគហ៊ីវ/ជម្ងឺអេដស៍ នៃស្ត្រីកម្ពុជា ។
- ធ្វើការជាមួយភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ ដើម្បីបញ្ចូលយេនឌ័រ ទៅក្នុងយុទ្ធនាការ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក្នុងឆ្នាំខាងមុខ ។
- រៀបចំឱ្យមានការសន្ទនារវាងអ្នកធ្វើគោលនយោបាយនិងអ្នកពាក់ព័ន្ធ ។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័តិមានអំពីគោលដៅទី១និងទី៦នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

UNDP    UNIFEM    JAPAN Official Development Assistance

# ការរួចផុតពីការរើកលូតលាស់
# ផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបនីយកម្ម
# មកលើស្ត្រីក្នុងវិស័យកាត់ដេរកម្ពុជា






## គម្រោងនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/
## មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី
## ត្រូវបានអនុវត្តក្នុងភាពជាដៃគូ
## ជាមួយអង្គការសីលការ SILAKA

# តើរួចផុតពីការរីកលូតលាស់ទេ?

## ផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបនីយកម្ម

## មកលើស្ត្រីក្នុងវិស័យកាត់ដេរកម្ពុជា

**បេសកកម្មស្តីអំពីស្ថានភាពស្ត្រី**

**វារៈប្រជុំលើកទី៤៩**

ពីថ្ងៃទី ២៨ ខែកុម្ភៈ ដល់ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៥

**ត្រូវបានរៀបចំឡើងដោយគម្រោងអភិវឌ្ឍន៍សហប្រជាជាតិ**

**មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី**

**គម្រោងយេនឌ័រ និង គម្រោងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍**

ខែកុម្ភៈ ឆ្នាំ២០០៥

**មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី**

---

*ឯកសារនេះត្រូវបានរៀបចំឡើងដោយ ឥង្គ្រិឌ ហ្វិត្សចេរ៉ាល់ឌ៍Ingrid FitzGerald ជាផ្នែកមួយនៃយេនឌ័រ របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឬយេនឌ័ររបស់មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់ស្ត្រី និងគម្រោង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលផ្តោតទៅលើទិសដៅមួយ (Goal One) ក្នុងប្រទេសកម្ពុជា ។ វាត្រូវការឱ្យមានរបាយការណ៍មួយ ដែលរៀបរាប់ពិស្តារជាងនេះ និងគោលនយោបាយសង្ខេប ដែលបង្កើតឡើង តាមគម្រោងនោះ និងការពិភាក្សាឆ្លងតាមការសន្ទនានយោបាយរបស់អ្នកពាក់ព័ន្ធចម្រុះ ស្តីអំពីផលប៉ះពាល់ នៃពាណិជ្ជសេរីភាវូបនីយកម្ម មកលើកម្មការិនីកាត់ដេរក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាពលោក ណូងលីន ហេហ្ស៊រ Noeleen Heyzer ជានាយកប្រតិបត្តិប្រចាំយូនីហ្វាម និងធ្វើជាម្ចាស់ផ្ទះរៀបចំដោយយូអិនឌីភីUNDPយូនីហ្វាមUNIFEM ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ។*

# ១ អារម្ភកថា

*យើងត្រូវការពារនិងគាំទ្រស្ត្រីទាំងឡាយដែលបាត់បង់ការងារដោយសារការបិទរោងចក្រ ធានាឱ្យមានទូវឱកាសការងារជម្រើស ការបណ្តុះបណ្តាល និង ការងារជំនាញនៅក្នុងវិស័យរបស់រដ្ឋាភិបាល ។ បើមិនដូច្នោះទេ កម្មករទាំងឡាយនេះនឹងធ្លាក់ចូលទៅក្នុងគ្រោះថ្នាក់ពេស្យាចារឬក៏ការជួញដូរ ។*

លោកបណ្ឌិត ណូងលីន ហេហ្សរ៍ នាយកប្រតិបត្តិអង្គការយូនីហ្វាម
ថ្ងៃទី១៤ ខែ មករា ឆ្នាំ២០០៥ ភ្នំពេញ

ពាណិជ្ជកម្មសេរីភាវូបនីយកម្ម ត្រូវបានស្វាគមន៍ដោយរដ្ឋាភិបាលនិងគ្រឹះស្ថានចំរុះដែលជាឧបករណ៍ ដើម្បីសម្រេចនូវការចំរើនលូតលាស់ និងកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ។ កម្ពុជាមិនមានជម្រើសណាផ្សេងក្រៅពីនេះទេ ដូច្នេះហើយទើបរាជរដ្ឋាភិបាល និងម្ចាស់ជំនួយច្រើនមើលឃើញនូវការចូលជា សមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងពាណិជ្ជកម្មសេរីភាវូបនីយកម្មថាជា ចំណុចស្នូលសំខាន់ដល់យុទ្ធសាស្ត្រ សំរាប់ការចំរើនលូតលាស់ និងការកាត់បន្ថយភាពក្រីក្រ ។

កំណែទម្រង់ពាណិជ្ជកម្ម ប៉ះពាល់ដល់ស្ត្រីនិងបុរសមិនដូចគ្នាទេ ករណីទាំងពីរនេះដោយសារនារីនិង បុរសមានឋានៈតួនាទីផ្សេងគ្នាក្នុងសង្គមនិងសេដ្ឋកិច្ច និងដោយសារការរាលដាលនយោបាយពាណិជ្ជកម្មដែល មានសក្តានុពលនាំឱ្យមានការថយចុះឬក៏សភាពកាន់តែដុនដាបនូវអសមភាពខាងភេទ(យេនឌ័រ) ។ ជាអកុសល នយោបាយពាណិជ្ជកម្មនិងអ្នកតាក់តែងនយោបាយទាំងឡាយ ជារឿយៗខកខានមិនបានយកបញ្ហាខាងយេនឌ័រ មកពិចារណា ដែលជាលទ្ធផលបណ្តាលឱ្យគេអនុវត្តកំណែទម្រង់នោះដោយមិនបានគិតគូរដល់ផលប្រយោជន៍របស់ ស្ត្រី ឬក៏របៀបដែលនឹងប៉ះពាល់ដល់ស្ត្រី ។ មិនមានយុទ្ធសាស្ត្រការពារត្រូវបានដាក់បញ្ចូលទៅក្នុងនយោបាយពាណិជ្ជកម្ម ដើម្បីធានាឱ្យមាននូវគុណប្រយោជន៍ដល់នារី និងមិនធ្វើឱ្យប្រសើរឡើងនូវផលប៉ះពាល់អវិជ្ជមានណាមួយឡើយ ។

សមធម៌យេនឌ័រជាចំណុចស្នូលកណ្តាលដ៏សំខាន់ ដើម្បីឱ្យទទួលបានជោគជ័យនូវគំនិតផ្តួច ផ្តើមអភិវឌ្ឍន៍និងកាត់បន្ថយភាពក្រីក្រ។ ប្រសិនបើចង់ឱ្យកំណែទម្រង់ពាណិជ្ជកម្មនាំមកនូវគុណប្រយោជន៍ដល់កម្ពុជា និងរួមចំណែកក្នុងការលើកស្ទួយបុរស និងនារីខ្មែរឱ្យផុតពីភាពក្រីក្រនោះ យេនឌ័រត្រូវតែ ស្ថិតនៅចំកណ្តាល មិនមែនស្ថិតនៅគៀនខាងក្រៅនៃនយោបាយពាណិជ្ជកម្ម និង ការអនុវត្តន៍ចាត់ ចែងពាណិជ្ជកម្មថ្មីៗនោះទេ ។

សារៈសំខាន់ជាស្នូលនៃសមធម៌យេនឌ័រខាងផ្លូវភេទក្នុងការអភិវឌ្ឍន៍ការកាត់បន្ថយភាពក្រីក្រ ត្រូវបានគេដាក់បញ្ចូលទៅក្នុងនយោបាយរដ្ឋាភិបាលកម្ពុជា ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបង្កើតនូវកម្មវិធីការងារក្នុង

អាណត្តិទីបីនៃរដ្ឋាភិបាលសំរាប់ការកែទម្រង់ និងអភិវឌ្ឍន៏ បានសង្កត់ធ្ងន់ថានារីគឺជាឆ្អឹងខ្នង(ខ្នងបង្អែក) សម្រាប់សង្គមសេដ្ឋកិច្ចកម្ពុជា ។ ផែនការយុទ្ធសាស្ត្រទីពីររយៈពេលប្រាំឆ្នាំដើម្បីស្ត្រី ពោលគឺ នារីរតនៈទីពីរនោះ បានកត់សំគាល់ឃើញនូវការផ្តល់សិទ្ធិអំណាចខាងសេដ្ឋកិច្ចថាជាគោលនយោបាយជាគន្លឹះក្នុងការសម្រេចបាននូវសមធមិខាងផ្លូវភេទយេនឌ័រនៅកម្ពុជា ។ លើសពីនេះ កម្ពុជាជាហត្ថលេខីមួយលើកិច្ចព្រមព្រៀងជាអន្តរជាតិ និងគម្រោងការណ៍ដែលគេគូសវាសឡើងដើម្បីលើកកម្ពស់សមធមិ យេនឌ័រនិងតួនាទីស្ត្រី ក្នុងការអភិវឌ្ឍន៏ ។

ការនេះរួមមានគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៍ អនុសញ្ញាស្តីការលុបបំបាត់ចោលរាល់ទំរង់រើសអើងប្រឆាំងនឹងនារីភេទCEDAW និងវេទិកាទីក្រុងប៉េកាំងត្រូវបានពិនិត្យមើលឡើងវិញនៅ ប៉េកាំងបូក១០ ដែលទាំងអស់នេះគេបាន ព្រមព្រៀងជាអន្តរជាតិ នូវសេចក្តីប្រាថ្នាទាំងឡាយដើម្បីស្ត្រី ។ ការប្រឆាំងជំទាស់នោះ ត្រូវតែធានាឱ្យមាន ការដឹងឮនូវគម្រោង ការណ៍ទាំងឡាយនេះ និងដឹកនាំតំរង់ផ្លូវនយោបាយពាណិជ្ជកម្ម និងត្រូវបានគេប្រើប្រាស់ ដើម្បីត្រួតពិនិត្យនូវផលប៉ះពាល់នៃពាណិជ្ជកម្មសេរីភាវូបនីយកម្មលើស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ស្ត្រី និង សមត្ថភាពដើម្បីចិញ្ចឹមជីវិត ។

អនាគតនៃវិស័យកាត់ដេរកម្ពុជា គឺជាបញ្ហាសំខាន់ស្លាប់រស់ដល់ស្ត្រី និងដល់ការផ្តួចផ្តើមគំនិតអភិវឌ្ឍន៏កាត់បន្ថយភាពក្រីក្រ ។ ទីផ្សារការងារកម្ពុជាតូចចង្អៀតនិងយេនឌ័រមានចំណាត់ថ្នាក់ខ្ពស់ ។ ឱកាស ការងារនៅមានកំរិត ជាពិសេសការងារក្នុងប្រព័ន្ធក្រៅពីវិស័យកសិកម្មដែលមានប្រជាពលរដ្ឋខ្មែរភាគច្រើនធ្វើ។ វិស័យកាត់ដេរ បានជួយស្ត្រីឱ្យមានការងារធ្វើជាច្រើនក្នុងប្រទេសកម្ពុជានិងបានដើរតួនាទីដ៏សំខាន់ក្នុងការលើកស្ទួយស្ត្រី និងក្រុមគ្រួសាររបស់ពួកគេឱ្យផុតពីភាពក្រីក្រ ។ ការលូតលាស់សេដ្ឋកិច្ច ដ៏សមស្របដែលកម្ពុជា ធ្លាប់បានជួបប្រទះ មួយផ្នែកធំនោះព្រោះតែការងារដ៏លំបាក និងការចូលរួមវិភាគទានពីយុវតីក្មេងៗ ទាំងនេះផងដែរ ហើយ កម្ពុជាមានកំណើនសេដ្ឋកិច្ចនោះ ដោយសារពួកគេដែលមានការជួយទ្រទ្រង់ឱ្យឆ្លងផុតរយៈកាលច្របូកច្របល់ ដែលកើតឡើងដាយសារតែ លទ្ធផលនៃពាណិជ្ជកម្មសេរីភាវូបនីយកម្ម ។

ជាការពិត ផលប៉ះពាល់នៃពាណិជ្ជកម្មសេរីភាវូបនីយកម្មលើផ្នែកកាត់ដេរ និងលើកម្មការិនីកាត់ដេរនឹងជាករណីពិសោធន៏សំរាប់កម្ពុជាក្នុងផ្នែកសំខាន់បី គឺ:

- ថាតើពាណិជ្ជកម្មសេរីភាវូបនីយកម្ម បានជួយចូលរួមជាវិភាគទាន ឬក៏ធ្វើឱ្យអន្តរាយដល់សមធមិយេឌ័រ ដែលរួមបញ្ចូលនូវអ្វីដែលជាវិសាលភាពនៃផលប៉ះពាល់អាក្រក់លើស្ត្រីហើយត្រូវបានគេរៀបចំផែនការជាស្រេច និងប្រឈមមុខដោះស្រាយដែរឬទេ ។
- វិសាលភាពដែលពាណិជ្ជកម្មសេរីភាវូបនីយកម្មក្នុងវិស័យកាត់ដេរ ជួយដល់ការកាត់បន្ថយភាពក្រីក្រ ឬក៏ធ្វើឱ្យខូចខាតដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ជាពិសេសសំរាប់ស្ត្រី ។
- ចុងក្រោយ ថាតើកំណែទម្រង់ពាណិជ្ជកម្មបានជួយ ឬក៏រារាំងកម្ពុជាពីការសម្រេចដល់គោលដៅដូចដែលបានបង្កើតឡើងនៅក្នុងគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៍ ។

ជាអកុសល រដ្ឋាភិបាលតែងតែមិនឈរក្នុងជំហរមួយដើម្បីកំណត់នូវលទ្ធផលនៃកំណែទម្រង់ពាណិជ្ជកម្មទេ ។ នៅកម្ពុជា ឥទ្ធិពលនៃការលើកស្ទួយពីបរិមាណកំណត់នៃកិច្ចព្រមព្រៀងពហុវាយនភណ្ឌ (MFA quotas)និងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTO ជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា ការងារ និង ការអភិវឌ្ឍន៍ មួយផ្នែកធំនឹងត្រូវកំណត់ទៅជាយ៉ាងណាបាន គឺដោយសារកម្លាំងថាមពលអន្តរជាតិ ដែលក្នុងនោះមានទាំងសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិន ។រដ្ឋាភិបាលអាចបន្ថយផលប៉ះពាល់អាក្រក់ពីពាណិជ្ជកម្មសេរីភាវូបនីយកម្មបាន ក៏ប៉ុន្តែមិនអាចច្រានចោលនូវឥទ្ធិពលនោះទាំងស្រុងបានទេ ។ អ្នកទិញដូរ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ រោងចក្រ និងអ្នកពាក់ព័ន្ធទាំងឡាយទាំងអស់គ្នានេះ រួមចំណែកទទួលខុសត្រូវធ្វើសកម្មភាពឱ្យប្រត្យក្សថា គុណប្រយោជន៍ពីកំណែទម្រង់ពាណិជ្ជកម្មនោះបានសម្រេច ផលជាក់ស្តែង និងជួយចូលរួមចំណែកឱ្យមានការអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រ ព្រមទាំងប្រឈមដោះស្រាយនឹងផលប៉ះពាល់អាក្រក់ណាមួយមកលើកម្មការិនីកាត់ដេរ និងសមធម៌ខាងផ្លូវភេទយេនឌ័រឱ្យបានកាន់តែធំទូលំ ទូលាយជាងមុនឡើង ។ ព្រោះហេតុនោះ តម្រូវឱ្យមានកិច្ចសហការពួតដៃគ្នាពីអ្នកពាក់ព័ន្ធទាំងឡាយ ឱ្យបានច្រើន ដើម្បីត្រៀមរៀបចំផែនការ និងអនុវត្តការប្រឈមមុខដោះស្រាយនូវការផ្លាស់ប្តូរប្រែប្រួលទាំងឡាយដែលនឹងមកដល់ ហើយនិងធានាឱ្យបានថាជីវភាពចិញ្ចឹមជីវិតរបស់ស្ត្រីត្រូវបានការពារ ។

អត្ថបទនេះត្រូវបានចងក្រងឡើង ដើម្បីផ្តល់ជូនការពិនិត្យមើលនូវស្ថានភាពស្ត្រីនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជានិងផលប៉ះពាល់ពីការផ្លាស់ប្តូរដ៏មានសក្តានុពលមកលើវិស័យនោះ ព្រមទាំងតម្រូវឱ្យមានវិធានការអនុវត្តដើម្បីប្រឈមដោះស្រាយនូវផលប៉ះពាល់ពីកំណែទម្រង់ពាណិជ្ជកម្ម ដើម្បីជម្រាបជូនជាព័ត៌មាន ដល់កិច្ចពិភាក្សានៅឯកិច្ចប្រជុំប៉េកាំង +១០ របស់អ្នករកស៊ីផ្លូវភេទ នៅក្នុងទីក្រុងញូយ៉ក ក្នុងខែ មករា-មីនា ឆ្នាំ ២០០៥ ។

## ២ ស្ថានភាពស្ត្រីនៅក្នុងវិស័យកាត់ដេរ

*យើងលែងអាចពឹងផ្អែកលើធនធានធម្មជាតិដូចពីមុនទៀតហើយ ។ ដីធ្លី សំបុកត្រីក្នុងទឹក ព្រៃប្រឹក្សា.....ដែលយើងធ្លាប់ពឹងពាក់ពំនាក់អាស្រ័យសំរាប់ការរស់រៀនចិញ្ចឹមជីវិត ឥឡូវនេះទីនោះលែងមានទៀតហើយ ។*

កម្មករកាត់ដេរកម្ពុជា

ភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៥

ឧស្សាហកម្មកាត់ដេរមានប្រវត្តិដ៏ខ្លីស្ថិតនៅក្នុងប្រទេសកម្ពុជាជាបណ្តោះអាសន្ន ។ រោងចក្រទាំងឡាយដែលគេបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ បានធានារ៉ាប់រងបង្កើតការងារថ្មីៗប្រហែល ២១០ ០០០ ក្នុងចន្លោះពីឆ្នាំ ១៩៩៧ និង ២០០៤ - ដោយផ្តល់ការងារ ១៤% នៃអ្នកចំណូលក្នុងទីផ្សារការងារថ្មី ក្នុងអំឡុង ពេលនេះ (EIC ២០០៥) ។ ទោះបីជាយ៉ាងណាក៏ដោយ ការងារកើនឡើងដល់កំពូលក្នុងឆ្នាំ ២០០០ ហើយចាប់ធ្លាក់ចុះមកវិញ ចាប់ពីពេលក្រោយនោះមក ។ លើសពីនេះ ភាគរយនៃការនាំចេញក្រោមប្រព័ន្ធបរិមាណកំណត់ (quota system) បានធ្លាក់ចុះជាបន្តបន្ទាប់ផងដែរពីប្រមាណ ៦០% ក្នុងឆ្នាំ១៩៩៩ មកនៅត្រឹម ៣០% ក្នុងឆ្នាំ ២០០៤ ។

ទោះបីជាឧស្សាហកម្មកាត់ដេរមានប្រវត្តិពិសោធន៍របស់ខ្លួនទើបតែថ្មីៗនេះក្តី ក៏មានសារៈសំខាន់យ៉ាងសម្បើមដល់សេដ្ឋកិច្ចកម្ពុជា និងដល់ការបង្កើតការងារ ជាពិសេសសំរាប់នារីៗ ។ ឧស្សាហកមកាត់ដេរជួយឱ្យបានការនាំចេញ ៨០% តាមគេប៉ាន់ប្រមាណ និង ១២% នៃផលិតផលក្នុងស្រុកសរុប ។ វិស័យនេះ បានផ្តល់ការងារដល់នារីចំនួន ២០០ ០០០នាក់ ដែលបំពេញបង្គ្រប់ឱ្យបាន ៨៥% នៃកម្មករកាត់ដេរ និង ៦% នៃកម្លាំង ពលកម្មជានារីភេទសរុប (EIC ២០០៥) ។ លើសពីនេះវិស័យកាត់ដេរជួយទ្រទ្រង់ការងារក្នុងវិស័យក្រៅប្រព័ន្ធប្រមាណ ១៥០ ០០០ ដែលក្នុងនោះមានអ្នកធ្វើការតាមផ្ទះ និងកម្មករគិតប្រាក់ឈ្នួលតាមសមិទ្ធផលការងារ (pieceworker) ដែលភាគច្រើនក្នុងចំណោមពួកគេគឺជានារី ។

យុវតីវ័យក្មេងទាំងឡាយ ដែលធ្វើការក្នុងវិស័យកាត់ដេរបានរួមវិភាគទានដ៏សំខាន់ដល់សេដ្ឋកិច្ចកម្ពុជា ។ ពួកគេៗមកពីតំបន់ជនបទដាច់ស្រយាលផ្សេងៗមកធ្វើការងារក្នុងទីក្រុងដើម្បីរកប្រាក់ចំណូល ប្រមាណ ៥០-៦០ ដុល្លា ក្នុងមួយខែ ។ ពួកគេបញ្ជូន ៥០% (ពាក់កណ្តាល) នៃប្រាក់កម្រៃទៅផ្ទះ សំរាប់ទ្រទ្រង់ក្រុមគ្រួសារ ដែលមានសមាជិកពី ៤-៩ នាក់ក្នុងគ្រួសារនីមួយៗ ។ ជារឿយៗ ពួកគេបានបោះបង់ការសិក្សាក្នុងសាលារៀនចោលមកធ្វើការងារដើម្បីឧបត្ថម្ភការសិក្សាដល់បងប្អូនប្រុសៗរបស់គេ ហើយមិនរវីរវល់ដល់ខ្លួនឯង ។ ពេលខ្លះគ្រួសារទាំងឡាយបានបោះបង់ការធ្វើកសិកម្មស្រែចំការ ដោយសារការចំណាយថ្លៃដើមខ្ពស់ពេក និងពឹងអាស្រ័យលើប្រាក់កម្រៃរបស់ស្ត្រីៗដើម្បីទ្រទ្រង់ ។ ការងារតាមរោងចក្រកាត់ដេរ បន្តឱ្យមានជាស្លាកស្នាមមិនល្អ គឺថា ក្នុងទម្លាប់ប្រកាន់អភិរក្ស តឹងតែងខាងផ្លូវភេទ (យេនឌ័រ) យុវតី វ័យក្មេងប្រថុយនឹងការខូចបង់កេរ្តិ៍ឈ្មោះ និងឱកាសរៀបអាពាហ៍ពិពាហ៍ជាគូគ្រង នៅពេលដែលពួកនាងបានចាកចេញពីផ្ទះ ទៅធ្វើការ

ក្នុងវិស័យកាត់ដេរ ។ ពួកនាង ប្រថុយគ្រោះកាចខូចសុខភាពរាងកាយ និងជីវភាពចិញ្ចឹមជីវិតរបស់ពួកគេនៅក្នុងនិងក្រៅរោងចក្រកាត់ដេរ ។

លក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរកម្ពុជា ត្រូវបានត្រួតពិនិត្យដោយអង្គការពលកម្មអន្តរជាតិ ILO ដែលធ្វើទស្សនកិច្ចដល់ទីកន្លែង និងធ្វើការបណ្តុះបណ្តាលក្នុងភាពជាដៃគូជាមួយនឹងឧស្សាហកម្មនោះ ដើម្បីធានាឱ្យបានថារោងចក្រនានាប្រតិបត្តិអនុលោមតាមច្បាប់ការងារកម្ពុជា ។ កម្ពុជាមានមោទនភាពថា ការចុះបញ្ជីសារមានលក្ខខណ្ឌការងារល្អ ក្នុងឧស្សាហកម្មកាត់ដេរ និងមានបំណងចង់បន្តប្រើប្រាស់បញ្ជីសារល្អនេះ ដើម្បីបង្ហាញថាកម្ពុជាល្អប្រសើរមិនដូចជាអ្នកប្រកួតប្រជែងទាំងឡាយនោះទេ និងពាក់ផ្លាក លើឧស្សាហកម្មនោះថាជាទីចាប់ចិត្តជិតអារម្មណ៍ពីអតិថិជនអ្នកទិញទាំងឡាយដែលរួសរាយជួយរ៉ាប់រងបាន ។

យោងតាមអង្គការពលកម្មអន្តរជាតិ ILO បានឱ្យ ដឹងថាអតិថិជនអ្នកទិញសំខាន់ៗមួយចំនួនបានបង្ហាញរួចមក ហើយថាពួកគេនឹងនៅតែបន្តទទួលទិញយកសំលៀកបំពាក់ដើមពីកម្ពុជានេះច្បាស់ណាស់ដោយសារថារោងចក្រ ទាំងឡាយអនុលោមតាមក្រមការងារនោះឯង ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គការពលកម្មអន្តរជាតិបានកត់សម្គាល់ផងដែរថាការរំលោភបំពានច្បាប់ នៅតែបន្តកើតមាននៅឡើយ ។ កម្មកររោងចក្រកាត់ដេរបានរាយការណ៍រៀបរាប់ដោយខ្លួនពួកគេថា ច្បាប់ការងារតែងតែមិនត្រូវបានគេដាក់កំហិតឱ្យគោរពអនុវត្តតាមទេ ។ ការរំលោភបំពានដែលពួកគេ លើកឡើងជាចម្បងនោះគឺការធ្វើការច្រើនម៉ោង បង្ខំឱ្យធ្វើការលើសម៉ោង និង ខ្វះប្រាក់កម្រៃក្នុងករណីកាត់ចេញពី ការងារ ។ កម្មកររោងចក្រដោយច្រើនមិនបានរួបរួមគ្នាជាសហជីពទេ - និងក្នុងភាពជាអ្នកដឹកនាំស្ត្រីមិនមាន ដំណាងសហជីពដ៏ល្អទេ ។ សម័យមួយនៅខាងក្រៅរបងរោងចក្រ កម្មការិនីស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ពីការ ចោរកម្មឆក់ផ្លូន់ ការចាំយាយីរំខានរុករាន និងការចាប់រំលោភសេពសន្ថវៈ ។ បរិយាកាសរស់នៅកកកុញកុះករ គ្មាន អនាម័យ និងពួកនាងប្រឹងបរិភោគនិងថែរក្សាសុខភាពឱ្យបានល្អដោយចំណាយប្រាក់កាសបន្តិចបន្តួចស្តួចស្តើង ។

ទោះបីជានារីនិងក្រុមគ្រួសាររបស់ពួកគេដឹងថា មានឱកាសធ្វើការក្នុងវិស័យកាត់ដេរ រកបានប្រាក់កម្រៃក៏ដោយតែថ្លៃចំណាយវិញក៏ធំផងដែរ ។ នេះហើយដែលបានពិពណ៌នាអំពីសេចក្តីប្រាថ្នារបស់កម្មករថានឹងចាកចេញពីវិស័យកាត់ដេរនេះ ត្រឡប់ទៅស្រុកភូមិរបស់ពួក គេវិញ ហើយស្វែងរកមុខរបរការងារផ្សេងមកជំនួសវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងកន្លែងតូចចង្អៀតនិងទីផ្សារការងារដែលត្រូវបានគេប្រកាន់បែងចែកខាងយេនឌ័រ ជម្រើសរបស់ស្ត្រី នៅមានកំរិត ហើយនិងឋានៈកំរិតជំនាញរបស់ពួកគេនៅទាបនៅឡើយបើធ្វើការប្រៀបធៀប ។ ជាពិសេស ពួកនាងខ្វះជំនាញជាផ្លូវការសំរាប់ប្តូរផ្លាស់ ដែលនឹងឱ្យពួកនាងអាចរក ការងារផ្សេងជាជំនួសវិញពុំបានឡើយ ។

## ៣ អនាគតវិស័យកាត់ដេរ

*ដូចដែលបានកត់សម្គាល់ខាងលើស្រាប់ហើយថា ការងារក្នុងវិស័យកាត់ដេរនិងភាគរយនៃសំលៀកបំពាក់ ដែលផលិតឡើងក្រោមប្រព័ន្ធបរិមាណកំណត់ (quota) បានធ្លាក់ចុះជាស្រេចទៅហើយមុននឹងការដកចេញ នូវកិច្ចព្រមព្រៀងពហុវាយនភណ្ឌ MFA និង ការចូលរបស់កម្ពុជាទៅក្នុងសមាជិកអង្គការពាណិជ្ជកម្មពិភពលោក WTOនោះទៅទៀត ។ បើឧស្សាហកម្មនោះ ស្ថិតនៅក្នុងអន្តរកាលរួចជាស្រេចទៅហើយនោះ តើមានអ្វី ដែលត្រូវរំពឹងទុកថានឹងកើតឡើងក្នុងឆ្នាំ ២០០៥ និងពេលក្រោយៗទៀតនោះ ?*

ដោយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាតម្រូវឱ្យស្ថាបនាបង្កើតការកែទម្រង់ជា ក្បួនចម្លងដើម្បី បើករបាំងដល់ការប្រកួតប្រជែង និងសម្រួលនូវរបបពាណិជ្ជកម្មថ្មី ។ នៅពេលជាមួយគ្នានេះ ការដកចេញនូវកិច្ចព្រមព្រៀងប្រព័ន្ធ បរិមាណកំណត់ពហុវាយនភណ្ឌ (MFA quota) និង ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នឹងបើកចំហវិស័យកាត់ដេរកម្ពុជាដល់ការប្រកួតប្រជែងកាន់តែកើនច្រើនឡើង ជាពិសេសពីប្រទេសទាំងឡាយដូចជា ចិននិងប៉ាគីស្ថានដែលមានការ ប្រណាំងប្រជែងខ្ពស់និងមានទំនាក់ទំនងថយក្រោយខ្លាំងជាងមុន ជាឧទាហរណ៍ដូចជាផលិតផលវាយនភណ្ឌ ។ វាទំនងដូចជាថានឹងមានគំនាបសង្កត់ ច្រើនមកលើវិស័យកាត់ដេរដើម្បីកាត់បន្ថយតម្លៃនិងកែលម្អការអនុវត្តន៍កិច្ចព្រមព្រៀងនិងផលិតភាព ។ អតិថិជនអ្នកទិញ នឹងមានតម្រូវការច្រើនជាងមុនដោយមានការរួមបញ្ចូលគ្នា និងពង្រីករោងចក្រទាំងឡាយ ដើម្បីឆ្លើយតបនឹងតម្រូវការដោយប្រើពេលវេលាឱ្យកាន់តែខ្លីរហ័សជាងមុន តម្លៃប្រកួតប្រជែងនិងប្រតិបត្តិការ ប្រកបដោយបច្ចេកទេសជំនាញជាងមុន ។ អ្នកទិញនឹងបន្តដាក់ថ្លៃទៅដល់ភាគីរោងចក្រ ឧទាហរណ៍ដូចជា ការទទ្ទឹងចង់ឱ្យភាគីរោងចក្រផ្តល់ប្រាក់កម្ចីឥណទាន ដោយមិនបាច់បង់ប្រាក់ជាមុនរហូតដល់អ្នកទទួលលក់រាយ លក់សំលៀកបំពាក់អស់ជាមុនសិនជាដើម ។

ទោះបីជាអ្នកទិញអាចដាក់សម្ពាធលើ( ភាគីរោងចក្រ) អ្នកផ្គត់ផ្គង់ឱ្យអនុវត្តតាមបទដ្ឋានការងារក្តី ក៏ភាគីរោងចក្រនឹងនៅតែតម្លើងថ្លៃ ហើយអាចនឹងកិរិតថ្លៃចំណាយលើកម្មករតាមការកាត់ប្រាក់ខែ និងការរៀបចំ កិច្ចសន្យាសារជាថ្មី ។ គេបាននិយាយថា រោងចក្រភាគច្រើនណាស់ដែលកំពុងរង់ចាំមើល គឺថាកំណត់ មើលពេលនៃកំណែទម្រង់រដ្ឋាភិបាលជម្រើសរបស់អ្នកទិញ ថាតើប្រទេសចិនទទួលជោគជ័យក្នុងការគ្របដណ្តប់ទីផ្សារឬ ថាតើការឆ្លើយតបរបស់សហរដ្ឋ អាមេរិកយ៉ាងដូចម្តេចវិញ ថាតើកម្ពុជាអាចបញ្ចុះបញ្ចូល សហរដ្ឋអាមេរិកឱ្យផ្តល់ការលើកលែងរួចពន្ធ ដែលអាចជួយលើកកម្ពស់ឱ្យមានច្រកចូលទៅក្នុងទីផ្សារដែរឬទេ ការព្យាយាមដែលកម្ពុជា ដាក់ផ្លាកឱ្យវិស័យកាត់ដេរ ដើម្បីទាក់ទាញអតិថិជនអ្នករ៉ាប់រងទិញថាតើអាច ជោគជ័យ ឬបរាជ័យ ហើយនេះពិតជាពិបាកធ្វើការព្យាករណ៍ទស្សន៍ទាយ ឱ្យបានច្បាស់លាស់ដាច់ខាតអំពីអនាគតនៃឧស្សាហកម្មនេះណាស់ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការយល់ស្របគ្នាជាទូទៅថា មានគ្រោះថ្នាក់ដោយពិតពីការធ្លាក់ចុះក្នុងឧស្សាហកម្មនេះ និងបរិមាណផ្គត់ផ្គង់មានចំនួនច្រើនលើសសេចក្តីត្រូវការ ទោះក្នុងអាណត្តិរយៈពេលខ្លីឬវែង ជាពិសេសបើកំណែទម្រង់ដែលម្ចាស់ជំនួយ និង រាជរដ្ឋាភិបាលទទួលស្គាល់ មិនត្រូវបានយកមកអនុត្ត ឱ្យបានឆាប់ក្នុងអនាគតដ៏ខ្លីក៏ដោយ ។

រាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ឥឡូវនេះបានផ្តល់ឱ្យមានការវិភាគជាយុទ្ធសាស្ត្រ គួរឱ្យកត់សម្គាល់ក្នុងការធ្វើផែន ការថែរក្សាអនាគតនៃវិស័យនោះឱ្យបានចាកពីក្តីបារម្ភ និងដើម្បីការពារសេដ្ឋកិច្ចកម្ពុជា ។ នេះរួមមានយុទ្ធសាស្ត្រកាត់បន្ថយថ្លៃចំណាយធ្វើពាណិជ្ជកម្មរកទទួលទាននៅកម្ពុជា ដែលក្នុងនោះមានថ្លៃចំណាយ លើហេដ្ឋារចនាសម្ព័ន្ធនិងថ្លៃទូរគមនាគមន៍ កែលម្អធ្វើឱ្យប្រសើរឡើងនូវផលិតភាពនិងប្រតិបត្តិការគ្រប់គ្រង លើរោងចក្រកាត់ដេរ ដាក់ពង្រាយទីតាំងមូលដ្ឋានឧស្សាហកម្មកម្ពុជាឱ្យបានច្រើនមុខដើម្បីបង្កើនការលូត លាស់និងការងារសំរាប់ជម្រើសផ្លាស់ប្តូរ និងការចូលរួមចរចាចម្រុះតាមរយៈសមាគមន៍ក្នុងតំបន់ដូចជាសមាគមន៍ ប្រជាជាតិអាស៊ីភាគអាគ្នេយ៍ ASEAN ដើម្បីជួយបន្តថែរក្សាការពារឧស្សាហកម្មកាត់ដេរឱ្យបានចាក ផុតក្តីបារម្ភ ។ យុទ្ធសាស្ត្រទាំងនេះ មានសារៈសំខាន់ជាអាយុជីវិតក្នុងការបង្កើតការងារថ្មីៗ ជាពិសេសសំរាប់ អ្នកចូលមករកទីផ្សារការងារថ្មីប្រមាណ ២០០ ០០០ក្នុងមួយឆ្នាំៗ ។ ទោះបីជាយ៉ាងណាក៏ដោយ ជាការសមគួរ នឹងនិយាយបានថា ល្បឿននិងវិសាលភាពនៃកំណែទម្រង់នៅតែមិនទាន់ច្បាស់លាស់នៅឡើយ ហើយអាណត្តិក្នុងរយៈពេលខ្លីទំនងដូចជាមិនបានផ្តល់គុណប្រយោជន៍អ្វីដល់កម្មការិនីកាត់ដេរសោះ ។

គ្រោងការណ៍សង្ខេបមួយចំនួនសំរាប់អនាគតវិស័យកាត់ដេរឥឡូវនេះត្រូវបានទទួលស្គាល់ហើយ[១] ។ សេចក្តីព្រាងសង្ខេបមួយដែលត្រូវបង្ហាញនៅទីនេះ គឺពឹងផ្អែកលើមតិយោបល់ និងការយល់ដឹងស៊ីជម្រៅដែលបានផ្តល់ឱ្យដោយអ្នកវិភាគ និងអ្នកពាក់ព័ន្ធទទួលផលទាំងឡាយជាបន្តបន្ទាប់ ។ ទាំងនេះមិនមែនជាការព្យាករណ៍គួរឱ្យទុកចិត្តទាំងស្រុងបានទេព្រោះថាការព្យាករណ៍ខ្លះមានទំនងច្រើនជាងពីការទស្សន៍ទាយផ្សេងដទៃទៀត ។ ទោះ បីជាយ៉ាងណាក៏ដោយ ពួកគេពិតជាបានបង្ហាញឱ្យឃើញនូវផលប៉ះពាល់ដែលអាចកើតមានឡើងមួយចំនួនមកលើ កម្មការិនីកាត់ដេរ និងមានឧបការៈប្រយោជន៍នៅពេលណាដែលគេត្រូវការពិចារណាអន្តរាគមន៍ដែលអាចធ្វើបាន នោះគឺ :

- គ្រោងការណ៍សង្ខេបក្នុងករណីអាក្រក់ធ្ងន់ធ្ងរបំផុត ល្បឿនកំណែទម្រង់ដ៏យឺតយ៉ាវ ឬអវិជ្ជមាន( មិនអាចកើតចេញជារូបរាងបាន) ។ ម្ចាស់រោងចក្របាត់បង់ទំនុកចិត្តជឿជាក់ និងក្រុមហ៊ុនតូចតាចបិទទ្វារ ចំណែកឯក្រុមហ៊ុន ធំៗជាងរើប្តូរទីតាំងទៅឯនាយក្រៅប្រទេស ជាកន្លែងដែលមានការចំណាយថ្លៃដើមធ្វើពាណិជ្ជកម្មរកស៊ី អាចល្មមចាត់ចែងប្រព្រឹត្តទៅបានស្រួលប្រសើរជាង ។ ការបាត់បង់ការងារទ្រង់ទ្រាយធំកើតឡើងដែលបណ្តាលឱ្យ ប៉ះពាល់កម្មកររហូតដល់ ៥០០០០នាក់ និង២០០០០០នាក់ក្នុងក្រុមគ្រួសារ ។ កម្ពុជាធ្លាប់ទទួលរងភាពរឹករវរខាងសង្គមនិង ឧស្សាហកម្ម ក្នុងអាណត្តិរយៈពេលខ្លី ។
- ក្នុងគ្រោងការណ៍សង្ខេបអាណត្តិខ្លីទីពីរ កំណែទម្រង់ខ្លះត្រូវបានអនុវត្ត និងសេចក្តីព្យាយាមដាក់ផ្លាកឱ្យវិស័យ(សំលៀកបំពាក់)នោះ ដើម្បីទាក់ទាញវិនិយោគទុនធំៗចាប់ផ្តើមចូលមករកស៊ី ។ ក្រុមហ៊ុនតូចតាចបិទទ្វារប៉ុន្តែរោង ចក្រធំៗ

ជាច្រើនបានច្របាច់បញ្ចូលគ្នាហើយពង្រីកប្រតិបត្តិការដោយស្រូបយកកម្មករដែលកាត់ចេញពីការងារ ។

ក្នុងគ្រោងការណ៍សង្ខេបទីបី គ្មានកំណែទម្រង់អ្វីកើតឡើងទេ ប៉ុន្តែថយចុះទៅវិញយ៉ាងយឺត១ជាងមុន ប្រើរយៈពេលច្រើនឆ្នាំឡើងទៅជាជាងរាប់គិតជាខែ ។ ភាពខ្សោយចុះ គួរគិតជាសម័យកាលឡើងទៅជាជាង គិតត្រឹមតែមួយរាត្រីកាល ។ ទិដ្ឋភាពមិនបានផ្លាស់ប្តូរច្រើនទេ រហូតដល់ក្រោយឆ្នាំ២០០៥ ទើបបានប្រសើរឡើង ប៉ុន្តែឧស្សាហកម្មនោះទទួលរងនូវការធ្លាក់ចុះក្នុងអាណត្តិមួយដ៏វែងឡើងដោយមានការបាត់បង់ការងារសំខាន់១ លើសពីពេលជាប្រក្រតី ។

ចុងក្រោយនេះ គ្រោងការណ៍សង្ខេបអាណត្តិទីបួនដែលមានរយៈពេលវែង គង់ឃើញថាកំណែទម្រង់ រដ្ឋាភិបាលត្រូវបានអនុវត្តដោយជោគជ័យ ឧស្សាហកម្មកាត់ដេរនឹងផលិតបានច្រើនជាងមុន ទំនាក់ទំនងយូរអង្វែង (ដូចជាផលិតផលវាយនភណ្ឌ) ត្រូវបានព្រមព្រៀងគ្នាចូលរួម និង ការវិនិយោគពីអ្នកទិញដូរមានកម្លាំងខ្លាំងក្លា ។ វិស័យនោះធ្លាប់ទទួលបានការលូតលាស់ ដោយមានការបង្កើតការងារថ្មី១រហូតដល់ចំនួន ១០០០០០ ក្រោយឆ្នាំ ២០០៥ ។

---

(១) នេះរួមមានទាំងការព្យាករណ៍ដោយធនាគារអភិវឌ្ឍន៍អាស៊ីADB និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា EICនិងការព្យាករណ៍របស់ មូលនិធិរូបិយវត្ថុអន្តរជាតិ IMF ធនាគារពិភពលោក សមាគមផលិតករសំលៀកបំពាក់កម្ពុជា GMAC និងអ្នកអត្ថាធិប្បាយដទៃទៀត ។

# ៤ គ្រោះថ្នាក់សំរាប់កម្មការិនី

ទោះបីមានការផ្តោតយកចិត្តទុកដាក់ខ្លាំងលើអនាគតនៃឧស្សាហកម្មកាត់ដេរនោះក្តី ក៏មានការពិភាក្សាតិចតួចណាស់អំពីផលប៉ះពាល់លើកម្មការិនី ។ សូម្បីយ៉ាងនោះ ផលប៉ះពាល់នៃការផ្លាស់ប្តូរក្នុងវិស័យកាត់ដេរដែលក្នុងនោះរួមមានចំណាត់ថ្នាក់ទាប និងសភាពច្រើនលើសពីតម្រូវការ ឬសូម្បីក្នុងករណីប្រសើរ បំផុតនៃគ្រោងការសង្ខេប ការលូតលាស់និងការពង្រីកក្តី ក៏នឹងមានការខុសប្លែកគ្នាឆ្ងាយរវាងនារីនិងកម្មការី បុរសជាសហការីជាមួយពួកនាង ដោយសារតែឋានៈសង្គមសេដ្ឋកិច្ចមិនដូចគ្នា កង្វះខាតការអប់រំ សមត្ថភាព រកការងារនៅមានកំរិតក្នុងទីផ្សារការងារដ៏តូចចង្អៀត ។

ក្នុងករណីបាត់បង់ការងារមានទំហំធំ គ្រោះថ្នាក់សំរាប់ស្ត្រីជារួមមាន :

- ការធ្លាក់ចូលទៅក្នុងពេស្យាកម្មជាក្រៅប្រព័ន្ធនិងមានការគ្រប់គ្រង និងគ្រោះថ្នាក់ពីមេរោគហ៊ីវនិងជម្ងឺអេដស៍ HIV/AIDS ។ នារីភាគច្រើនដែលចាកចោលវិស័យកាត់ដេរចូលទៅធ្វើឧស្សាហកម្មផ្លូវភេទ ជារឿយៗព្រោះធ្វើឱ្យពួកគេរកប្រាក់ចំណូល និងបន្តជួយទ្រទ្រង់គ្រួសាររបស់នាងបាន ។ ខណៈដែលអត្រានៃការឆ្លងមេរោគហ៊ីវនិងជម្ងឺអេដស៍ក្នុងឧស្សាហកម្មផ្លូវភេទ បានធ្លាក់ចុះ ព្រោះតែអន្តរាគមន៍ខាងសុខាភិបាលមានប្រសិទ្ធិភាពនិងអន្តរាគមន៍ផ្សព្វផ្សាយដល់សង្គមកម្ពុជា នៅតែជាប្រទេសមួយដែលមានអត្រាឆ្លងមេរោគហ៊ីវនិងជម្ងឺអេដស៍ខ្ពស់ក្នុងតំបន់នៅឡើយ ។ ឧស្សាហកម្មផ្លូវភេទក្រៅប្រព័ន្ធកំពុងតែ រីកដុះដាលឡើង ដែលជាផ្នែកមួយដោយសារលទ្ធផលនៃ ការបង្រ្កាបរបស់រដ្ឋាភិបាលលើពេស្យាកម្មដែលមានការគ្រប់គ្រង និងអត្រាឆ្លងរោគហ៊ីវ/ជម្ងឺអេដស៍យ៉ាងខ្ពស់ក្នុងចំណោម ពេស្យាចារក្រៅប្រព័ន្ធ ។
- ចំណាកស្រុក ទាំងនៅក្នុងស្រុក ឬក្រៅប្រទេស ដើម្បីរកការងារធ្វើ ។ អត្រាចំណាកស្រុកនៅកម្ពុជា ទាំងក្នុងស្រុកនិងក្រៅប្រទេសនោះ មានកំរិតខ្ពស់រួចជាស្រេចទៅហើយ ដោយមានប្រជាពលរដ្ឋកម្ពុជាប្រមាណ ៨០០០០០ដែលកំពុងធ្វើការងារនៅស្រុកក្រៅ ។វិស័យកាត់ដេរ ព្រមទាំងវិស័យក្រៅប្រព័ន្ធ ជាអ្នកជួយ ជម្រុញឱ្យមានចំណាកស្រុកក្នុង ប្រទេស ។ នៅពេលដែលចំណាកស្រុកផ្តល់ឱ្យស្ត្រីនូវឱកាសល្អចូលទៅធ្វើការងារដែលមានប្រាក់ឈ្នួលនិងបន្តជួយទ្រទ្រង់ក្រុម គ្រួសារនោះ ពួកនាងក៏ទទួលរងគ្រោះថ្នាក់ផងដែរ ដូចជាត្រូវបានគេជួញដូរ ឆបោកយកធ្វើអាជីវកម្ម ឬក៏ត្រូវគេរំលោភសេពសន្ថវៈ ។ ពួកនាងព្រាត់ប្រាសឆ្ងាយ ពីក្រុមគ្រួសារ មួយអន្លើដោយមាន ស្លាកស្នាមទុរយស (មិនល្អ) អាស្រ័យដោយការងារឆ្ងាយពីផ្ទះសម្បែងនេះ ។
- ការចូលធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ។ វិស័យក្រៅប្រព័ន្ធនោះ ជួយបូកបន្ថែមសមាមាត្រសំខាន់មួយនៃសេដ្ឋកិច្ច កម្ពុជាប្រមាណ២០%នៃកម្លាំងពលកម្មស្ថិតនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមប្រជុំជនទីក្រុង ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធនោះជួយផ្ទុំឱ្យបានប្រហែល ៦០% នៃផលិតផលសរុបក្នុងស្រុក និងជួយទ្រទ្រង់នូវការចាកផុតចំណាកស្រុក ក្នុងប្រទេសយ៉ាងច្រើន ។ ស្ត្រីមានឱកាសបើកចំហតិចតួចក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចទីផ្សារការងារ ក្នុងប្រព័ន្ធដែរ ។ នារីទាំងឡាយមានទំនោរចូលចិត្តដើរលក់ដូរតាមផ្លូវ បើកលក់រាយ ជារឿយៗ មានបំណង ធ្វើជាកម្មការិនី ឬពាណិជ្ជកម្មជាលក្ខណៈគ្រួសារ ។

វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនមានបទបញ្ញត្តិការពារឱ្យមានរបៀបរៀបរយត្រឹមត្រូវទេ កម្មករតែងរងគ្រោះព្រោះលក្ខខណ្ឌការងារមិនល្អ ប្រឈមមុខនឹងការគម្រាមកំហែង និងការយាយីរុកគួនរំខាន (EIC 2005b) ។

ការវិលត្រឡប់ទៅផ្ទះសម្បែងដោយគ្មានប្រាក់កម្រៃទ្រទ្រង់ ៖ ដូចដែលបានរៀបរាប់ខាងលើហើយថាកម្មការិនីកាត់ដេរជាច្រើន សម្តែងចំណង់ចំណូលចិត្តគិតចង់ត្រឡប់ទៅផ្ទះសម្បែងស្រុកភូមិដើម្បីចាប់ផ្តើមបើក មុខរបរផ្ទាល់ខ្លួន ឧទាហរណ៍ដូចជាមុខរបរខាងកាត់ដេរ ឬកែសម្ផស្ស ។ ទោះបីជាយ៉ាងណាក៏ដោយ តម្រូវការ សំរាប់មុខរបរទាំងនេះនៅមានកម្រិតនៅឡើយហើយនារីខ្វះខាតជំនាញនិងសមត្ថភាពពីដំណើរការកាន់កាប់ពាណិជ្ជកម្មផ្ទាល់ខ្លួនឯង ។ ពួកនាងទំនងជាប្រឈមនឹងការគាបសង្កត់ខ្លាំងពីគ្រួសារ ឱ្យត្រឡប់ទៅទីក្រុងបន្តរកប្រាក់ចំណូលក្នុងស្ថានភាពមិនទៀងទាត់ ឬក៏ធ្វើចំណាកស្រុកទៅបរទេស ។

សូម្បីក្នុងករណីលំបាកយ៉ាប់យ៉ឺនក្តី ក៏ស្ត្រីនៅតែប្រឈមនឹងការប្រថុយប្រថាននឹងការខកខាន ខូចខាតទាំង នេះដដែល ប្រសិនបើពួកនាងមិនអាចបំពេញទម្រង់បែបបទចុះបញ្ជីឈ្មោះ (form of registration) មួយចំនួន និងលិខិតបញ្ជាក់អះអាង (referal) សំរាប់ការងារថ្មី ខណៈដែលគេប្រើប្រាស់ប្រាក់ចំណូលទ្រទ្រង់ ក្នុងសម័យកាលឥតការងារធ្វើ ។

នៅកម្ពុជា មុខរបរ និង ការងារមានការរើសអើងខ្ពស់ខាងយេនឌ័រចំពោះស្ត្រី ដែលចាប់អារម្មណ៍លើ មុខរបរការងារមានជំនាញការទន់ទាបដែលតម្រូវឱ្យមានការអប់រំតិចតួច ។ តាមបទពិសោធន៍បានបង្ហាញថា នៅពេលដែលឧស្សាហកម្មប្រើប្រាស់ជំនាញបច្ចេកទេសខ្ពស់ជាងមុននិងការងារជំនាញឯកទេសខ្ពស់ជាងមុនត្រូវបង្កើតឡើងនោះបុរសទេដែលមានឱកាសចូលទៅធ្វើការងារទាំងនេះ មិនមែននារីទេ ។ ព្រោះហេតុនោះ ទោះបីជា វិស័យកាត់ដេរនោះពង្រីកធំឡើងក្តី ក៏មិនមានការធានាថានារីនឹងអាចមានឱកាសល្អថ្មីនេះទេ ជាពិសេសសំរាប់មុខងារដែលត្រូវការជំនាញឯកទេសខ្ពស់ជាង ដែលនឹងអាចកើតមានឡើងខណៈដែលរោងចក្រធំៗ រួមបញ្ចូលគ្នានិងរើរុះរៀបចំរចនាសម្ព័ន្ធក្នុងវិស័យនោះឡើងវិញនោះ ។

បន្ថែមពីលើការខកខានមិនបានធ្វើការងារជំនាញនោះ មានគ្រោះភយន្តរាយពីស្ថានភាពការងារអាចកាន់ តែអាក្រក់ធ្ងន់ធ្ងរឡើងចំពោះនារីដែលស្ថិតនៅក្នុងវិស័យកាត់ដេរនោះ ។ ប្រសិនបើរោងចក្រកាត់ដេរស្ថិតនៅក្រោមសម្ពាធបង្ខំឱ្យកាត់បន្ថយថ្លៃដើម និងកំណែទម្រង់មិនត្រូវបានអនុវត្ត ពាណិជ្ជកម្មអាចត្រូវបង្ខំឱ្យរឹតបន្តឹង លក្ខខណ្ឌនានានិងរឹតត្បិតប្រាក់ឈ្នួលដើម្បីប្រកួតប្រជែងជាបន្តទៅទៀត ។ គេសង្ឃឹមថាការពាក់ផ្លាកឱ្យវិស័យកាត់ដេរដើម្បីទាក់ទាញការចាប់អារម្មណ៍ក្នុងកំរិតខ្ពស់ អតិថិជនអ្នកទិញដូរនឹងជំទាស់រារាំងនឹងសម្ពាធទាំងនេះមកលើម្ចាស់រោងចក្រ ។

កំណែទម្រង់ពាណិជ្ជកម្ម បានផ្តល់ឱ្យនូវឱកាសល្អព្រមទាំងគ្រោះថ្នាក់មកជាមួយផងដែរ ក្នុងករណីវិស័យកាត់ដេរនៅកម្ពុជា ឱកាសទាំងនេះរួមមានសក្តានុពលសំរាប់ការបង្កើតការងារថ្មីៗនៅក្នុងវិស័យកាត់ដេរ ។ ឱកាសដ៏មានសក្តានុពលដទៃទៀតរួមមានការបង្កើតឧស្សាហកម្មថ្មីៗ ដូចជាវាយនភណ្ឌដើម្បីដាក់បញ្ចូលទៅក្នុងវិស័យសំលៀកបំពាក់ និងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ច ដែលគេស្នើឡើងដើម្បីទាក់ទាញវិនិយោគ ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីទាញយកផលប្រយោជន៍ពីឱកាសល្អទាំងនេះ កម្មការិនីនឹងតម្រូវឱ្យមានការគាំទ្រដែលក្នុងនោះរួមមាន ការគាំទ្រឱ្យមានប្រាក់កម្រៃ និងអភិវឌ្ឍន៍

ជំនាញការ ។ លើសពីនេះ តម្រូវឱ្យមានវិធានការការងារ ដើម្បីបន្ធូរបន្ថយឱនភាពធ្លាក់ចុះដ៏មានសក្តានុពលនៃកំណែទម្រង់ពាណិជ្ជកម្មដើម្បីកម្មករិនីកាត់ដេរ ។

# ៥ សេចក្តីត្រូវការឱ្យមានអន្តរាគមន៍

ដោយផ្អែកលើការវិភាគគម្រោងការសង្ខេបផ្សេងៗ តើអ្វីជាសេចក្តីត្រូវការនៃការគាំទ្រកម្មការិនី ? សេចក្តីត្រូវការឱ្យមានសេចក្តីសង្ខេបនៃអន្តរាគមន៍ និងសកម្មភាពនាពេលបច្ចុប្បន្នដែលអាចធ្វើបាន ដើម្បីទាញការយកចិត្តទុកដាក់ដល់ សេចក្តីត្រូវការរបស់កម្មការិនីមានដូចតទៅ :

- ការទ្រទ្រង់ប្រាក់ចំណូល ការចុះបញ្ជីការ និងលិខិតបញ្ជាក់ ។ ជម្រើសយកការគាំទ្រប្រាក់ចំណូល( អាហារទ្រទ្រង់និងជម្រកស្នាក់នៅ) ត្រូវការបង្កើតឱ្យមានឡើងដោយឆាប់រហ័ស ទោះជាមានខ្សត់ខ្សោយទ្រង់ទ្រាយតូច ឬក៏ការបាត់បង់ការងារទ្រង់ទ្រាយធំក្តី ។ប្រព័ន្ធចុះបញ្ជីការនិងប្រព័ន្ធសេវាបញ្ជូនបន្តទាមទារការដាក់បញ្ចូលឱ្យសមស្រប ដើម្បីឱ្យស្ត្រីអាចមានឱកាសការងារថ្មីៗ ។ លើសពីនេះ គំនិតផ្តួចផ្តើមដែលមានស្រាប់ដើម្បីបើកការបណ្តុះបណ្តាលហ្វឹកហ្វឺន និងជម្រើសការងារ ត្រូវការពង្រីកឱ្យកាន់តែទូលំទូលាយឡើងថែមទៀត ។ មានការងារនិងកម្មវិធីជួយរកការងារឱ្យធ្វើមួយចំនួនរួចជាស្រេចទៅហើយ នៅក្នុងទីកន្លែងដែលអាចជួយយកធ្វើជាគំរូបាន ឬក៏អាចឱ្យគេចូលមកពាក់ព័ន្ធផ្តល់សេវាកម្មបាន ។ លើសពីនេះការសាកល្បងដែលជួយផ្តល់ប្រាក់ដោយធនាគារអភិវឌ្ឍន៍ អាស៊ីដែលកំពុងត្រូវបានអនុវត្តដោយដៃគូអង្គការក្រៅរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍ នៅកម្ពុជា (PADEK) នោះ កំពុងបើកជូនការអភិវឌ្ឍន៍បណ្តុះបណ្តាលជំនាញដល់ស្ត្រីដើម្បីចេញចាកពីឧស្សាហកម្មនោះ ។ មានការចំណាយ ថ្លៃដើមច្រើនទាក់ទិននឹងការជួយគាំទ្រប្រាក់ចំណូល និង ប្រាកដជាមានគ្រោះថ្នាក់ដល់កម្មករនិងដល់ប្រទេសកម្ពុជាតែម្តង ប្រសិនបើគ្មានធ្វើអ្វីសោះនោះ ។ ជំហានដំបូងត្រូវតែបង្កើតជាគំរូនិងមានថ្លៃចំណាយដែលរៀបរាប់រ៉ាយរ៉ាប់ឱ្យបានពិស្តារច្រើនជាងនេះ សំរាប់ការជួយទ្រទ្រង់ប្រាក់ចំណូល ការចុះបញ្ជីការ និងសេវាបញ្ជូនបន្ត (referal)ដោយដកបទពិសោធន៍ក្នុងប្រទេសកម្ពុជានិងក្នុងតំបន់ ដែលក្នុងនោះរួមមានជម្រើសទាំងឡាយសម្រាប់ ផ្តល់ឱ្យនូវសន្តិសុខសង្គម និង ការគាំពារផ្នែកសង្គមកិច្ចកំពុងត្រូវបានស្នើឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងម្ចាស់ជំនួយ នាពេលថ្មីៗនេះ ។

- ការបណ្តុះបណ្តាលជំនាញការសំរាប់ជម្រើសការងារនិងការបង្កើតការងារ : ទោះបីជាមានឱនភាពធ្លាក់ចុះរយៈពេលវែងក្នុងវិស័យនោះក្តី ក៏មានការរៀបចំផែនការនាពេលឥឡូវនេះ សំរាប់កម្មវិធីជម្រើសជាបន្តបន្ទាប់ នៅក្នុងមុខរបរក្រៅពីវិស័យកាត់ដេរ ។ ការសាកល្បងរបស់អង្គការប៉ាដិកជាឧទាហរណ៍មួយ ។ ក្រសួងកិច្ចការនារីកំពុងតែបើកមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីឡើងវិញដើម្បីផ្តល់ការបណ្តុះបណ្តាលជំនាញ ឱកាសប្រើប្រាស់ឥណទានខ្នាតតូច និងជំនាញក្នុងសហគ្រាសដល់នារីតាមតំបន់ជនបទដាច់ស្រយាល ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តួចផ្តើមគំនិតបណ្តុះបណ្តាលជំនាញណាមួយសំរាប់ការងារជម្រើសត្រូវតែផ្តោតការយកចិត្តទុកដាក់លើសេចក្តីត្រូវការសុំទាមទារជាបន្ទាន់ និងមុខរបរវិជ្ជាជីវៈបែបទំនើបថ្មីមិនមែនធ្វើតាមបែបប្រពៃណីទម្លាប់ចាស់ នៅកម្ពុជានិងក្នុងតំបន់ ។ ការបង្រៀនស្ត្រីឱ្យចេះការអ៊ុតសក់ កាត់សក់ និងដេរប៉ាក់នៅមិនទាន់គ្រប់គ្រាន់ទេ បើគ្មានតម្រូវការទីផ្សារសំរាប់ជំនាញទាំងនេះនោះ ការផ្តួចផ្តើមគំនិតនេះនឹងបរាជ័យទៅវិញ ។

សកម្មភាពការបង្កើត ការងារមានសារៈសំខាន់យ៉ាងប្រត្យក្សណាស់ ដោយសារតែឱកាសទីផ្សារការងារតូចចង្អៀតពេក សំរាប់នារី ។ អង្គការនិងគម្រោងខាងយេនឌ័រ ត្រូវតែធ្វើសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយទាំងឡាយដើម្បីធានាឱ្យបានថាសកម្មភាពបង្កើតការងារ គួរគិតគូរពិចារណាអំពីបញ្ហាខាងភេទ(យេនឌ័រ)និងនារីជាគោលដៅប្រកបដោយប្រសិទ្ធភាព ។

ការបណ្តុះបណ្តាលជំនាញនៅក្នុងរោងចក្រៈ ការបណ្តុះបណ្តាលជំនាញបន្ថែមទាំងរយៈពេលវែងនិងខ្លីពិតជាត្រូវការចាំបាច់សំរាប់ស្ត្រីដែលស្ថិតនៅក្នុងឧស្សាហកម្មកាត់ដេរនោះ ។ ជាបឋម ការបណ្តុះបណ្តាលជំនាញនេះត្រូវ ឱ្យទាក់ទិនជាមួយនឹងជំនាញក្នុងពេលឥឡូវនេះ ដោយផ្តល់ការហ្វឹកហ្វឺន ដែលគេទទួលស្គាល់ជាផ្លូវការដល់ស្ត្រី ឱ្យពួកគេអាចមានសន្តិសុខការងារប្រកបដោយនិរភ័យចាកផុតក្តីបារម្ភ ហើយផ្តល់នូវជំនាញដែលអាចផ្លាស់ប្តូរបានដល់ពួកគេ។ ។ នារីត្រូវការកម្មវិធីហ្វឹកហ្វឺនរយៈពេលវែងដើម្បី អាចទាញយកផលប្រយោជន៍ពីកាលានុវត្តន៍/ឱកាសដែល គេត្រូវការជំនាញខ្ពស់ជាងនេះដែលនឹងត្រូវទទួល ។ សមាគមនី ផលិតករសំលៀកបំពាក់ក្នុងកិច្ចសហការជាមួយអង្គការពលកម្មអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងកិច្ចការនារីឥឡូវកំពុងតែពង្រីកកម្មវិធីដែលអនុញ្ញាតឱ្យមានសិទ្ធិចូលស្មើភាពគ្នាដែល ត្រូវផ្តល់ជូនដោយមជ្ឈមណ្ឌលហ្វឹកហ្វឺនកាត់ ដេរសំលៀកបំពាក់ (GTC) ហើយគំនិតផ្តួចផ្តើមថ្មីៗណាមួយគួរតែត្រូវ អនុវត្តក្នុងភាពជាដៃគូជាមួយនឹងអង្គការទាំងនេះ ។

ការយកចិត្តទុកដាក់នឹងការងារសមស្រប ៈ ដូចដែលបានពិពណ៌នាត្រួសៗខាងលើស្រាប់ថា នៅពេលដែលការងារក្នុងវិស័យកាត់ដេរ ជួយផ្តល់ឱ្យនារីខ្មែរនូវឱកាសចូលទៅធ្វើការដែលមានប្រាក់ឈ្នួលមិនធ្លាប់មានពីមុនមក នេះហើយដែលកម្មការិនីមានកម្រៃ ។ សកម្មភាពការងារត្រឹមត្រូវ ណែនាំដោយអង្គការពលកម្មអន្តរជាតិជាបញ្ហាសំខាន់ ទាក់ទិននឹងការការផ្តួចផ្តើមគំនិតដាក់ផ្លាកឈ្មោះ ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា ។ ការជួយគាំទ្រគំនិតផ្តួចផ្តើមទាំងនេះឱ្យបន្តដំណើរទៅមុខទៀតនោះ នឹងមានសារៈសំខាន់ខ្លាំងណាស់ដល់វិស័យនេះ និងដល់ការងាររបស់នារីៗ ។ លើសពីនេះ អន្តរាគមន៍ដែលគួរសវាស រៀបចំឡើងដើម្បីប្រឆាំងតទល់នឹងស្លាកស្នាមទុយិសដែលជាប់មកតាមជាមួយនឹងការងារផ្នែកកាត់ដេរហើយនិង ការលើកកម្ពស់ការទទួលស្គាល់នូវការចូលរួមផ្នែកសេដ្ឋកិច្ចរបស់នារីៗ គឺជាសេចក្តីត្រូវការចាំបាច់ផងដែរ ។

ទំនាក់ទំនងជាមួយនឹងវិស័យក្រៅប្រព័ន្ធ ៈ មានវិស័យក្រៅប្រព័ន្ធដ៏សំខាន់មួយដែលជួយគាំទ្រដល់ឧស្សាហកម្មកាត់ដេរនេះដែលក្នុងនោះរួមមានកម្មករបម្រើការតាមផ្ទះ(home-workers)និងកម្មករស៊ីបុង(ដេរម៉ៅការ pieceworkers) ដែលក្នុងចំណោមអ្នកទាំងនោះភាគច្រើនជាស្រីៗ ។ លើសពីនេះ វិស័យក្រៅប្រព័ន្ធនោះ គឺជា ទីដៅរួមទូទៅដល់ស្ត្រីភាគច្រើនដែលចេញចាកពីការងារផ្នែកកាត់ដេរ ។ ទោះបីជាយ៉ាងណាក៏ដោយ រហូតមកដល់ សព្វថ្ងៃមានទិន្នន័យតិចតួចណាស់ស្តីអំពីនារីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ឧទាហរណ៍ គេយល់ដឹងតិចតួចណាស់អំពី ទំហំ សមាសភាព កម្រិតប្រាក់ចំណូល លក្ខខណ្ឌធ្វើការនៃការងារទាំងឡាយក្នុងវិស័យក្រៅប្រព័ន្ធដែល ជួយគាំទ្រឧស្សាហកម្មកាត់ដេរ ។ ក្នុងដំណាក់កាលទីមួយ តម្រូវឱ្យមានការសាវជ្រាវបន្ថែមដើម្បីបង្កើន ការយល់ដឹងឱ្យកាន់តែប្រសើរឡើងអំពីការងារក្នុងវិស័យមិនផ្លូវការនោះ ។ អង្គការពលកម្ម

អន្តរជាតិក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ឥឡូវនេះកំពុងតែទទួលធ្វើគម្រោងធំមួយ អំពីវិស័យក្រៅប្រព័ន្ធ ។ ទោះបីជាយ៉ាងណាក៏ដោយ រហូតមកដល់បច្ចុប្បន្ននេះ ការនេះថ្វីត្បិតមិនទាន់មានការយកចិត្តទុកដាក់ខាងយេនឌ័រនៅឡើយ ក្តីក៏វានឹងមានសារៈសំខាន់ជាសារវន្តក្នុងការធានាឱ្យបានថា ទស្សនវិស័យអំពីយេនឌ័រមានរួមបញ្ចូលនៅក្នុងកិច្ចការងារនេះ និងក្នុងយុទ្ធសាស្ត្រទាំងឡាយ ដើម្បីពង្រីកការការពារដល់កម្មករក្នុងវិស័យក្រៅប្រព័ន្ធ ឧទាហរណ៍ ដូចជាដោយការវិសោធនកម្មច្បាប់ក្រមការងារ ។ ដំណាក់កាលជាបឋម ការងារនេះអាចទាក់ទិននឹងការស្រាវជ្រាវអំពីការងារវិស័យក្រៅផ្លូវការ ក្នុងកិច្ចសហការជាមួយអង្គការពលកម្មអន្តរជាតិ/វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ។

- ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូចនិងមធ្យម(សតម/SME)៖ វិស័យដែលពាក់ព័ន្ធគ្នាសំខាន់មួយនោះ គឺជាការផ្តល់ឱ្យនូវកម្មវិធីអភិវឌ្ឍន៍ សតម ដើម្បីស្ត្រី ។ ការវិនិយោគកាន់តែធំឡើងក្នុងការអភិវឌ្ឍន៍ សតម ទាំងឡាយ (SMEs) គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានចង្អុលបង្ហាញនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលស្រាប់ និងមានគំនិតផ្តួចផ្តើមមួយចំនួន ជួយដល់ការអភិវឌ្ឍន៍ សតម ដែលក្នុងនោះរួមមានជំនាញក្នុងភាពជាសហគ្រាស ឱកាសទទួលបានឥណទានខ្នាតតូច ព័ត៌មានទីផ្សារ និងការបង្កើតសមាគមពាណិជ្ជកម្ម ។ វានឹងមានសារៈសំខាន់ក្នុងការលើកស្ទួយគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ សតម ដោយផ្តោតទៅរកនារីនៅក្នុងការងារក្រៅប្រព័ន្ធ និងក្នុងឧស្សាហកម្មដែលមានស្ត្រីច្រើនលើសលប់ ដូចជាការដើរលក់ដូរតាមផ្លូវនិងការលក់រាយកំប៉ិកកំប៉ុក ។ ការពិនិត្យមើលឡើងវិញនូវគំនិតផ្តួចផ្តើម សតម ដែលមានស្រាប់ក្នុងការចូលទៅពាក់ព័ន្ធនិងផ្តោតអារម្មណ៍លើនារីៗនោះ នឹងមានសារៈសំខាន់ជាជំហានដំបូង ។

- ឱកាសទទួលបាននូវការអប់រំវិជ្ជាជីវៈ និងការហ្វឹកហ្វឺន ៖ ការវិនិយោគផ្នែកធនធានមនុស្សគឺជាកម្មវិធីជាគន្លឹះ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទទួលបន្ទុកអភិវឌ្ឍកម្លាំងពលកម្មប្រកបដោយជំនាញ ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ទាំងឡាយរបស់កម្ពុជា ដែលក្នុងនោះរួមមានតាមរយៈបង្កើតផែនការអភិវឌ្ឍន៍ធនធានមនុស្សមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការបើកវគ្គអប់រំនិងបណ្តុះបណ្តាលនៅកម្ពុជានោះ បន្តការលំបាកពីព្រោះតែប្រព័ន្ធអប់រំអន់ថយ និងកំរិតនៃការអប់រំនៅទន់ទាប ជាពិសេសក្នុងបណ្តាស្ត្រីទាំងឡាយ ។ ក្នុងករណីបណ្តុះបណ្តាលនិងអប់រំវិជ្ជាជីវៈការផ្តល់ឱ្យ ផ្នែកសាធារណៈនៅមានកំរិតតូចណាស់ និងមានឱកាសទទួលបានការហ្វឹកហ្វឺនតិចតួចចំពោះនារីដែលមានអាយុពេញវ័យធ្វើការក្រៅពីមុខរបរអាជីពក្នុងវិស័យតូចចង្អៀត ដូចជាការកាត់ដេរ កែសម្ផស្ស និងការអ៊ុតសក់ កាត់សក់ ។ ការកែប្រែបន្ថែមមួយក្នុងគោលនយោបាយបណ្តុះបណ្តាល តម្រូវឱ្យបើកវគ្គសមរម្យនិងពង្រីកឱ្យមានការចូលរួមពីស្ត្រី ដែលក្នុងនោះរួមមានមុខរបរអាជីពបែបទំនើបដែលកំពុងតែកើតឡើង ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញថាខ្លួនសុខចិត្តធ្វើកិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP/ យូនីហ្វាម UNIFEM និងទីភ្នាក់ងារដទៃទៀតដើម្បីប្រឈមដោះស្រាយបញ្ហាទាំងនេះ ។

- ការត្រួតពិនិត្យតាមដានមើលអំពីដំណើរជឿនលឿន ៖ ជាអវសានចុងក្រោយ ការធ្វើឱ្យប្រាកដ ថាយន្តតាមដានមានដំណើរការធានាឱ្យបាន ថាផលប៉ះពាល់ពីការផ្លាស់ប្តូរវិស័យកាត់ដេរអាចគេវាស់វែងបានហើយត្រូវដាក់បញ្ចូលទៅក្នុង

របាយការណ៍ ទាក់ទងដំណើរការជឿនលឿនទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ឧទាហរណ៍ ការនេះជារួមមានបង្កើតសន្ទស្សន៍បន្ថែមដូចជា ទីដៅចាកចេញរបស់កម្មការិនី ស្ថានភាពការងារ និងអត្រាចូលរួម ក្នុងការបណ្តុះបណ្តាលយុវតី និងស្ត្រីដែលមានអាយុ ពី ១៥ ទៅ ២៤ ឆ្នាំ និងកំរិតភាពក្រីក្រនៃកម្មករកាត់ដេរ និងគ្រួសាររបស់ពួកគេ ។ កិច្ចចរចាជាមួយទីភ្នាក់ងារដែលមានការទទួលខុសត្រូវក្នុងការពិនិត្យតាមដាន និងការប្រមូលទិន្នន័យនោះ នឹងត្រូវការធានាឱ្យបានថាសូចនាករ (សន្ទស្សន៍) ទាំងឡាយ (indicators) អាចទទួលយកមកប្រើ ប្រាស់បាន ។

## ៦ ដំណើរការទៅមុខ

ភារកិច្ចរៀបចំផែនការនិងអនុវត្តសកម្មភាព ដើម្បីប្រឈមដោះស្រាយនូវផលប៉ះពាល់នៃការផ្លាស់ប្តូរ ក្នុងវិស័យកាត់ដេរមកលើកម្មការិនីកាត់ដេរ គឺជាការរួមចំណែកទទួលខុសត្រូវ ចំណុចមួយដែលទាក់ទិននឹងអ្នកពាក់ព័ន្ធជាច្រើន ផ្នែកដូចជារដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ឧស្សាហកម្មកាត់ដេរ កម្មករសហជីព និងអតិថិជន អ្នកទិញដូរ ។ ការប្រកួតប្រជែងដ៏សំខាន់គឺត្រូវអនុវត្តសកម្មភាព ពីពេលឥឡូវនេះដើម្បីប្រុងប្រៀបរៀបចំសំរាប់គ្រោះអន្តរាយដែលមានសក្តានុពល និងបន្តពួតដៃគ្នាឱ្យបានធំទូលាយពីអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីរៀបផែនការ និងធ្វើការងាររួមជាមួយគ្នា ធានាឱ្យបានថាគ្រោះថ្នាក់នោះ បានដឹង និងបានដោះស្រាយ ។ ភារកិច្ចនេះពាក់ព័ន្ធនឹងខ្នាតវាស់វែងដូចខាងក្រោម :

- បន្តចូលប្រឡូកឱ្យបានច្រើនលំដាប់ថ្នាក់ពីអ្នកពាក់ព័ន្ធទាំងឡាយ ក្នុងកិច្ចសន្ទនាដែលកំពុងតែប្រព្រឹត្តរៀបចំផែនការ មានសកម្មភាពនិងពិនិត្យតាមដានភាពជឿនលឿនដោយ ចូលរួមរៀនសូត្រពីគ្នា និងពង្រីកបន្ថែមការងារដែល ដំណើរការរួចដើម្បីជួយទ្រទ្រង់កម្មការិនីកាត់ដេរនិងគាំពារឱ្យមានសន្តិសុខផុតក្តីព្រួយកង្វល់ដល់អនាគតនៃវិស័យសំលៀកបំពាក់នោះ ។
- ទំនាក់ទំនងនិងរៀនសូត្របទពិសោធន៍ពីក្នុងតំបន់និងអន្តរជាតិ នាំយកអង្គការអន្តរជាតិនិងដំណាងមកក្នុងប្រទេសកម្ពុជាក្នុងការចូលរួមក្នុងសន្ទនា និងដោយធានាថាកម្ពុជាមានសម្លេងមួយក្នុងតំបន់ក៏ដូចជាក្នុងពិភពលោក ។
- បង្កើតជាគំរូនិងការចំណាយសំរាប់ការជួយទ្រទ្រង់ប្រាក់ចំណូល ការចុះបញ្ជីការ និងសេវាបញ្ជូនបន្ត ក្នុងការជួយស្ត្រីដែលគេកាត់ចេញពីការងារ និងធ្វើការឧបត្ថម្ភផ្តល់មូលនិធិដល់សេវាគាំទ្រ ដោយមានការចូលរួម យកចិត្តទុកដាក់ពីគ្រប់ភាគីមានដូចជាខាងរដ្ឋាភិបាលជាដើម ។
- ធានាឱ្យបានថាការធ្វើទំនាក់ទំនងជាមួយវិស័យដទៃទៀត និងគំនិតផ្តួចផ្តើមទាំងឡាយនៅតែមានជាបន្ត ដែលមានដូចជាការងារសមស្របក្នុងវិស័យក្រៅប្រព័ន្ធ អភិវឌ្ឍន៍សហគ្រាសខ្នាតតូចនិងមធ្យម សតម (SME) ការផ្តល់គោលនយោបាយបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈ ។
- បង្កើតឧបករណ៍ (Tools) ស្រាវជ្រាវថ្មីៗសំរាប់ការតស៊ូមតិ ឧទាហរណ៍ដូចជា( ការស្រាវជ្រាវ អំពីស្ត្រីក្នុងវិស័យក្រៅប្រព័ន្ធ ។
- ធ្វើបណ្ណកំណត់ត្រាពិន្ទុមួយ (a scorecard) ដើម្បីត្រួតពិនិត្យតាមដានភាពជឿនលឿន ប្រាក់កម្រៃដែលរកបាន និងការផ្តួចផ្តើមគំនិតដែលបានទទួលយក និងផលប៉ះពាល់របស់វា ក្នុងគោលបំណងតាមដានវាស់វែងមើលនូវឥទ្ធិពល នៃការផ្លាស់ប្តូរខាងវិស័យកាត់ដេរមកលើកម្មការិនី និងការជឿនលឿនរបស់កម្ពុជាទៅរក គោលដៅអភិវឌ្ឍន៍ជាគន្លឹះដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) នៅជាអាទិ៍ ។

ការសង្ឃឹមរង់ចាំមើលភាពល្អប្រពៃមិនទាន់គ្រប់គ្រាន់ទេ ។ កម្ពុជាជំពាក់ឧបការគុណច្រើនទៀត ចំពោះយុវតី វ័យក្មេងទាំងនេះដែលបានជួយទ្រទ្រង់គ្រួសារនិងជួយធ្វើឱ្យមានកំណើនលូតលាស់សេដ្ឋកិច្ច ។ ការប្រកួតប្រជែងគឺថាត្រូវ តែចាប់អនុវត្តនាពេលឥឡូវនេះ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរដែលកំពុងតែចូលមកដល់ ។ នៅកំរិតអន្តរជាតិ តាមរយៈ មធ្យោបាយផ្សេងៗដូចជា ប៉េកាំង+10 អង្គការជួយគាំទ្រ បានឈរក្នុងជំហរដ៏រឹងមាំក្នុងការដាក់សម្ពាធលើអតិថិជនអ្នក ទិញជួរ រដ្ឋាភិបាល និងឧស្សាហកម្មកាត់ដេរឱ្យចាត់វិធានការ ។ នៅឯកំរិត ថ្នាក់ជាតិ រាល់អ្នកពាក់ព័ន្ធទាំងអស់មានការទទួល ខុស ត្រូវនឹងធ្វើកិច្ចការជាមួយគ្នាដើម្បីគ្រោងផែនការនិងធ្វើកិច្ចការពារកម្មការិនីកាត់ដេរ និងធានាឱ្យបានថាពួកគេមិនអាចគេច ផុតពីកំណើនលូតលាស់នេះទេ តែអាចចូលរួមនិងទទួលផលប្រយោជន៍ ពីការផ្លាស់ប្តូរប្រែប្រួល ដែលកើតមានឡើងដោយ សារតែកំណែទម្រង់ពាណិជ្ជកម្មនោះមកវិញ ។

# ឯកសារយោង


- ធនាគារអភិវឌ្ឍន៍អាស៊ី ទស្សនវិស័យអភិវឌ្ឍន៍អាស៊ាន២០០៤អេ (2004a) ធនាគារអភិវឌ្ឍន៍អាស៊ីទីក្រុង ម៉ានីល
- ធនាគារអភិវឌ្ឍន៍អាស៊ី២០០៣ ជំនួយការបច្ចេកទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ការភាពក្រីក្រនិងផ្តល់សិទ្ធិអំណាចដល់កម្មការិនីរោងចក្រ ដែលប៉ះពាល់ដោយសារការប្រែប្រួលបរិយាកាសពាណិជ្ជកម្មអន្តរជាតិ ធនាគារអភិវឌ្ឍន៍អារស៊ី ទីក្រុងម៉ានីល
- Baier-D'Orezo, M. 2004 ( ឯកសារនៅមិនទាន់បោះពុម្ភ) ការបណ្តុះបណ្តាលយុវតីវ័យក្មេងនិងនារី : ការពិចារណាមើលតំបន់ខ្លះ ។
- បេរេស្វដ អិម អេតអាល់ ២០០៤ ( Bereford,M. et al 2004) ការកាត់បន្ថយភាពក្រីក្រ នៃសេដ្ឋកិច្ចខ្នាតធំនៅកម្ពុជា កម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ ភ្នំពេញ
- អ្នកស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៍ (CRD) និយោជិតកាត់ដេរ២០០៤នៅកម្ពុជា :ការស្ទង់មើលសេដ្ឋកិច្ច សង្គម ធនាគារអភិវឌ្ឍន៍អាស៊ី ភ្នំពេញ
- អង្គការឃែរអន្តរជាតិ ១៩៩៩ ការកាត់ដេរដើម្បីអនាគតប្រសើរឡើងឬ ? អង្គការឃែរ ភ្នំពេញ
- កាតាហ្គេ អិន យេនឌ័រ ២០០១កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិផ្នែកពាណិជ្ជកម្មនិងភាពក្រីក្រ ចេណេវ៉ា
- ចាន់ សុផល និង សោ សុវណ្ណរិថ ចំណាកស្រុករកការងារធ្វើរបស់ប្រជាជនកម្ពុជាទៅកាត់ប្រទេសថៃ១៩៩៩: ការវាយតម្លៃជាបឋម ឯកសារការងារ ១១ វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ
- ជា ហួត និងសុខ ហាច ២០០១ ( ឧស្សាហកម្មកាត់ដេរកម្ពុជា) ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ច្បាប់លេខ៥( ៣) កក្កដា-កញ្ញា២០០១ វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គម២០០៤ ( ដែលជិតមកដល់) សន្ទស្សន៍ត្រួតពិនិត្យមើលភាពក្រីក្រនិងការអភិវឌ្ឍន៍នៅកម្ពុជា (CPDMI) និយមន័យនិងប្រភពទិន្នន័យ ដែលរៀបចំដោយក្រុមជំនួយបច្ចេកទេស វិភាគ និងត្រួតពិនិត្យភាពក្រីក្រ ក្រសួងផែនការ ភ្នំពេញ
- តងគ្និសថី អិម ការធ្វើផលិតកម្មសំលៀកបំពាក់ឱ្យមានតម្លៃ: ការស្ទង់មើលចលនាសហជីពពាណិជ្ជកម្ម នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា ភ្នំពេញ
- យេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីយេនឌ័រនៅកម្ពុជាឆ្នាំ២០០៣ ក្នុងការបណ្តុះបណ្តាល អប់រំវិជ្ជាជីវៈ និង បច្ចេកទេស GAD ភ្នំពេញ
- ហ្គុដប្រ្វាយ អិម អេត អាល់២០០១ ការសិក្សាទីផ្សារការងារកម្ពុជា : យោងតាម ឯកសារស្តីពីការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងកែសម្រួលវិបត្តិ ឯកសារការងារ ១៨ វិទ្យាស្ថានស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ

- ហ្គមែន ស៊ី អូភាន អេត អាល់១៩៩៩ យេនឌ័រនិងការអភិវឌ្ឍន៍នៅកម្ពុជា: ឯកសារការងារត្រួតមើល ១០ វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា ភ្នំពេញ
- ហ្គមែន ស៊ីអូភាន ១៩៩៧ ការទាក់ទិនគ្នានៃការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមដើម្បីការងាររបស់ស្ត្រី នៅកម្ពុជា : ករណីសិក្សាអំពីកម្មកររោងចក្រកាត់ដេរ មជ្ឈមណ្ឌលអប់រំយុវជនឧត្តមសិក្សា អ្នកគ្រប់គ្រង
- ហ្គោថូស្កា អេះ ២០០១ នារីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅអាស៊ីភាគអាគ្នេយ៍: ការត្រួតពិនិត្យមើលឡើងវិញ នូវការនិពន្ធចងក្រង គណៈកម្មការដើម្បីនារីនៅអាស៊ាន ទីក្រុងបាងកក
- មូលនិធិរូបិយវត្ថុអន្តរជាតិ២០០៤កម្ពុជា: សេចក្តីថ្លែងការណ៍បូកសរុបសំរាប់អត្ថបទឆ្នាំ២០០៤ IV Consultation Discussion មូលនិធិរូបិយវត្ថុអន្តរជាតិ IMF
- *គ្រឹះស្ថានអភិវឌ្ឍន៍វិស័យឯកជនទន្លេមេគង្គ*MPDF 2005 វិស័យកាត់ដេរនៅកម្ពុជា : ទស្សនវិស័យក្រោយកិច្ចព្រមព្រៀងពហុវាយនភណ្ឌ ព្រឹត្តិប័ត្រ បញ្ហាពាណិជ្ជកម្ម (៥) MPDF ភ្នំពេញ
- នុត អិម២០០៥ (Nuth, M. 2005)( ការត្រួតពិនិត្យមើលការនិពន្ធចងក្រងស្តីអំពីការងារសមស្រប នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅ កម្ពុជា) ការឡើងបកស្រាយនៅឯសិក្ខាសាលាសេដ្ឋកិច្ចក្រៅប្រព័ន្ធ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥ ។
- ណារ៉ុន ហង្ស ជួន ២០០២ (Naron, Hang Chuon2002) ប្រសិទ្ធភាពនៃសមាជិកភាពអង្គការ ពាណិជ្ជកម្មពិភពលោកស្តីអំពីសហគ្រាសខ្នាត តូចនិងមធ្យម (SMEs) និងវិស័យកាត់ដេរកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភ្នំពេញ
- ណដាស អេច្ចឃេ ២០០៤(Nordas,H.K.2004) ឧស្សាហកម្មសំលៀកបំពាក់និងវាយនភណ្ឌពិភពលោកក្រោយកិច្ចព្រមព្រៀងស្តី អំពីសំលៀកបំពាក់និងវាយនភណ្ឌ អង្គការពាណិជ្ជកម្មពិភពលោក ចេណេវ៉ា
- នុរិន អេ ២០០២ (Nurin, A.2002)សេដ្ឋកិច្ចក្នុងវិស័យក្រៅប្រព័ន្ធ នៅអាស៊ី ចេញពីទស្សនវិស័យការងារ សមស្របអង្គការពលកម្មអន្តរជាតិ ចេណេវ៉ា
- អង្គការអុកស្វាមអន្តរជាតិ ២០០៤ អេ Trading Away Our Right អង្គការអុកស្វាមអន្តរជាតិ ទីក្រុងអុកស្វ៊ដ
- អង្គការអុកស្វាមអន្តរជាតិ ២០០៤ បេ ការចូលអង្គការពាណិជ្ជអន្តរជាតិរបស់កម្ពុជា : តើត្រូវមានច្បាប់បែបណាចំពោះប្រទេសក្រីក្រមួយនេះ អ៊ុកស្វាមអន្តរជាតិ ទីក្រុងអុកស្វ៊ដ
- អង្គការអុកស្វាមអន្តរជាតិ ឆ្នាំ២០០១ ការធ្វើប្រសើរឡើងនូវពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ អ៊ុកស្វាមអន្តរជាតិ ទីក្រុងអុកស្វ៊ដ
- រាជរដ្ឋាភិបាលកម្ពុជា ២០០៤ បេ គម្រោងចំណាយក្នុងអាណត្តិជាមធ្យមសេចក្តីព្រាងបឋមរបស់កម្ពុជារវៀងឆ្នាំ ២០០៥-២០០៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភ្នំពេញ
- រាជរដ្ឋាភិបាលកម្ពុជា២០០៤ប៊ី ផែនការយុទ្ធសាស្ត្រអប់រំ ក្រសួងអប់រំយុវជននិងកីឡា ភ្នំពេញ
- រាជរដ្ឋាភិបាលកម្ពុជា២០០៤២០០៤ស៊ី នារីរតនៈទី២ :ក្រសួងកិច្ចការនារី ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ

ក្រសួងកិច្ចការនារី ទីក្រុងភ្នំពេញ

- រាជរដ្ឋាភិបាលកម្ពុជា២០០៣កម្ពុជា: យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ២០០៣-២០០៥ រាជរដ្ឋាភិ បាលកម្ពុជា ភ្នំពេញ
- សាលិញ្ជ័រ អិល២០០៤(Salinger,L.2004) ខ្នាតវាស់វែងទាំងដឹងនិងមិនដឹង នៃការប្រកួតប្រជែង វិស័យកាត់ដេរកម្ពុជា ក្រោយឆ្នាំ២០០៤: លទ្ធផលនៃបេសកកម្មឆ្លុះមើល ទីភ្នាក់ងារសហរដ្ឋអាមេរិក សំរាប់ការអភិវឌ្ឍន៍អន្តរជាតិ USAID
- សម្តេចហ៊ុនសែន ២០០៤ សេចក្តីថ្លែងការណ៍ស្តីអំពី យុទ្ធសាស្រ្តចតុកោណដើម្បីការលូតលាស់ ការងារសមធម៌និងប្រសិទ្ធភាព កិច្ចប្រជុំគណ:រដ្ឋមន្ត្រីដំបូងនៃសភាជាតិនៃនីតិការទី៣ នៅឯការិយាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤
- លោក សុខ ហាច ២០០៥ ( ផលប៉ះពាល់ពីការលុបចោលប្រព័ន្ធបរិមាណកំណត់មកលើកម្មការិនីកាត់ដេរនៅ កម្ពុជា) សេចក្តីឡើងថ្លែងបង្ហាញនៅក្នុងសន្ទនាអំពីនយោបាយរបស់អ្នកពាក់ព័ន្ធច្រើនគ្នាអំពីផលប៉ះពាល់ នៃពាណិជ្ជសេរីភាវូបនីយកម្មលើកម្មការិនីនៅកម្ពុជា ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៥។
- លោក សុខ ហាច ២០០៤ ( ឧស្សាហកម្មកាត់ដេរកម្ពុជា ឆ្នាំ ២០០៥ និងពេលក្រោយៗ: ការវិភាគ បរិមាណនៃការប្រកួតប្រជែងដ៏លំបាក) ទស្សនាវដ្តីសេដ្ឋកិច្ច វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ថ្ងៃទី១/៥ ខែកក្កដា-កញ្ញា ឆ្នាំ២០០៤
- លោក សុខ ហាច អេត អាល់ ២០០១ ( ឧស្សាហកម្មកាត់ដេរនៅកម្ពុជា : ការអនុវត្តន៍ ការប្រកួតប្រជែង និងនយោបាយ) pp ៤៧-៦២ ក្នុងទស្សនាវដ្តីសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ២០០១ វិទ្យាស្ថានស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា២០០១ ភ្នំពេញ
- ឯកឧត្តម សុខ ស៊ីសុផាណា២០០៣ ( ការសិក្សារបស់យូនេស្កាប UNESCAP ស្តីអំពីការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោកWTO -ការសិក្សានៅក្នុងប្រទេសកម្ពុជា) តាមឯកសារដូចដែលបាន ឡើងថ្លែងបង្ហាញនៅក្នុងគំរោងច្របាច់បញ្ចូលគ្នា និង ការចូលជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោក: ការប្រកួតប្រជែងនិងឱកាសសំរាប់ការកាត់បន្ថយភាពក្រីក្រ ថ្ងៃទី១-៣ខែឧសភា ឆ្នាំ២០០៣ ភ្នំពេញ
- អង្គការយូនីហ្វាម អេត អាល់ ២០០៤អេ ភាគហ៊ុនស្មើគ្នាដើម្បីស្ត្រី: សកម្មភាពត្រូវឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដើម្បីនារីនិងបុរស អង្គការយូនីហ្វាម ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស ភ្នំពេញ
- អង្គការយូនីហ្វាម អេត អាល ២០០៤ប៊ី ភាគហ៊ុនស្មើភាពសំរាប់ស្ត្រី: ការវាយតម្លៃយេនឌ័រនៅកម្ពុជា អង្គការយូនីហ្វាម ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស ភ្នំពេញ

- កម្មវិធីរ៉ូមីនដើម្បីការផ្លាស់ប្តូរ២០០៥ (Womyn's Agenda for a change 2005) ការឡើងថ្លែងបង្ហាញ ដោយកម្មករកាត់ដេរនៅក្នុងសន្ទនាគោលនយោបាយរបស់អ្នកពាក់ព័ន្ធច្រើនគ្នាស្តីអំពីផលប៉ះពាល់នៃពាណិជ្ជសេរីភាវូបនីយកម្មលើកម្មការិនីកាត់ដេរនៅកម្ពុជា ថ្ងៃទី១៤ខែមករាឆ្នាំ២០០៥
- វិលល្យែម អិម២០០៤ (Williams, M. 2004) (បញ្ហាយេនឌ័រដែលកំពុងលេចឡើង នាពេលបច្ចុប្បន្ន ក្នុងប្រព័ន្ធពាណិជ្ជកម្មជាពហុភាគី) យោងតាម ឯកសារអំពីប្រវត្តិសង្ខេបសំរាប់កិច្ចប្រជុំពហុភាគី នៃកិច្ចការយេនឌ័រ/ស្ត្រី ហ្វីជី
- វិលល្យែម អិម២០០៣(Williams, M. 2004) មធ្យោបាយដោះស្រាយជាយុទ្ធសាស្ត្រដើម្បីយេនឌ័រ : កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងនយោបាយពាណិជ្ជកម្ម បណ្តាញពាណិជ្ជកម្មនិងយេនឌ័រអន្តរជាតិ ការិប៊ីន
- ក្រុមធនាគារពិភពលោក២០០៤ កម្ពុជា: ការទាញយកឱកាសពិភពលោក: បរិយាកាសវិនិយោគនិង យុទ្ធសាស្ត្រកំណែទម្រង់ ។

## I. ទិសដៅ/គោលបំណង

គម្រោងនេះស្វែងបញ្ជ្រាបយេនឌ័រ ទៅក្នុងកិច្ចការរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) លើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ដែលមានស្រាប់ ដោយសម្ដៅដល់ការកសាងសមត្ថភាពថ្នាក់ជាតិ និង ការងារតស៊ូមតិឬការងារស្វែងរកការគាំទ្រ (Advocacy) ។ គម្រោងនេះនឹងជួយធ្វើជាយានសំរាប់ធានាថា ទំហំយេនឌ័រនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ត្រូវបានគេលើកឡើង ធ្វើវិភាគ និងឆ្លុះបញ្ចាំងក្នុងក្រុមគោលដៅថ្នាក់ជាតិ និងទស្សនវិស័យយេនឌ័រត្រូវបានថែរក្សានៅរាល់ដំណើរការនៃការធ្វើរបាយការណ៍ត្រួតពិនិត្យ និងការតស៊ូមតិលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅគ្រប់ក៏រិតថ្នាក់ជាតិ ។

គម្រោងនេះមានស្ថាប័នគាំទ្រសំខាន់បីនៅគ្រប់លំដាប់ថ្នាក់ក្នុងប្រទេសគឺៈ រដ្ឋាភិបាល សង្គមស៊ីវិល និងក្រុមការងារសហប្រជាជាតិ (UN Country Team) ។ ស្ថាប័នគាំទ្រនីមួយៗនេះមានតួនាទីសំខាន់ណាស់ ដើម្បីឱ្យគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចាក់ឫសបាននៅក្នុងប្រទេសទាំងឡាយ ។

**គោលដៅតូចបន្ទាប់(Sub-goals) នៃគម្រោងទាក់ទិននឹងស្ថាប័នគាំទ្រទាំងបីខាងលើនេះគឺ :**

១- ដើម្បីធ្វើការតស៊ូមតិជាមួយអ្នកធ្វើនយោបាយ និងអ្នកធ្វើផែនការកម្មវិធីទាំងឡាយថាការបញ្ជ្រាបសមភាពយេនឌ័រក្នុងរាល់គោលដៅអភិវឌ្ឍន៍សហប្រជាជាតិ ជាស្នូលសំខាន់សំរាប់ការអភិវឌ្ឍន៍ជាតិ ។

២- ដើម្បីពង្រឹងមធ្យោបាយសំរាប់ការត្រួតពិនិត្យមើលនូវការឆ្លើយតបយេនឌ័រ (Gender Sensitive) និងរបាយការណ៍អំពីការរីកចំរើនទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។

## II យុទ្ធសាស្ត្រ

ប្រទេសទាំងឡាយទាក់ទងនឹងការអនុវត្តន៍សាកល្បងគម្រោងនេះគឺៈ កម្ពុជា (Cambodia) កេនយ៉ា (Kenya) គាហ្គីស្តង់ (Kyrgyzstan) ម៉ារ៉ុក(Maroc) និងប៉េរូ(Peru) ។

### យុទ្ធសាស្ត្រពីរជាគន្លឹះនៃគម្រោងនេះគឺៈ

**ក.ការតស៊ូមតិ–** ប្ដេជ្ញាចិត្តដើម្បីឱ្យមានសមភាពយេនឌ័រនិងការផ្ដល់ឱ្យមានការអនុវត្តន៍សិទ្ធិអំណាចស្ត្រី នៅក្នុងប្រទេសកម្ពុជាតាមរយៈកិច្ចព្រមព្រៀងតាមផែនការសកម្មភាព (PFA) នៃទីក្រុងប៉េកាំង អនុសាសន៍ស្ដីពី ការលុបបំបាត់រាល់ទំរង់រើសអើងប្រឆាំងនឹងនារីភេទ និង លំដាប់ថ្នាក់ធំៗនៃផែនការសកម្មភាពថ្នាក់តំបន់ ថ្នាក់ជាតិនិងកិច្ចព្រមព្រៀង ។ ជាពិសេស ដៃគូគម្រោងនឹងបង្កើតយុទ្ធសាស្ត្រតស៊ូមតិ ឧបករណ៍ និងវិធីសាស្ត្រដែលទាក់ទិន នឹងពតិមានក្នុងការបញ្ជ្រាប សមភាពយេនឌ័រទៅក្នុងយុទ្ធនាការតស៊ូមតិ លើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលមានស្រាប់ ។ ប្រទេសដែលធ្វើការសាកល្បងអនុវត្ត

នីមួយៗ នឹងរៀបចំបង្កើតយុទ្ធសាស្ត្រដ៏សមស្រប ឧបករណ៍ និងយន្តការចែកចាយទាំងអស់នេះត្រូវបានគូសវាសឡើងដើម្បីឱ្យសម្រេចបាននូវគោលដៅរួម ។

**៦.ការកសាងសមត្ថភាព–** ដំណើរការគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ នឹងបន្តទៅអនុវត្តនៅគ្រប់កំរិតប្រទេស នៅឆ្នាំ ២០១៥ ។ សារៈសំខាន់នៃការបង្កើនសមត្ថភាពកំរិតមូលដ្ឋាន តាមរយៈដំណើរការអនុវត្តន៍ គម្រោងនេះ គឺត្រូវបានភ្ជាប់ជាមួយនឹងនិរន្តរភាពយូរអង្វែង ។ ការកសាងសមត្ថភាពនឹងផ្ដោតលើការតស៊ូមតិ ការសន្ទនាពេលនយោបាយ និងការអភិវឌ្ឍន៍ និងការសង្កេតមើលនូវសូចនាករឆ្លើយតបចំពោះយេនឌ័រ ការប្រើប្រាស់និងបង្ហាញនូវទិន្នន័យខូចព្រហ្មចារីប្រព័ន្ធផ្សព្វផ្សាយនិងគមនាគមន៏និងវិធីផ្សេងៗ ដើម្បីបង្កើនលើកទឹកចិត្តឱ្យចូលជាប់ទាក់ទិនគ្នារវាងការអនុវត្តន៏គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។

## III យុទ្ធសាស្ត្រនៅកម្ពុជា

យេនឌ័រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជារបស់យូនីហ្វាម និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ស្វែងរកដៃគូជាមួយនឹងក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.គ.ស) និងបណ្ដាញអង្គការ សង្គមស៊ីវិលដើម្បី :

- បង្កើនការយល់ដឹងតាមរយៈការកសាងសមត្ថភាពអំពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានិងសង្ខេបគោលនយោបាយ យេនឌ័រដល់ក្រុមស្ត្រីក្នុងរាជរដ្ឋាភិបាលកម្ពុជានិងសង្គមស៊ីវិលពីកំរិតថ្នាក់ជាតិដល់កំរិតមូលដ្ឋាន ។
- ធ្វើការតស៊ូមតិជាមួយអ្នកធ្វើនយោបាយលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចំណុចទី១ និងទី៦លើភាពក្រីក្រ របស់នារីកម្ពុជានិងភាពងាយរងគ្រោះឆ្លងរោគហ៊ីវ/ជម្ងឺអេដស៏ នៃស្ត្រីកម្ពុជា ។
- ធ្វើការជាមួយភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ ដើម្បីបញ្ចូលយេនឌ័រទៅក្នុងយុទ្ធនាការគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក្នុងឆ្នាំខាងមុខ ។
- រៀបចំឱ្យមានការសន្ទនារវាងអ្នកធ្វើគោលនយោបាយនិងអ្នកពាក់ព័ន្ធ ។
- ធ្វើយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំពីគោលដៅទី១ និង ទី៦នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

# សីលការ

**សីលការ** ជាអង្គការបង្កើនសមត្ថភាពកម្ពុជាដែលមិនប្រកាន់គណបក្សនយោបាយណាមួយឡើយដែលត្រូវបានចុះ បញ្ជីជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងខែមករា ឆ្នាំ១៩៩៧ ។ សីលការ ធ្វើការដើម្បីពង្រឹងសមត្ថភាពស្ថាប័ន សាធារណៈ ឯកជន និងរដ្ឋាភិបាល តាមរយៈសហប្រតិបត្តិការ អប់រំ និងហ្វឹកហ្វឺន ជំនាញ និង ទ្រឹស្តីស្នូល ផ្នែកការិយាល័យ (ដូចជា ជំនាញរដ្ឋបាល គ្រប់គ្រង និងហិរញ្ញកិច្ច) ព្រមទាំងចូលរួម ឬរៀបចំ និងអនុវត្ត កម្មវិធីផ្សេងៗដើម្បីបង្កើននូវ តម្លាភាព សមភាពយេនឌ័រ និងការទទួលខុសត្រូវ របស់អង្គការនិងស្ថាប័ននានា ។ សីលការ ធ្វើការងារខាងការសម្រុះសម្រួលផងដែរ ដែលជាជំហានសំខាន់ដើម្បីអាចឈានទៅរកការបង្កើតបរិយាកាសសន្តិសុខមនុស្សជាតិ និងអភិវឌ្ឍន៍ ។

**អ្នកទំនាក់ទំនង:**


លោកស្រី ឃិះ ធីដា អ្នកសម្របសម្រួល

យេនឌ័រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

អង្គការសីលការ ផ្ទះលេខ ៦អេស(s) ផ្លូវ ២១

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានី ភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៧ ៨៧២

ទូរសារលេច (៨៥៥) ២៣ ២១៣ ១០៨

ទូរស័ព្ទចល័ត (៨៥៥) ១២ ៨៣៨ ៤៦៤

E-mail: silaka@forum.org.kh

**CONTACT PERSON:**


**Ms. Lucita S.Lazo**
Regional Programme Director
UNIFEM East & Southeast Asia Regional Office
5th Floor, UN Building
Rajadamnern Avenue
Tel: (662) 288-2093/288-2589
Fax: (622) 280-6030